លឹម ផល្គុន និង សែន ពិសិដ្ឋ
បរិញ្ញាបត្រផ្នែក គណិតវិទ្យា

# កំណែលំហាត់

# គណិតវិទ្យា

## កម្រិតមូលដ្ឋាន

## ១២



ស្របតាមកម្មវិធីសិក្សាថ្មី

លឹម ផល្គុន និង សែន ពិសិដ្ឋ
បរិញ្ញាបត្រផ្នែក គណិតវិទ្យា

# កំណែលំហាត់

# គណិតវិទ្យា

## កម្រិតមូលដ្ឋាន



## ១២

ស្របតាមកម្មវិធីសិក្សាថ្មី

# គណៈកម្មការនិពន្ធ និង រៀបរៀង

លោក លឹម ផល្គុន

លោក សែន ពិសិដ្ឋ

# គណៈកម្មការត្រួតពិនិត្យបច្ចេកទេស

| | |
|---|---|
| លោក លឹម ឆុន | លោក អ៊ឹង សំណាង |
| លោកស្រី ទុយ វីណា | លោក ទិត្យ ម៉េង |
| លោក នន់ សុខណា | លោក ព្រឹម សុនិត្យ |

# គណៈកម្មការត្រួតពិនិត្យអក្ខរាវិរុទ្ធ

លោក លឹម មិត្តសិរ

| ការិយាកុំព្យូទ័រ | រចនាទំព័រ និង ក្រាប |
|---|---|
| លោក អ៊ឹង សំណាង | លោក ព្រំ ម៉ាឡា |
| កញ្ញា លី គុណ្ណាកា | |

# អារម្ភកថា

សួស្តីមិត្តអ្នកសិក្សា ជាទីមេត្រី !!

សៀវភៅ កំណែលំហាត់គណិតវិទ្យាថ្នាក់ទី12 កម្រិតមូលដ្ឋានដែលយើងខ្ញុំបាន រៀបរៀងនេះ រួមមានបួនជំពូកធំៗ ដែលបានដកស្រង់ចេញពីសៀវភៅគណិតវិទ្យា ថ្នាក់ទី១២កម្រិតមូលដ្ឋាន របស់ក្រសួងអប់រំ យុវជន និងកីឡា ។ ក្នុងជំពូកនីមួយៗយើងខ្ញុំបានសង្ខេបមេរៀន និង ដកស្រង់លំហាត់ក្នុងមេរៀននៃជំពូក នីមួយៗមកធ្វើដំណោះស្រាយយ៉ាងក្បោះក្បាយ ដែលអាចជាជំនួយស្មារតីដល់អ្នកសិក្សា ក្នុងគ្រប់មជ្ឈដ្ឋាន ។

ទោះជាយ៉ាងណាក៏ដោយ ការបកស្រាយនូវរាល់លំហាត់ក្នុងសៀវភៅ នេះវាមិនល្អហួសគេហួសឯង ទាំងស្រុងនោះទេ ។ កំហុសឆ្គងនានា ទាំងបច្ចេកទេស និង អក្ខរាវិរុទ្ធប្រាកដជាកើតមានដោយអចេតនា ពុំខានឡើយ អាស្រ័យហេតុនេះ យើងខ្ញុំរង់ចាំជានិច្ចនូវមតិរិះគន់បែបស្ថាបនាពីសំណាក់ អ្នកសិក្សាក្នុងគ្រប់មជ្ឈដ្ឋាន ដើម្បីកែតម្រូវសៀវភៅនេះឱ្យកាន់តែមានសុក្រិត្យភាព ថែមទៀត ។

ជាទីបញ្ចប់ យើងខ្ញុំអ្នករៀបរៀង សូមជូនពរដល់អ្នកសិក្សាទាំងអស់ ទទួលបានជោគជ័យក្នុងជីវិត និង មានសុខភាពល្អ ។

បាត់ដំបងថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១០

អ្នករៀបរៀង **លឹម ផល្គុន**

# មាតិការឿង

ទំព័រ


## ជំពូកទី១

មេរៀនទី១ លីមីតនៃអនុគមន៍ ០១

មេរៀនទី២ ភាពជាប់នៃអនុគមន៍ ៣៣

## ជំពូកទី២

មេរៀនទី១ ដេរីវេនៃអនុគមន៍ ៥៨

មេរៀនទី២ អនុវត្តន៍នៃអនុគមន៍ ៨០

## ជំពូកទី៣

មេរៀនទី១ អនុគមន៍ សនិទាន ១០៦

មេរៀនទី២ អនុគមន៍អិុស្ប៉ូណង់ស្យែល ១៣៥

មេរៀនទី៣ អនុគមន៍លោការីត ១៥០

## ជំពូកទី៤

មេរៀនទី១ ព្រីមីទីវ និង អាំងតេក្រាលមិនកំណត់ ១៥៩

មេរៀនទី២ អាំងតេក្រាលកំណត់ ១៨០

លំហាត់បន្ថែម ១៨៩

*មេរៀនសង្ខេប*

# លីមីតនៃអនុគមន៍

## ១_លីមីតនៃអនុគមន៍ត្រង់ចំនួនកំណត់

✍ ***និយមន័យ*** :

អនុគមន៍ $f$ មានលីមីតស្មើ $L$ កាលណា $x$ ខិតជិត $a$ បើគ្រប់ចំនួន $\varepsilon > 0$ មានចំនួន $\delta > 0$ ដែល $0 < |x - a| < \delta$ នាំឱ្យ $|f(x) - L| < \varepsilon$ ។

គេសរសេរ : $\lim\limits_{x \to a} f(x) = L$ ។

✍ ***និយមន័យ*** :

គេថាអនុគមន៍ $f$ ខិតទៅ $+\infty$ ឬ $-\infty$ កាលណា $x$ ខិតទៅជិត $a$ បើចំពោះគ្រប់ចំនួន $M > 0$ មាន $\delta > 0$ ដែល $0 < |x - a| < \delta$ នាំឱ្យ $f(x) > M$ ឬ $f(x) < -M$ ។

គេសរសេរ $\lim\limits_{x \to a} f(x) = +\infty$ ឬ $\lim\limits_{x \to a} f(x) = -\infty$ ។

## ២_លីមីតនៃអនុគមន៍ត្រង់អនន្ត

✍ គេថាអនុគមន៍ $f$ មានលីមីតស្មើ $L$ កាលណា $x$ ទៅជិត $+\infty$ ឬ $-\infty$ បើចំពោះគ្រប់ចំនួន $\varepsilon > 0$ គេអាចរក $N > 0$ ដែល $x > N$ ឬ $x < -N$ នាំឱ្យ $|f(x) - L| < \varepsilon$ ។

គេសរសេរ $\lim_{x\to+\infty} f(x) = L$ ឬ $\lim_{x\to-\infty} f(x) = L$ ។

✍ គេថាអនុគមន៍ $f$ មានលីមីត $+\infty$ កាលណា $x$ ទៅជិត $+\infty$ បើចំពោះគ្រប់ចំនួន $M > 0$ គេមាន $N > 0$ ដែល $x > N$ នាំឱ្យ $f(x) > M$ ។គេសរសេរ $\lim_{x\to+\infty} f(x) = +\infty$ ។

✍ គេថាអនុគមន៍ $f$ មានលីមីត $+\infty$ កាលណា $x$ ទៅជិត $-\infty$ បើចំពោះគ្រប់ចំនួន $M > 0$ គេមាន $N > 0$ ដែល $x < -N$ នាំឱ្យ $f(x) > M$ ។គេសរសេរ $\lim_{x\to-\infty} f(x) = +\infty$ ។

## ៣_ប្រមាណវិធីលើលីមីត

បើ $\lim_{x\to a} f(x) = L$ ; $\lim_{x\to a} g(x) = M$ និង $\lim_{x\to a} h(x) = N$ ដែល $L$ ; $M$ ; $N$ ជាចំនួនពិតនោះគេបាន :

1/ $\lim_{x\to a}\left[f(x) \pm g(x)\right] = L \pm M$

( $a$ ជាចំនួនកំណត់ ឬអនន្ត ) ។

$2/\ \lim_{x\to a}\left[f(x)+g(x)-h(x)\right]=L+M-N$

$3/\ \lim_{x\to a}\left[k\,f(x)\right]=k\ \lim_{x\to a}\left[f(x)\right]$

$4/\ \lim_{x\to a}\left[f(x).g(x).h(x)\right]=L.M.N$

$5/\ \lim_{x\to a}\left[\dfrac{f(x)}{g(x)}\right]=\dfrac{L}{M}\ ;\ M\neq 0$

$6/\ \lim_{x\to a}\left[f(x)\right]^n=L^n$ ដែល $n$ ជាចំនួនគត់ធម្មជាតិមិនសូន្យ ។

## ៤_លីមីតនៃអនុគមន៍អសនិទាន

$1/\lim_{x\to a}\left(\sqrt[n]{x}\right)=\sqrt[n]{a}$ ចំពោះ $a\geq 0$ និង $n\in IN$

$2/\lim_{x\to a}\left(\sqrt[n]{x}\right)=\sqrt[n]{a}$ ចំពោះ $a<0$ និង $n$ ជាចំនួនគត់សេស

$3/\lim_{x\to a}\left[\sqrt[n]{f(x)}\right]=\sqrt[n]{\lim_{x\to a}\left[f(x)\right]}=\sqrt[n]{L}$

បើ $L\geq 0$ និង $n$ ជាចំនួនគត់គូ ឬ $L<0$ និង $n$ ជាចំនួនគត់សេស ។

## ៥_លីមីតនៃអនុគមន៍បណ្តាក់

បើ $f$ និង $g$ ជាអនុគមន៍ដែលមាន $\lim_{x\to a}[g(x)]=L$

និង $\lim_{x\to L}f(x)=f(L)$ នោះ $\lim_{x\to a}f\left[g(x)\right]=f(L)$ ។

## ៦_លីមីតតាមការប្រៀបធៀប

✍ បើគេមានអនុគមន៍ $f\ ;g$ និងចំនួនពិត $A$ ដែល $\lim_{x\to+\infty}g(x)=+\infty$

និង $f(x) \geq g(x)$ ចំពោះគ្រប់ $x \geq A$ នោះ $\lim_{x\to+\infty} f(x) = -\infty$ ។

✍ បើគេមានអនុគមន៍ $f\ ; g$ និងចំនួនពិត $A$ ដែល $\lim_{x\to+\infty} g(x) = +\infty$

និង $f(x) \leq g(x)$ ចំពោះគ្រប់ $x \geq A$ នោះ $\lim_{x\to+\infty} f(x) = -\infty$ ។

✍ បើគេមានអនុគមន៍ $f\ ; g; h$ និងចំនួនពិត $A$ ដែល

$\lim_{x\to+\infty} g(x) = \lim_{x\to+\infty} h(x) = \lambda$ និង $g(x) \leq f(x) \leq h(x)$ ចំពោះគ្រប់

$x \geq A$ នោះ $\lim_{x\to+\infty} f(x) = \lambda$ ។

✍ បើគេមានអនុគមន៍ $f\ ; g$ និងចំនួនពិត $A$ ដែល $\lim_{x\to+\infty} f(x) = \lambda$

$\lim_{x\to+\infty} g(x) = \lambda'$ និង $f(x) \leq g(x)$ ចំពោះគ្រប់ $x \geq A$

នោះ $\lambda \leq \lambda'$ ។

## ៧_លីមីតរាងមិនកំនត់

### ✍ លីមីតដែលមានរាងមិនកំនត់ $\frac{0}{0}$

***វិធាន*** ដើម្បីគណនាលីមីតដែលមានរាងមិនកំនត់ $\frac{0}{0}$ គេត្រូវបំបែកភាគយក និង ភាគបែងជាផលគុណកត្តា ហើយសម្រួលកត្តារួម រួចគណនាលីមីតនៃកន្សោមថ្មី ។

## ✍ លីមីតដែលមានរាងមិនកំនត់ $\frac{\infty}{\infty}$

***វិធាន*** ដើម្បីគណនាលីមីតដែលមានរាងមិនកំនត់ $\frac{\infty}{\infty}$ គេត្រូវដាក់តួដែលមានដឺក្រេធំជាងគេនៅភាគយក និង ភាគបែងជាផលគុណកត្តា ហើយសម្រួលកត្តារួម រួចគណនាលីមីតនៃកន្សោមថ្មី ។

## ✍ លីមីតដែលមានរាងមិនកំនត់ $+\infty-\infty$

***វិធាន*** ដើម្បីគណនាលីមីតដែលមានរាងមិនកំនត់ $+\infty-\infty$ គេត្រូវដាក់តួដែលមានដឺក្រេធំជាងគេនៅភាគយក និង ភាគបែងជាផលគុណនៃកត្តា ហើយសម្រួលកត្តារួម រួចគណនាលីមីតនៃកន្សោមថ្មី ។

## ៨_លីមីតនៃអនុគមន៍ត្រីកោណមាត្រ

-បើ **a** ជាចំនួនពិតស្ថិតនៅក្នុងដែនកំនត់នៃអនុគមន៍ត្រីកោណមាត្រដែលឱ្យនោះគេបាន $\lim\limits_{x\to a}\sin x=\sin a$ ; $\lim\limits_{x\to a}\cos x=\cos a$

និង $\lim\limits_{x\to a}\tan x=\tan a$ ។

-វិធាន បើ **x** ជារង្វាស់មុំ ឬធ្នូគិតជារ៉ាដ្យង់នោះគេបាន

$$\lim_{x\to 0}\frac{\sin x}{x}=1 \quad \text{និង} \quad \lim_{x\to 0}\frac{1-\cos x}{x}=0 \quad ។$$

## ៩_លីមីតនៃអនុគមន៍អ៊ិចស្ប៉ូណង់ស្យែល

$1/\ \lim_{x\to+\infty} e^x = +\infty$

$2/\ \lim_{x\to-\infty} e^x = 0$

$3/\ \lim_{x\to+\infty} \frac{e^x}{x} = +\infty$

$4/\ \lim_{x\to+\infty} \frac{e^x}{x^n} = +\infty \quad (n > 0)$

$5/\ \lim_{x\to+\infty} \frac{x^n}{e^x} = 0 \quad (n > 0)$

## ១០_លីមីតនៃអនុគមន៍លោការីតនេពែ

$1/\ \lim_{x\to+\infty} \ln x = +\infty$

$2/\ \lim_{x\to0^+} \ln x = -\infty$

$3/\ \lim_{x\to+\infty} \frac{\ln x}{x} = 0$

$4/\ \lim_{x\to0} x\ln x = 0$

$5/\ \lim_{x\to+\infty} \frac{\ln x}{x^n} = 0 \quad (n > 0)$

$6/\ \lim_{x\to0^+} x^n \ln x = 0$

## លំហាត់ និង ដំណោះស្រាយ

1-ស្រាយបញ្ជាក់ថា លីមីតខាងក្រោមនេះពិតដោយប្រើនិយមន័យ

ក. $\lim_{x\to 3}(5x-2)=13$

ខ. $\lim_{x\to 2^-}\sqrt{(x-2)(x-3)}=0$

គ. $\lim_{x\to x_0}(ax+b)=ax_0+b$

**ដំណោះស្រាយ**

ក. $\lim_{x\to 3}(5x-2)=13$

តាង $f(x)=5x-2$

គេមាន $f(x)-13=(5x-2)-13=5x-15=5(x-3)$

$|f(x)-13|=5|x-3|<\varepsilon$ នាំឱ្យ $|x-3|<\frac{\varepsilon}{5}$

បើគេតាង $\delta=\frac{\varepsilon}{5}$ នោះគ្រប់ $\varepsilon>0$ មាន $\delta=\frac{\varepsilon}{5}>0$ ដែល

$|x-3|<\delta$ នាំឱ្យ $|f(x)-13|<\varepsilon$ ។

គេថា $f(x)$ មានលីមីតស្មើ $13$ កាលណា $x$ ខិតជិត $3$ ។

ដូចនេះ $\lim_{x\to 3}(5x-2)=13$ ។

ខ. $\lim\limits_{x\to 2^-}\sqrt{(x-2)(x-3)}=0$

តាង $f(x)=\sqrt{(x-2)(x-3)}$

ដោយ $x\to 2^-$ នោះយើងសន្មតថា $0<x<2$ ។

គេបាន $|x-2|=-(x-2)=2-x>0$

និង $|x-3|=-(x-3)=3-x<3$ ។

ចំពោះគ្រប់ $\varepsilon>0$ យក $\delta=\dfrac{\varepsilon^2}{3}$ ដែល $0<|x-2|<\delta$

នាំឱ្យ $|f(x)|=|\sqrt{(x-2)(x-3)}|=|\sqrt{(2-x)(3-x)}|$

$$|f(x)|<\sqrt{\frac{\varepsilon^2}{3}\times 3}=\varepsilon$$ ។

ដូចនេះចំពោះគ្រប់ $\varepsilon>0$ មាន $\delta>0$ ដែល $0<|x-2|<\delta$

នាំឱ្យ $|\sqrt{(x-2)(x-3)}|<\varepsilon$ ។

ដូចនេះ $\lim\limits_{x\to 2^-}\sqrt{(x-2)(x-3)}=0$ ។

គ. $\lim\limits_{x\to x_0}(ax+b)=ax_0+b$

តាង $f(x)=ax+b$

-ចំពោះ $a=0$ នោះគ្រប់ $x$ គេមាន $ax+b=b$

ក្នុងករណីនេះ $\lim\limits_{x\to x_0}(ax+b)=ax_0+b=b$ ។

-សន្មតថា $\mathbf{a \neq 0}$ ។

គេមាន $\mathbf{f(x)-(ax_0+b)=ax+b-ax_0-b=a(x-x_0)}$

$\mathbf{|f(x)-(ax_0+b)|=|a|.|x-x_0|<\varepsilon}$

ឬ $\mathbf{|x-x_0|<\dfrac{\varepsilon}{|a|}\,,\ a\neq 0}$ ។

បើគេតាង $\delta=\dfrac{\varepsilon}{|a|}$ នោះគ្រប់ $\varepsilon>0$ មាន $\delta=\dfrac{\varepsilon}{|a|}>0$

ដែល $|x-x_0|<\delta$ នាំឱ្យ $\mathbf{|f(x)-(ax_0+b)|<\varepsilon}$

ដូចនេះ $\mathbf{\lim\limits_{x\to x_0}(ax+b)=ax_0+b}$ ។

**2-**បើ $\mathbf{\lim\limits_{x\to a}f(x)=M}$ និង $\mathbf{\lim\limits_{x\to a}g(x)=L}$ ដែល $\mathbf{M}$ និង $\mathbf{L}$ ជាចំនួនថេរនោះ ចូរបង្ហាញថា

ក. $\mathbf{\lim\limits_{x\to a}[k.f(x)]=k.L}$

ខ. $\mathbf{\lim\limits_{x\to a}[f(x)+g(x)]=L+M}$

**ដំណោះស្រាយ**

ក. $\mathbf{\lim\limits_{x\to a}[k.f(x)]=k.L}$

-បើ $\mathbf{k=0}$ នោះ $\mathbf{kf(x)=kL=0}$ គ្រប់ $\mathbf{x}$ ។

-សន្មតថា $\mathbf{k \neq 0}$

គេមាន $\lim\limits_{x\to a} f(x) = L$ ចំពោះគ្រប់ $\varepsilon > 0$ មាន $\delta > 0$

ដែល $|f(x) - L| < \dfrac{\varepsilon}{|k|}$ ចំពោះគ្រប់ $x$ ដែល $|x - a| < \delta$ ។

ដូចនេះគ្រប់ $x$ ដែល $|x - a| < \delta$ នោះយើងបាន

$$|kf(x) - kl| = |k||f(x) - l| < |k|.\frac{\varepsilon}{|k|} = \varepsilon$$ ។

ដោយគ្រប់ $\varepsilon > 0$ មាន $\delta > 0$ ដែល $|kf(x) - kl| < \varepsilon$ គ្រប់ $x$

នោះ $|x - a| < \delta$ ។

ដូចនេះ $\lim\limits_{x\to a}[kf(x)] = kL$ ។

ខ. $\lim\limits_{x\to a}[f(x) + g(x)] = L + M$

ដោយ $\lim\limits_{x\to a} f(x) = L$ និង $\lim\limits_{x\to a} g(x) = M$ នោះចំពោះគ្រប់ $\varepsilon > 0$

មាន $\delta_1 > 0$ និង $\delta_2 > 0$ ដែល

$|f(x) - L| < \dfrac{\varepsilon}{2}$ ចំពោះ $|x - a| < \delta_1$

$|g(x) - M| < \dfrac{\varepsilon}{2}$ ចំពោះ $|x - a| < \delta_2$

គេមាន $|f(x) + g(x) - L - M| = |(f(x) - L) + (g(x) - M)|$

$$\leq |f(x) - L| + |g(x) - M|$$

យក $\delta < \delta_1$ និង $\delta < \delta_2$ នោះគ្រប់ $x$ ដែល $|x-a| < \delta$

គេបាន $|f(x)+g(x)-L-M| \le |f(x)-L| + |g(x)-M| < \frac{\varepsilon}{2} + \frac{\varepsilon}{2} = \varepsilon$ ។

ដោយគ្រប់ $\varepsilon > 0$ មាន $\delta > 0$ ដែល $|x-a| < \delta$ នាំឱ្យ

$|(f(x)+g(x)) - (L+M)| < \varepsilon$ ។

ដូចនេះ $\lim_{x\to a}[f(x)+g(x)] = L+M$ ។

3-គណនាលីមីតខាងក្រោម

ក. $\lim_{x\to 0}\frac{\sqrt{x^2-x+1}-1}{\sqrt{1+x}-\sqrt{1-x}}$

ខ. $\lim_{x\to +\infty}\frac{(x-1)(2x+3)(2-x)}{(x^2+1)(2x+1)}$

គ. $\lim_{x\to 0^-}\frac{x^2+x}{|x|}$

ឃ. $\lim_{x\to -\infty}(\sqrt{x^2+8x-1}-\sqrt{x^2-3})$

## ដំណោះស្រាយ

គណនាលីមីតខាងក្រោម

ក. $\lim_{x\to 0}\frac{\sqrt{x^2-x+1}-1}{\sqrt{1+x}-\sqrt{1-x}}$

$$(\sqrt{A}-\sqrt{B})(\sqrt{A}+\sqrt{B})=A-B$$

$$=\lim_{x\to 0}\frac{(x^2-x+1-1)(\sqrt{1+x}+\sqrt{1-x})}{(1+x-1+x)(\sqrt{x^2-x+1}+1)}$$

$$=\lim_{x\to 0}\frac{x(x-1)(\sqrt{1+x}+\sqrt{1-x})}{2x(\sqrt{x^2-x+1}+1)}$$

$$=\lim_{x\to 0}\frac{(x+1)(\sqrt{1+x}+\sqrt{1-x})}{2(\sqrt{x^2-x+1}+1)}=\frac{1\times 2}{2\times 2}=\frac{1}{2}$$

ដូចនេះ $\lim_{x\to 0}\frac{\sqrt{x^2-x+1}-1}{\sqrt{1+x}-\sqrt{1-x}}=\frac{1}{2}$ ។

ខ. $\lim_{x\to +\infty}\frac{(x-1)(2x+3)(2-x)}{(x^2+1)(2x+1)}$

$$=\lim_{x\to +\infty}\frac{x^3(1-\frac{1}{x})(2+\frac{3}{x})(\frac{2}{x}-1)}{x^3(1+\frac{1}{x^2})(2+\frac{1}{x})}$$

$$=\lim_{x\to +\infty}\frac{(1-\frac{1}{x})(2+\frac{3}{x})(\frac{2}{x}-1)}{(1+\frac{1}{x^2})(2+\frac{1}{x})}=\frac{-2}{2}=-1$$

ដូចនេះ $\lim_{x\to +\infty}\frac{(x-1)(2x+3)(2-x)}{(x^2+1)(2x+1)}=-1$ ។

គ. $\lim\limits_{x\to 0^-}\dfrac{x^2+x}{|x|}$

$=\lim\limits_{x\to 0^-}\dfrac{x(x+1)}{-x}$

$=-\lim\limits_{x\to 0^-}(x+1)=-1$

ដូចនេះ $\lim\limits_{x\to 0^-}\dfrac{x^2+x}{|x|}=-1$ ។

ឃ. $\lim\limits_{x\to -\infty}(\sqrt{x^2+8x-1}-\sqrt{x^2-3})$

$=\lim\limits_{x\to -\infty}\dfrac{x^2+8x-1-x^2+3}{\sqrt{x^2+8x-1}+\sqrt{x^2-3}}$

$=\lim\limits_{x\to -\infty}\dfrac{8x+2}{|x|\sqrt{1+\frac{8}{x}-\frac{1}{x^2}}+|x|\sqrt{1-\frac{3}{x^2}}}$

$=\lim\limits_{x\to -\infty}\dfrac{x(8+\frac{2}{x})}{-x(\sqrt{1+\frac{8}{x}-\frac{1}{x^2}}+\sqrt{1-\frac{3}{x^2}})}$

$=-\lim\limits_{x\to -\infty}\dfrac{8+\frac{2}{x}}{\sqrt{1+\frac{8}{x}-\frac{1}{x^2}}+\sqrt{1-\frac{3}{x^2}}}=-\dfrac{8}{1+1}=-4$

ដូចនេះ $\lim\limits_{x\to -\infty}(\sqrt{x^2+8x-1}-\sqrt{x^2-3})=-4$ ។

4-កំនត់ចំនួនថេរ **a** ដើម្បីឱ្យលីមីតខាងក្រោមជាលីមីតនៃចំនួនថេរ ហើយ កំនត់លីមីតនេះផង ។

ក. $\lim\limits_{x\to 1}\dfrac{\sqrt{x+3}-a}{x-1}$  ខ. $\lim\limits_{x\to 0}\dfrac{\sqrt{1+3x}+a}{x}$

គ. $\lim\limits_{x\to 2}\dfrac{\sqrt{x+a}-1}{x-2}$  ឃ. $\lim\limits_{x\to -1}\dfrac{\sqrt{x^2+ax}-1}{x^2-1}$

## ដំណោះស្រាយ

កំនត់ចំនួនថេរ **a** ដើម្បីឱ្យលីមីតខាងក្រោមជាលីមីតនៃចំនួនថេរ ហើយ កំនត់លីមីតនេះផង

ក. $\lim\limits_{x\to 1}\dfrac{\sqrt{x+3}-a}{x-1}$

ដើម្បីឱ្យលីមីតនេះជាចំនួនថេរលុះត្រាតែ $x=1$ ជាឫសសមីការ $\sqrt{x+3}-a=0$ គេបាន $\sqrt{1+3}-a=0 \Rightarrow a=2$ ។

ចំពោះ $a=2$ គេបាន

$$\lim_{x\to 1}\frac{\sqrt{x+3}-2}{x-1}=\lim_{x\to 1}\frac{x+3-4}{(x-1)(\sqrt{x+3}+2)}$$

$$=\lim_{x\to 1}\frac{1}{\sqrt{x+3}+2}=\frac{1}{4}$$

ខ. $\lim\limits_{x\to 0}\dfrac{\sqrt{1+3x}+a}{x}$

ដើម្បីឱ្យលីមីតនេះជាចំនួនថេរលុះត្រាតែ $x=0$ ជាឬសសមីការ

$\sqrt{1+3x}-a=0$ គេបាន $\sqrt{1+3(0)}+a=0 \Rightarrow a=-1$ ។

ចំពោះ $a=-1$ គេបាន

$$\lim_{x\to 0}\frac{\sqrt{1+3x}-1}{x}=\lim_{x\to 0}\frac{1+3x-1}{x(\sqrt{1+3x}+1)}$$

$$=\lim_{x\to 0}\frac{3}{\sqrt{1+3x}+1}=\frac{3}{2}$$

គ. $\lim\limits_{x\to 2}\dfrac{\sqrt{x+a}-1}{x-2}$

ដើម្បីឱ្យលីមីតនេះជាចំនួនថេរលុះត្រាតែ $x=2$ ជាឬសសមីការ

$\sqrt{x+a}-1=0$ គេបាន $\sqrt{2+a}-1=0 \Rightarrow a=-1$ ។

ចំពោះ $a=-1$ គេបាន

$$\lim_{x\to 2}\frac{\sqrt{x-1}-1}{x-2}=\lim_{x\to 2}\frac{x-1-1}{(x-2)(\sqrt{x-1}+1)}$$

$$=\lim_{x\to 2}\frac{1}{\sqrt{x-1}+1}=\frac{1}{2}$$

ឃ. $\lim\limits_{x\to -1}\dfrac{\sqrt{x^2+ax}-1}{x^2-1}$

ដើម្បីឱ្យលីមីតនេះជាចំនួនថេរលុះត្រាតែ $x=-1$ ជាឫសសមីការ

$\sqrt{x^2+ax}-1=0$ គេបាន $\sqrt{1-a}-1=0\Rightarrow a=0$ ។

ចំពោះ $a=0$ គេបាន

$$\lim_{x\to -1}\frac{\sqrt{x^2}-1}{x^2-1}=\lim_{x\to -1}\frac{|x|-1}{(|x|-1)(|x|+1)}$$

$$=\lim_{x\to -1}\frac{1}{|x|+1}=\frac{1}{2}$$

5-គណនាលីមីតខាងក្រោម

ក. $\lim\limits_{x\to 0}\dfrac{x\sin 3x}{\sin^2 5x}$

ខ. $\lim\limits_{x\to 0}\dfrac{(1-\cos x)^2}{\tan^3 x-\sin^3 x}$

គ. $\lim\limits_{x\to 0}\dfrac{\sqrt{2}-\sqrt{1+\cos x}}{\sin^2 x}$

ឃ. $\lim\limits_{x\to \frac{\pi}{2}}\dfrac{1-\sin x}{\left(\dfrac{\pi}{2}-x\right)^2}$

ង. $\lim\limits_{x\to \pm\infty} x\sin\dfrac{1}{x}$

ច. $\lim\limits_{x\to +\infty} x^2\left(1-\cos\dfrac{1}{x}\right)$

## ដំណោះស្រាយ

គណនាលីមីតខាងក្រោម

ក. $\lim\limits_{x\to 0}\dfrac{x\sin 3x}{\sin^2 5x}$

$$=\lim_{x\to 0}\frac{3.\dfrac{\sin 3x}{3x}}{25.\left(\dfrac{\sin 5x}{x}\right)^2}=\frac{3.1}{25.1^2}=\frac{3}{25}$$

ដូចនេះ $\lim\limits_{x\to 0}\dfrac{x\sin 3x}{\sin^2 5x}=\dfrac{3}{25}$ ។

ខ. $\lim\limits_{x\to 0}\dfrac{(1-\cos x)^2}{\tan^3 x-\sin^3 x}$

$$=\lim_{x\to 0}\frac{(1-\cos x)^2}{\tan^3 x-\cos^3 x\tan^3 x}$$

$$=\lim_{x\to 0}\frac{(1-\cos x)^2}{(1-\cos^3 x)\tan^3 x}=\lim_{x\to 0}\frac{1-\cos x}{(1+\cos x+\cos^2 x)\tan^3 x}$$

$$=\lim_{x\to 0}\frac{2\sin^2\dfrac{x}{2}}{(1+\cos x+\cos^2 x)\tan^3 x}$$

$$=\frac{1}{2}\lim_{x\to 0}\frac{\sin^2\dfrac{x}{2}}{(\dfrac{x}{2})^2}\times\frac{x^3}{\tan^2 x}\times\frac{1}{x(1+\cos x+\cos^2 x)}=\pm\infty$$

គ. $\lim_{x\to 0}\dfrac{\sqrt{2}-\sqrt{1+\cos x}}{\sin^2 x}$

$$=\lim_{x\to 0}\frac{2-1-\cos x}{\sin^2 x(\sqrt{2}+\sqrt{1+\cos x})}$$

$$=\lim_{x\to 0}\frac{1-\cos x}{\sin^2 x(\sqrt{2}+\sqrt{1+\cos x})}$$

$$=\lim_{x\to 0}\frac{2\sin^2\frac{x}{2}}{4\sin^2\frac{x}{2}\cos^2\frac{x}{2}(\sqrt{2}+\sqrt{1+\cos x})}$$

$$=\lim_{x\to 0}\frac{1}{2\cos^2\frac{x}{2}(\sqrt{2}+\sqrt{1+\cos x})}=\frac{1}{4\sqrt{2}}=\frac{\sqrt{2}}{8}$$

ដូចនេះ $\lim_{x\to 0}\dfrac{\sqrt{2}-\sqrt{1+\cos x}}{\sin^2 x}=\dfrac{\sqrt{2}}{8}$ ។

ឃ. $\lim_{x\to\frac{\pi}{2}}\dfrac{1-\sin x}{\left(\frac{\pi}{2}-x\right)^2}$

តាង $t=\dfrac{\pi}{2}-x\Rightarrow x=\dfrac{\pi}{2}-t$

កាលណា $x\to\dfrac{\pi}{2}$ នោះ $t\to 0$

គេបាន $\lim\limits_{x\to\frac{\pi}{2}}\frac{1-\sin x}{\left(\frac{\pi}{2}-x\right)^2}=\lim\limits_{t\to0}\frac{1-\sin(\frac{\pi}{2}-t)}{t^2}$

$$=\lim_{t\to0}\frac{1-\cos t}{t^2}$$

$$=\lim_{t\to0}\frac{2\sin^2\frac{t}{2}}{t^2}$$

$$=\frac{1}{2}\lim_{t\to0}\frac{\sin^2\frac{t}{2}}{(\frac{t}{2})^2}=\frac{1}{2}$$

ដូចនេះ $\lim\limits_{x\to\frac{\pi}{2}}\frac{1-\sin x}{\left(\frac{\pi}{2}-x\right)^2}=\frac{1}{2}$ ។

ង. $\lim\limits_{x\to\pm\infty}x\sin\frac{1}{x}$

តាង $t=\frac{1}{x}$ កាលណា $x\to\pm\infty$ នោះ $t\to0$

$\lim\limits_{x\to\pm\infty}x\sin\frac{1}{x}=\lim\limits_{t\to0}\frac{\sin t}{t}=1$

ដូចនេះ $\lim\limits_{x\to\pm\infty}x\sin\frac{1}{x}=1$ ។

ច. $\lim\limits_{x\to+\infty} x^2\left(1-\cos\frac{1}{x}\right)$

តាង $t=\frac{1}{x}$ កាលណា $x\to+\infty$ នោះ $t\to 0$

គេបាន $\lim\limits_{x\to+\infty} x^2\left(1-\cos\frac{1}{x}\right)=\lim\limits_{t\to0}\frac{1-\cos t}{t^2}$

$$=\lim_{t\to0}\frac{2\sin^2\frac{t}{2}}{t^2}$$

$$=\frac{1}{2}\lim_{t\to0}\frac{\sin^2\frac{t}{2}}{(\frac{t}{2})^2}=\frac{1}{2}$$

ដូចនេះ $\lim\limits_{x\to+\infty} x^2\left(1-\cos\frac{1}{x}\right)=\frac{1}{2}$ ។

6-គណនាលីមីតខាងក្រោម

ក. $\lim\limits_{x\to\pm\infty}(x^2+xe^x)$

ខ. $\lim\limits_{x\to+\infty}(1-x)e^x$

គ. $\lim\limits_{x\to+\infty}(x+2)e^{-x}$

ឃ. $\lim\limits_{x\to+\infty}\dfrac{e^x-x}{2e^x+1}$

ង. $\lim\limits_{x\to0}\ln\left(\dfrac{x}{x+1}\right)$

ច. $\lim\limits_{x\to\pm\infty}x\ln(x^2+1)$

ឆ. $\lim\limits_{x\to-4}x\ln\left(4-3x-x^2\right)$

ជ. $\lim\limits_{x\to+\infty}\{x[\ln(x+1)-\ln x]\}$

## ដំណោះស្រាយ

គណនាលីមីតខាងក្រោម

ក. $\lim\limits_{x\to\pm\infty}(x^2+xe^x)$

គេមាន $\lim\limits_{x\to+\infty}(x^2+xe^x)=\lim\limits_{x\to+\infty}(x^2)+\lim\limits_{x\to+\infty}(xe^x)=+\infty$

( ព្រោះ $\lim\limits_{x\to+\infty}x^2=+\infty$ ; $\lim\limits_{x\to+\infty}xe^x=+\infty$ )

ហើយ $\lim\limits_{x\to-\infty}(x^2+xe^x)=\lim\limits_{x\to-\infty}(x^2)+\lim\limits_{x\to-\infty}(xe^x)=+\infty$

( ព្រោះ $\lim\limits_{x\to-\infty}x^2=+\infty$ ; $\lim\limits_{x\to-\infty}xe^x=0$ )

ដូចនេះ $\lim\limits_{x\to\pm\infty}(x^2+xe^x)=+\infty$ ។

ខ. $\lim\limits_{x\to+\infty}(1-x)e^{x}$

ដោយ $\lim\limits_{x\to+\infty}(1-x)=-\infty$ និង $\lim\limits_{x\to+\infty}e^{x}=+\infty$

ដូចនេះ $\lim\limits_{x\to+\infty}(1-x)e^{x}=-\infty$

គ. $\lim\limits_{x\to+\infty}(x+2)e^{-x}$

$=\lim\limits_{x\to+\infty}xe^{-x}+2\lim\limits_{x\to+\infty}e^{-x}=0$ ( ព្រោះ $\lim\limits_{x\to+\infty}e^{-x}=0$ )

ដូចនេះ $\lim\limits_{x\to+\infty}(x+2)e^{-x}=0$ ។

ឃ. $\lim\limits_{x\to+\infty}\dfrac{e^{x}-x}{2e^{x}+1}$

$$=\lim_{x\to+\infty}\frac{e^{x}(1-\frac{x}{e^{x}})}{e^{x}(2+\frac{1}{e^{x}})}=\lim_{x\to+\infty}\frac{1-xe^{-x}}{2+e^{-x}}=\frac{1}{2}$$

( ព្រោះ $\lim\limits_{x\to+\infty}xe^{-x}=0$ , $\lim\limits_{x\to+\infty}e^{-x}=0$ )

ង. $\lim\limits_{x\to0}\ln\left(\dfrac{x}{x+1}\right)$

$=\lim\limits_{x\to0}\left[\ln x-\ln(x+1)\right]$

$=\lim\limits_{x\to0}\ln x-\lim\limits_{x\to0}\ln(x+1)=-\infty$

ដូចនេះ $\lim\limits_{x\to0}\ln\left(\dfrac{x}{x+1}\right)=-\infty$ ។

ច. $\lim_{x\to\pm\infty} x\ln(x^2+1)$

$= \lim_{x\to\pm\infty}(x)\times\lim_{x\to\pm\infty}\ln(x^2+1) = \pm\infty$

ព្រោះ $\lim_{x\to\pm\infty}(x) = \pm\infty$ និង $\lim_{x\to\pm\infty}\ln(x^2+1) = +\infty$

ដូចនេះ $\lim_{x\to\pm\infty} x\ln(x^2+1) = \pm\infty$ ។

ឆ. $\lim_{x\to-4} x\ln\left(4-3x-x^2\right)$

តាង $x = t-4$ កាលណា $x\to -4$ នោះ $t\to 0$

$= \lim_{t\to 0}(t-4)\ln\left[4-3(t-4)-(t-4)^2\right]$

$= \lim_{t\to 0}(t-4)\ln(5t-t^2)$

$= \lim_{t\to 0}(t-4)[\ \ln t+\ln(5-t)] = +\infty$

( ព្រោះ $\lim_{t\to 0}(t-4) = -4$ ; $\lim_{t\to 0}[\ln t+\ln(5-t)] = -\infty$ )

ដូចនេះ $\lim_{x\to-4} x\ln\left(4-3x-x^2\right) = +\infty$ ។

ជ. $\lim_{x\to+\infty}\{x[\ln(x+1)-\ln x]\}$

$= \lim_{x\to+\infty} x\ln\left(\frac{x+1}{x}\right) = \lim_{x\to+\infty}\ln\left(1+\frac{1}{x}\right)^x = \ln e = 1$

( ព្រោះ $\lim_{x\to+\infty}\left(1+\frac{1}{x}\right)^x = e$ )

ដូចនេះ $\lim_{x\to+\infty}\{x[\ln(x+1)-\ln x]\} = 1$ ។

7-គណនាលីមីតខាងក្រោម

ក. $\lim_{x\to 0}\frac{\tan x-\sin x}{x^3}$ ខ. $\lim_{x\to 0}\frac{1+\sin x-\cos x}{1-\sin x-\cos x}$

គ. $\lim_{x\to 0}\frac{1-\cos x\sqrt{\cos 2x}}{x^2}$ ឃ. $\lim_{x\to 0}\frac{1-\cos x\cos 2x}{x^2}$

## ដំណោះស្រាយ

គណនាលីមីតខាងក្រោម

ក. $\lim_{x\to 0}\frac{\tan x-\sin x}{x^3}$

$$=\lim_{x\to 0}\frac{\tan x-\tan x\cos x}{x^3}$$

$$=\lim_{x\to 0}\frac{\tan x(1-\cos x)}{x^3}=\lim_{x\to 0}\frac{2\tan x\sin^2\frac{x}{2}}{x^3}$$

$$=\frac{1}{2}\lim_{x\to 0}\frac{\sin^2\frac{x}{2}}{\left(\frac{x}{2}\right)^2}\times\lim_{x\to 0}\frac{\tan x}{x}=\frac{1}{2}$$

ដូចនេះ $\lim_{x\to 0}\frac{\tan x-\sin x}{x^3}=\frac{1}{2}$ ។

ខ. $\lim\limits_{x\to 0}\dfrac{1+\sin x-\cos x}{1-\sin x-\cos x}$

$$=\lim_{x\to 0}\frac{\dfrac{1-\cos x}{x}+\dfrac{\sin x}{x}}{\dfrac{1-\cos x}{x}-\dfrac{\sin x}{x}}=\frac{0+1}{0-1}=-1$$

( ព្រោះ $\lim\limits_{x\to 0}\dfrac{\sin x}{x}=1$ ; $\lim\limits_{x\to 0}\dfrac{1-\cos x}{x}=0$ )

គ. $\lim\limits_{x\to 0}\dfrac{1-\cos x\sqrt{\cos 2x}}{x^2}$

$$=\lim_{x\to 0}\frac{(1-\cos x)+\cos x(1-\sqrt{\cos 2x})}{x^2}$$

$$=\lim_{x\to 0}\frac{1-\cos x}{x^2}+\lim_{x\to 0}\frac{\cos x(1-\cos 2x)}{x^2(1+\sqrt{\cos 2x})}$$

$$=\lim_{x\to 0}\frac{2\sin^2\dfrac{x}{2}}{x^2}+\lim_{x\to 0}\frac{2\cos x\sin^2 x}{x^2(1+\sqrt{\cos 2x})}$$

$$=\frac{1}{2}\lim_{x\to 0}\frac{\sin^2\dfrac{x}{2}}{\left(\dfrac{x}{2}\right)^2}+\lim_{x\to 0}\frac{\sin^2 x}{x^2}\times\frac{2\cos x}{1+\sqrt{\cos 2x}}=\frac{1}{2}+1=\frac{3}{2}$$

ដូចនេះ $\lim\limits_{x\to 0}\dfrac{1-\cos x\sqrt{\cos 2x}}{x^2}=\dfrac{3}{2}$ ។

ឃ. $\lim\limits_{x\to 0}\dfrac{1-\cos x\cos 2x}{x^2}$

$$=\lim_{x\to 0}\frac{(1-\cos x)+\cos x(1-\cos 2x)}{x^2}$$

$$=\lim_{x\to 0}\frac{1-\cos x}{x^2}+\lim_{x\to 0}\frac{\cos x(1-\cos 2x)}{x^2}$$

$$=\lim_{x\to 0}\frac{2\sin^2\frac{x}{2}}{x^2}+\lim_{x\to 0}\frac{2\cos x\sin^2 x}{x^2}$$

$$=\frac{1}{2}\lim_{x\to 0}\frac{\sin^2\frac{x}{2}}{\left(\frac{x}{2}\right)^2}+2\lim_{x\to 0}\left[(\cos x)\times\left(\frac{\sin x}{x}\right)^2\right]$$

$$=\frac{1}{2}+2=\frac{5}{2}$$

ដូចនេះ $\lim\limits_{x\to 0}\dfrac{1-\cos x\cos 2x}{x^2}=\dfrac{5}{2}$ ។

៨-គណនាលីមីតខាងក្រោម

ក. $\lim\limits_{x\to\frac{\pi}{6}}\frac{2\sin^2x-3\sin x+1}{4\sin^2x-1}$ ខ. $\lim\limits_{x\to0}\frac{1+x\sin x-\cos x}{\sin^2x}$

គ. $\lim\limits_{x\to a}\frac{x(a-b)}{\sin ax-\sin bx}$ $(a\neq0\ ,\ b\neq0\ ,\ a\neq b)$

ឃ. $\lim\limits_{x\to0}\frac{\sin^2x}{\sqrt{1+x\sin x-\cos x}}$

ង. $\lim\limits_{x\to+\infty}(\sqrt{x^2+3x}-\sqrt{x^2+1}-1)$

ច. $\lim\limits_{x\to0}\frac{\sin 3x}{\sqrt{x+2}-\sqrt{2}}$

## ដំណោះស្រាយ

គណនាលីមីតខាងក្រោម

ក. $\lim\limits_{x\to\frac{\pi}{6}}\frac{2\sin^2x-3\sin x+1}{4\sin^2x-1}$

$$=\lim_{x\to\frac{\pi}{6}}\frac{(\sin x-1)(2\sin x-1)}{(2\sin x-1)(2\sin x+1)}$$

$$=\lim_{x\to\frac{\pi}{6}}\frac{\sin x-1}{2\sin x+1}=\frac{\frac{1}{2}-1}{1+1}=-\frac{1}{4}$$

ដូចនេះ $\lim\limits_{x\to\frac{\pi}{6}}\dfrac{2\sin^2 x-3\sin x+1}{4\sin^2 x-1}=-\dfrac{1}{4}$ ។

ខ. $\lim\limits_{x\to 0}\dfrac{1+x\sin x-\cos x}{\sin^2 x}$

$$=\lim_{x\to 0}\frac{\frac{\sin x}{x}+\frac{1-\cos x}{x^2}}{\frac{\sin^2 x}{x^2}}=\frac{1+\frac{1}{2}}{1^2}=\frac{3}{2}$$ ព្រោះ $\lim\limits_{x\to 0}\dfrac{\sin x}{x}=1$

និង $\lim\limits_{x\to 0}\dfrac{1-\cos x}{x^2}=\lim\limits_{x\to 0}\dfrac{2\sin^2\frac{x}{2}}{x^2}=\dfrac{1}{2}\lim\limits_{x\to 0}\dfrac{\sin^2\frac{x}{2}}{\left(\frac{x}{2}\right)^2}=\dfrac{1}{2}$ ។

ដូចនេះ $\lim\limits_{x\to 0}\dfrac{1+x\sin x-\cos x}{\sin^2 x}=\dfrac{3}{2}$ ។

គ. $\lim\limits_{x\to a}\dfrac{x(a-b)}{\sin ax-\sin bx}$ ( $a\neq 0$ , $b\neq 0$ , $a\neq b$ )

គេមាន $\sin ax-\sin bx=2\sin\dfrac{(a-b)x}{2}\cos\dfrac{(a+b)x}{2}$

$$=\lim_{x\to 0}\frac{x(a-b)}{2\sin\frac{(a-b)x}{2}\cos\frac{(a+b)x}{2}}$$

$$=\lim_{x\to 0}\frac{(a-b)x}{2\sin\frac{(a-b)x}{2}}\times\frac{1}{\cos\frac{(a+b)x}{2}}=1$$

ឃ. $\lim\limits_{x\to 0}\frac{\sin^2 x}{\sqrt{1+x\sin x}-\cos x}$

$$=\lim_{x\to 0}\frac{\sin^2 x(\sqrt{1+x\sin x}+\cos x)}{1+x\sin x-\cos^2 x}$$

$$=\lim_{x\to 0}\frac{\sin^2 x(\sqrt{1+x\sin x}+\cos x)}{x\sin x+\sin^2 x}$$

$$=\lim_{x\to 0}\frac{\sin x(\sqrt{1+x\sin x}+\cos x)}{x+\sin x}$$

$$=\lim_{x\to 0}\frac{\frac{\sin x}{x}}{1+\frac{\sin x}{x}}\times\lim_{x\to 0}(\sqrt{1+x\sin x}+\cos x)=\frac{1}{2}\times 2=1$$

ដូចនេះ $\lim\limits_{x\to 0}\frac{\sin^2 x}{\sqrt{1+x\sin x}-\cos x}=1$ ។

ង. $\lim\limits_{x\to+\infty}(\sqrt{x^2+3x}-\sqrt{x^2+1}-1)$

$$=\lim_{x\to+\infty}\left(\frac{x^2+3x-x^2-1}{\sqrt{x^2+3x}+\sqrt{x^2+1}}-1\right)$$

$$=\lim_{x\to+\infty}\left(\frac{3x-1}{\sqrt{x^2+3x}+\sqrt{x^2+1}}-1\right)$$

$$=\frac{3}{2}-1=\frac{1}{2}$$

ដូចនេះ $\lim\limits_{x\to+\infty}(\sqrt{x^2+3x}-\sqrt{x^2+1}-1)=\frac{1}{2}$ ។

ច. $\lim_{x\to 0}\frac{\sin 3x}{\sqrt{x+2}-\sqrt{2}}$

$$=\lim_{x\to 0}\frac{\sin 3x(\sqrt{x+2}+\sqrt{2})}{x+2-2}$$

$$=3\lim_{x\to 0}\frac{\sin 3x}{3x}\times\lim_{x\to 0}(\sqrt{x+2}+\sqrt{2})$$

$$=3\times 1\times 2\sqrt{2}=6\sqrt{2}$$

ដូចនេះ $\lim_{x\to 0}\frac{\sin 3x}{\sqrt{x+2}-\sqrt{2}}=6\sqrt{2}$ ។

9-កំនត់អនុគមន៍ដឺក្រេទីពីរដែលបំពេញលក្ខខណ្ឌលីមីតទាំងពីរខាងក្រោម

$$\lim_{x\to +\infty}\frac{f(x)}{x^2-1}=1\ \ (i)\quad \text{និង}\quad \lim_{x\to 1}\frac{f(x)}{x^2-1}=-1\ \ (ii)$$

**ដំណោះស្រាយ**

កំនត់អនុគមន៍ដឺក្រេទីពីរ

តាង $f(x)=ax^2+bx+c$

គេមាន $\lim_{x\to +\infty}\frac{ax^2+bx+c}{x^2-1}=1$

សមមូល $\lim_{x\to +\infty}\frac{ax^2}{x^2}=1\Rightarrow a=1$

អនុគមន៍អាចសរសេរ $f(x)=x^2+bx+c$ ។

គេមាន $\lim_{x\to 1}\frac{f(x)}{x^2-1}=-1$

គេទាញ $\lim_{x\to 1}f(x)=0$

$$\lim_{x\to 1}(x^2+bx+c)=0$$

$$1+b+c=0\Rightarrow c=-1-b$$

អនុគមន៍អាចសរសេរ $f(x)=x^2+bx-1-b$

$$f(x)=(x-1)(x+1)+b(x-1)$$

$$=(x-1)(x+1+b)$$

ហើយ $\lim_{x\to 1}\frac{f(x)}{x^2-1}=\lim_{x\to 1}\frac{(x-1)(x+1+b)}{x^2-1}=-1$

ឬ $\lim_{x\to 1}\frac{(x-1)(x+1+b)}{(x-1)(x+1)}=-1$

$$\lim_{x\to 1}\frac{x+1+b}{x+1}=-1$$

$$\frac{2+b}{2}=-1\Rightarrow b=-4$$

ដូចនេះ $f(x)=x^2-4x+3$ ។

10-គេមានពហុកោណនិយ័តចារឹកក្នុងរង្វង់ដែលមាន **n** ជ្រុងនិងកាំស្មើ **a** ។

តាង $S_n$ ជាផ្ទៃក្រឡានៃពហុកោណនេះ ។ គណនា $S_n$ រួច $\lim\limits_{n\to+\infty} S_n$ ។

**ដំណោះស្រាយ**




គណនា $S_n$ រួច $\lim\limits_{n\to+\infty} S_n$

-មុំផ្ចិតរបស់ពហុកោណ

$$\varphi_n = \frac{2\pi}{n}$$

-ក្រឡាផ្ទៃត្រីកោណ**OAB**

$$S_{OAB} = \frac{1}{2}a^2 \sin\frac{2\pi}{n}$$

-ក្រឡាផ្ទៃរបស់ពហុកោណនិយ័ត **n** ជ្រុង

$$S_n = n\times S_{OAB} = \frac{1}{2}a^2 n \sin\frac{2\pi}{n}$$

យើងបាន $\lim\limits_{n\to+\infty} S_n = \lim\limits_{n\to+\infty}\frac{1}{2}a^2 n\sin\frac{2\pi}{n} = \pi a^2 \lim\limits_{n\to+\infty}\dfrac{\sin\frac{2\pi}{n}}{\frac{2\pi}{n}} = \pi a^2$

ដូចនេះ $\lim\limits_{n\to+\infty} S_n = \pi a^2$ ។

*មេរៀនទី២*

# ភាពជាប់នៃអនុគមន៍

## ១_ភាពជាប់ត្រង់មួយចំនុច

✍ ***និយមន័យ*** :

អនុគមន៍ $y = f(x)$ ជាប់ត្រង់ចំនុច $x = c$ កាលណា $f$ បំពេញលក្ខខណ្ឌទាំងបីដូចខាងក្រោម

1- $f$ កំណត់ចំពោះ $x = c$

2- $f$ មានលីមីតកាលណា $x \to c$

3- $\lim\limits_{x \to c} f(x) = f(c)$

## ២_លក្ខណៈនៃអនុគមន៍ជាប់

បើ $f$ និង $g$ ជាអនុគមន៍ជាប់ត្រង់ $x = c$ នោះគេបាន

១. $f(x) \pm g(x)$ ជាអនុគមន៍ជាប់ត្រង់ $x = c$

២. $f(x).g(x)$ ជាអនុគមន៍ជាប់ត្រង់ $x = c$

៣. $\dfrac{f(x)}{g(x)}$ ជាអនុគមន៍ជាប់ត្រង់ $x = c$ ដែល $g(c) \neq 0$ ។

## ៣_ភាពជាប់លើចន្លោះ

✍ ***និយមន័យ*** :

-អនុគមន៍ $\mathbf{f}$ ជាប់លើចន្លោះបើក $\mathbf{(a,b)}$ លុះត្រាតែ $\mathbf{f}$ ជាប់ចំពោះគ្រប់តម្លៃ $\mathbf{x}$ នៃចន្លោះបើនោះ ។

-អនុគមន៍ $\mathbf{f}$ ជាប់លើចន្លោះបិទ $\mathbf{[a,b]}$ លុះត្រាតែ $\mathbf{f}$ ជាប់ លើចន្លោះបើក $\mathbf{(a,b)}$ និងមានលីមីត $\lim\limits_{x\to a^+} f(x) = f(a)$ ; $\lim\limits_{x\to b^-} f(x) = f(b)$

( អនុគមន៍ $\mathbf{f}$ ជាប់ត្រង់ $\mathbf{a}$ ខាងស្តាំ ជាប់ត្រង់ $\mathbf{b}$ ខាងឆ្វេង )

## ៤_ភាពជាប់នៃអនុគមន៍បណ្តាក់

បើអនុគមន៍ $\mathbf{g}$ ជាប់ត្រង់ $\mathbf{x = c}$ និងអនុគមន៍ $\mathbf{f}$ ជាប់ត្រង់ $\mathbf{g(c)}$ នោះអនុគមន៍បណ្តាក់ $(f \circ g)(x) = f\left[\, g(x) \,\right]$ ជាប់ត្រង់ $\mathbf{c}$ ។

## ៥_អនុវត្តន៍ អនុគមន៍បន្លាយតាមភាពជាប់

បើ $\mathbf{f}$ ជាអនុគមន៍មិនកំនត់ត្រង់ $\mathbf{x = a}$ និងមានលីមីត $\lim\limits_{x\to a} f(x) = L$ នោះអនុគមន៍បន្លាយនៃ $\mathbf{f}$ តាមភាពជាប់ត្រង់ $\mathbf{x = a}$ កំនត់ដោយ

$$g(x) = \begin{cases} f(x) & \text{បើ } x \neq a \\ L & \text{បើ } x = a \end{cases}$$

# ៦_ទ្រឹស្តីបទតម្លៃកណ្តាល

*ទ្រឹស្តីបទ* :

បើអនុគមន៍ $f$ ជាប់លើចន្លោះបិទ $[a, b]$ និង $k$ ជាចំនួនមួយនៅចន្លោះ $f(a)$ និង $f(b)$ នោះមានចំនួនពិត $c$ មួយយ៉ាងតិចក្នុងចន្លោះបិទ $[a, b]$ ដែល $f(c) = k$ ។



## លំហាត់ និង ដំណោះស្រាយ

1-បញ្ជាក់ថា តើអនុគមន៍ខាងក្រោមជាប់ត្រង់តម្លៃ $x$ ដែលឱ្យឬទេ ?

ក. $f(x) = 5x^2 - 6x + 1$ , $x = 2$

ខ. $f(x) = \dfrac{x+2}{x+1}$ , $x = 1$

គ. $f(x) = \dfrac{\sqrt{x}-2}{x-4}$ , $x = 4$

ឃ. $f(x) = \dfrac{|x+2|}{x+2}$ , $x = -2$

ង. $f(x) = \begin{cases} x+1 & \text{បើ } x \le 2 \\ 2 & \text{បើ } x > 2 \end{cases}$ , $x = 2$

ច. $f(x) = \begin{cases} \dfrac{x^2-1}{x+1} & \text{បើ } x < -1 \\ x^2 - 3 & \text{បើ } x \ge -1 \end{cases}$ , $x = -1$

### ដំណោះស្រាយ

**សិក្សាភាពជាប់នៃអនុគមន៍**

ក. $f(x) = 5x^2 - 6x + 1$ , $x = 2$

មាន $f(2) = 20 - 12 + 1 = 9$ កំនត់

$\lim_{x\to 2} f(x) = \lim_{x\to 2}(5x^2 - 6x + 1) = 20 - 12 + 1 = 9$

ដោយ $\lim_{x\to 2} f(x) = f(2) = 9$ នាំឱ្យ $f$ ជាអនុគមន៍ជាប់ត្រង់ $x = 2$ ។

ខ. $f(x) = \dfrac{x+2}{x+1}$ , $x = 1$

មាន $f(1) = \dfrac{3}{2}$ កំនត់

$\lim_{x\to 1} f(x) = \lim_{x\to 1} \dfrac{x+2}{x+1} = \dfrac{3}{2}$

ដោយ $\lim_{x\to 1} f(x) = f(1) = \dfrac{3}{2}$ នាំឱ្យ $f$ ជាអនុគមន៍ជាប់ត្រង់ $x = 1$ ។

គ. $f(x) = \dfrac{\sqrt{x} - 2}{x - 4}$ , $x = 4$

មាន $f(4) = \dfrac{\sqrt{4} - 2}{4 - 4} = \dfrac{0}{0}$ មិនកំនត់

ដូចនេះ $f$ ជាអនុគមន៍ដាច់ត្រង់ $x = 4$ ។

ឃ. $f(x) = \dfrac{|x+2|}{x+2}$ , $x = -2$

មាន $f(-2) = \dfrac{|-2+2|}{-2+2} = \dfrac{0}{0}$ មិនកំនត់

ដូចនេះ $f$ ជាអនុគមន៍ដាច់ត្រង់ $x = -2$ ។

ង. $f(x)=\begin{cases} x+1 & \text{បើ } x\le 2 \\ 2 & \text{បើ } x>2 \end{cases}$ , $x=2$

មាន $f(2)=2+1=3$

$\lim\limits_{x\to 2^-} f(x)=\lim\limits_{x\to 2^-}(x+1)=3$ និង $\lim\limits_{x\to 2^+} f(x)=\lim\limits_{x\to 2^+}(2)=2$

ដោយ $\lim\limits_{x\to 2^-} f(x)\ne \lim\limits_{x\to 2^+} f(x)$ នោះ $f(x)$ គ្មានលីមីត $x\to 2$ ។

ដូចនេះ $f(x)$ ជាអនុគមន៍ដាច់ត្រង់ $x=2$ ។

ច. $f(x)=\begin{cases} \dfrac{x^2-1}{x+1} & \text{បើ } x<-1 \\ x^2-3 & \text{បើ } x\ge -1 \end{cases}$ , $x=-1$

មាន $f(-1)=1-3=-2$ កំនត់

$\lim\limits_{x\to -1^-} f(x)=\lim\limits_{x\to -1^-}\left(\dfrac{x^2-1}{x+1}\right)=\lim\limits_{x\to -1^-}(x-1)=-2$

$\lim\limits_{x\to -1^+} f(x)=\lim\limits_{x\to -1^+}(x^2-3)=-2$

ដោយ $\lim\limits_{x\to -1^-} f(x)=\lim\limits_{x\to -1^+} f(x)=-2$

ដូចនេះ $f(x)$ ជាអនុគមន៍ជាប់ត្រង់ $x=-1$ ។

2-រកតម្លៃ x ដែលធ្វើឱ្យអនុគមន៍ខាងក្រោមជាអនុគមន៍ដាច់ ។

ក. $f(x)=\dfrac{3x-1}{2x-6}$

ខ. $f(x)=\dfrac{x}{x^2+4x-5}$

គ. $f(x)=\dfrac{x^2-2x+1}{x^2-x-2}$

ឃ. $f(x)=\dfrac{3x-2}{x^2-3x-18}$

ង. $f(x)=\begin{cases}\dfrac{1}{2}x+1 & \text{បើ } x\le 2\\ 3-x & \text{បើ } x>2\end{cases}$

ច. $f(x)=\begin{cases}-x+1 & \text{បើ } x\le -1\\ 2 & \text{បើ } -1<x<1\\ -x+3 & \text{បើ } x>1\end{cases}$

**ដំណោះស្រាយ**

រកតម្លៃ x ដែលធ្វើឱ្យអនុគមន៍ខាងក្រោមជាអនុគមន៍ដាច់ ។

ក. $f(x)=\dfrac{3x-1}{2x-6}$

អនុគមន៍ f ជាអនុគមន៍ដាច់លុះត្រាតែ $2x-6=0\Rightarrow x=3$ ។

ខ. $f(x)=\dfrac{x}{x^2+4x-5}$

អនុគមន៍ f ជាអនុគមន៍ដាច់លុះត្រាតែ $x^2+4x-5=0$

គេទាញឫស $x_1=1\ ;\ x_2=-5$ ។

គ. $f(x)=\dfrac{x^2-2x+1}{x^2-x-2}$

អនុគមន៍ f ជាអនុគមន៍ដាច់លុះត្រាតែ $x^2-x-2=0$

គេទាញឫស $x_1=-1\ ;\ x_2=2$ ។

ឃ. $f(x)=\dfrac{3x-2}{x^2-3x-18}$

អនុគមន៍ f ជាអនុគមន៍ដាច់លុះត្រាតែ $x^2-3x-18=0$

$\Delta=9+72=9^2$

គេទាញឫស $x_1=\dfrac{3+9}{2}=6\ ;\ x_2=\dfrac{3-9}{2}=-3$ ។

ង. $f(x)=\begin{cases}\dfrac{1}{2}x+1 & \text{បើ}\quad x\le 2\\ 3-x & \text{បើ}\quad x>2\end{cases}$

តាង $(d_1): y=\dfrac{1}{2}x+1\ ,\ x\le 2$

និង $(d_2): y=3-x\ ,\ x>2$




តាមក្រាហ្វិកយើងឃើញថាគ្រប់ $x \in IR$ , $f$ ជាអនុគមន៍ដាច់ ។

ច. $f(x) = \begin{cases} -x+1 & \text{បើ } x \leq -1 \\ 2 & \text{បើ } -1 < x < 1 \\ -x+3 & \text{បើ } x > 1 \end{cases}$

ដោះស្រាយដូចលំហាត់ទី ( ង )

គេបានគ្រប់ $x \in IR$ អនុគមន៍ $f$ ជាអនុគមន៍ដាច់ ។

3-សិក្សាភាពជាប់នៃអនុគមន៍ខាងក្រោមលើចន្លោះដែលឱ្យ ។

ក. $f(x)=\frac{x-3}{4+x}$ លើចន្លោះ $(0,1)$ និង $[-4,1]$

ខ. $f(x)=x(1+\frac{1}{x})$ លើចន្លោះ $(0,1)$ និង $[0,1]$

គ. $f(x)=\begin{cases} x(x-1) & \text{បើ } x\le 3 \\ \frac{x^2-9}{x-3} & \text{បើ } x>3 \end{cases}$

លើចន្លោះ $(0,3)$ និង $[0\ ,\ 3\ ]$

**ដំណោះស្រាយ**

សិក្សាភាពជាប់នៃអនុគមន៍

ក. $f(x)=\frac{x-3}{4+x}$ លើចន្លោះ $(0,1)$ និង $[-4,1]$

-លើចន្លោះ $(0,1)$ យើងឃើញថាអនុគមន៍ $f$ កំនត់បានជានិច្ច

ដូចនេះអនុគមន៍ $f$ ជាអនុគមន៍ជាប់លើចន្លោះ $(\ 0\ ,\ 1\ )$ ។

-លើចន្លោះ $[-4\ ,\ 1\ ]$ អនុគមន៍ $f$ មិនអាចកំនត់បានជានិច្ចទេ ព្រោះ

បើ $x=-4$ នោះ $f(-4)=\frac{-4-3}{4-4}=-\frac{7}{0}$ មិនកំនត់ ។

ដូចនេះ $f$ ជាអនុគមន៍ដាច់ត្រង់ $x=-4$ និងដាច់ក្នុងចន្លោះ $[-4\ ,\ 1\ ]$ ។

ខ. $f(x)=x(1+\frac{1}{x})$ លើចន្លោះ $(0,1)$ និង $[0,1]$

-លើចន្លោះ $(0\,,1)$ យើងឃើញថា $f(x)=x(1+\frac{1}{x})=x+1$ កំនត់

ដូចនេះ $f$ ជាអនុគមន៍ជាប់លើចន្លោះ $(0\,,1)$ ។

-លើចន្លោះ $[\,0\,,1\,]$ យើងឃើញថា $f$ ជាអនុគមន៍ដាច់ត្រង់ $x=0$

ព្រោះអនុគមន៍ $f$ មិនកំនត់ត្រង់ $x=0$ ។

ដូចនេះ $f$ ជាអនុគមន៍ដាច់លើចន្លោះ $[\,0\,,1\,]$ ។

គ. $f(x)=\begin{cases} x(x-1) & \text{បើ } x\le 3 \\ \dfrac{x^2-9}{x-3} & \text{បើ } x>3 \end{cases}$

លើចន្លោះ $(0,3)$ និង $[0\,,3\,]$

បើ $x=3$ នោះ $f(3)=3(3-1)=6$ កំនត់

មាន $\lim\limits_{x\to 3^-} f(x)=\lim\limits_{x\to 3^-} x(x-1)=6$

និង $\lim\limits_{x\to 3^+} f(x)=\lim\limits_{x\to 3^+}\dfrac{x^2-9}{x-3}=\lim\limits_{x\to 3+}(x+3)=6$

ដោយ $\lim\limits_{x\to 3^-} f(x)=\lim\limits_{x\to 3^+} f(x)=6\Rightarrow \lim\limits_{x\to 3} f(x)=6=f(3)$

ដូចនេះ $f$ ជាអនុគមន៍ជាប់លើ IR ។ ហេតុនេះវាជាអនុគមន៍ជាប់

លើចន្លោះ $(0,3)$ និង $[0\,,3\,]$ ។

4-រកតម្លៃ $\mathbf{A}$ ដែលធ្វើឱ្យ $\mathbf{f(x)}$ ជាប់គ្រប់តម្លៃ $\mathbf{x}$

ក. $\mathbf{f(x)} = \begin{cases} \mathbf{Ax-3} & \text{បើ } \mathbf{x<2} \\ \mathbf{3-x+2x^2} & \text{បើ } \mathbf{x\geq 2} \end{cases}$

ខ. $\mathbf{f(x)} = \begin{cases} \mathbf{1-3x} & \text{បើ } \mathbf{x<4} \\ \mathbf{Ax^2+2x-3} & \text{បើ } \mathbf{x\geq 4} \end{cases}$

**ដំណោះស្រាយ**

រកតម្លៃ $\mathbf{A}$ ដែលធ្វើឱ្យ $\mathbf{f(x)}$ ជាប់គ្រប់តម្លៃ $\mathbf{x}$

ក. $\mathbf{f(x)} = \begin{cases} \mathbf{Ax-3} & \text{បើ } \mathbf{x<2} \\ \mathbf{3-x+2x^2} & \text{បើ } \mathbf{x\geq 2} \end{cases}$

ដើម្បីឱ្យ $\mathbf{f(x)}$ ជាប់គ្រប់តម្លៃ $\mathbf{x}$ លុះត្រាតែ

$$\lim_{x\to 2^-} f(x) = \lim_{x\to 2^+} f(x) = f(2)$$

គេបាន $\lim\limits_{x\to 2^-}(Ax-3) = \lim\limits_{x\to 2^+}(3-x+2x^2)$

$$2A-3 = 3-2+8$$

$$2A-3 = 9 \Rightarrow A = 6$$

ដូចនេះ $\mathbf{A=6}$ ។

ខ. $f(x)=\begin{cases} 1-3x & \text{បើ } x<4 \\ Ax^2+2x-3 & \text{បើ } x\geq 4 \end{cases}$

ដើម្បីឱ្យ $f(x)$ ជាប់គ្រប់តម្លៃ $x$ លុះត្រាតែ

$$\lim_{x\to 4^-} f(x)=\lim_{x\to 4^+} f(x)=f(4)$$

គេបាន $\lim_{x\to 4^-}(1-3x)=\lim_{x\to 4^+}(Ax^2+2x-3)$

$$1-12=16A+8-3$$

$$-11=16A+5\Rightarrow A=-1$$

ដូចនេះ $A=-1$ ។

5-រកតម្លៃ $A$ និង $B$ ដែលធ្វើឱ្យអនុគមន៍កំណត់ដោយ

$$f(x)=\begin{cases} Ax^2+5x-9 & \text{បើ } x<1 \\ B & \text{បើ } x=1 \\ (3-x)(A-2x) & \text{បើ } x>1 \end{cases}$$

ជាប់គ្រប់តម្លៃ $x$ ។

## ដំណោះស្រាយ

រកតម្លៃ $A$ និង $B$

ដើម្បីឱ្យ $f(x)$ ជាប់គ្រប់តម្លៃ $x$ លុះត្រាតែ

$$\lim_{x\to1^-} f(x)=\lim_{x\to1^+} f(x)=f(1)$$

គេបាន $\lim_{x\to1^-}(Ax^2+5x-9)=\lim_{x\to1^+}(3-x)(A-2x)=B$

$$A+5-9=2(A-2)=B$$

$$A-4=2A-4=B$$

**គេទាញ** $A=0$ , $B=-4$ ។

6-ក្នុងបណ្តាអនុគមន៍ខាងក្រោម តើ **f** អាចមានបន្លាយតាមភាពជាប់ត្រង់ **a** ឬទេ ?

ក. $\mathbf{f(x)=\dfrac{x^2-9}{x-3}}$ , $\mathbf{a=3}$ ។

ខ. $\mathbf{f(x)=\dfrac{x^2+3x-10}{x-2}}$ , $\mathbf{a=2}$ ។

គ. $\mathbf{f(x)=\dfrac{x^3-1}{x-1}}$ , $\mathbf{a=1}$ ។

ឃ. $\mathbf{f(x)=\dfrac{x^2-16}{x^2-3x-4}}$ , $\mathbf{a=4}$

**ដំណោះស្រាយ**

រកអនុគមន៍បន្លាយតាមភាពជាប់

ក. $\mathbf{f(x)=\dfrac{x^2-9}{x-3}}$ , $\mathbf{a=3}$ ។

គេមាន $\mathbf{\lim\limits_{x\to3}f(x)=\lim\limits_{x\to3}\dfrac{x^2-9}{x-3}=\lim\limits_{x\to3}(x+3)=6}$

ដូចនេះគេអាចបន្លាយ **f** តាមភាពជាប់ត្រង់ $\mathbf{a=3}$ ។

បើ **g** ជាអនុគមន៍បន្លាយតាមភាពជាប់នោះអនុគមន៍ **g** កំនត់ដោយ

$$f(x)=\begin{cases}\dfrac{x^2-9}{x-3} & \text{បើ } x\neq 3\\ 6 & \text{បើ } x=3\end{cases}$$

ខ. $f(x)=\dfrac{x^2+3x-10}{x-2}$ , $a=2$ ។

គេមាន $\lim\limits_{x\to 2}f(x)=\lim\limits_{x\to 2}\dfrac{x^2+3x-10}{x-2}=\lim\limits_{x\to 2}(x+5)=7$

ដូចនេះគេអាចបន្លាយ $f$ តាមភាពជាប់ត្រង់ $a=2$ ។

បើ $g$ ជាអនុគមន៍បន្លាយតាមភាពជាប់នោះអនុគមន៍ $g$ កំនត់ដោយ

$$f(x)=\begin{cases}\dfrac{x^2+3x-10}{x-2} & \text{បើ } x\neq 2\\ 7 & \text{បើ } x=2\end{cases}$$

គ. $f(x)=\dfrac{x^3-1}{x-1}$ , $a=1$ ។

គេមាន $\lim\limits_{x\to 1}f(x)=\lim\limits_{x\to 1}\dfrac{x^3-1}{x-1}=\lim\limits_{x\to 1}(x^2+x+1)=3$

ដូចនេះគេអាចបន្លាយ $f$ តាមភាពជាប់ត្រង់ $a=1$ ។

បើ $g$ ជាអនុគមន៍បន្លាយតាមភាពជាប់នោះអនុគមន៍ $g$ កំនត់ដោយ

$$f(x)=\begin{cases}\dfrac{x^3-1}{x-1} & \text{បើ } x\neq 1\\ 3 & \text{បើ } x=1\end{cases}$$

ឃ. $f(x)=\dfrac{x^2-16}{x^2-3x-4}$ , $a=4$

គេមាន $\lim\limits_{x\to 4} f(x)=\lim\limits_{x\to 4}\dfrac{x^2-16}{x^2-3x-4}$

$$=\lim_{x\to 4}\frac{(x+4)(x-4)}{(x+1)(x-4)}$$

$$=\lim_{x\to 4}\frac{x+4}{x+1}=\frac{8}{5}$$

ដូចនេះគេអាចបន្លាយ $f$ តាមភាពជាប់ត្រង់ $a=4$ ។

បើ $g$ ជាអនុគមន៍បន្លាយតាមភាពជាប់នោះអនុគមន៍ $g$ កំនត់ដោយ

$$f(x)=\begin{cases}\dfrac{x^2-16}{x^2-3x-4} & \text{បើ } x\neq 4\\[2ex] \dfrac{8}{5} & \text{បើ } x=4\end{cases}$$

7-ប្រើទ្រឹស្តីបទតម្លៃកណ្តាល បង្ហាញថា អនុគមន៍ខាងក្រោមមានចំនួន $c$ ក្នុងចន្លោះដែលឱ្យ ។

ក. $f(x) = x^2 + x - 1$ , $[0,5]$ , $f(c) = 11$ ។

ខ. $f(x) = x^2 - 6x + 8$ , $[0 , 3 ]$ , $f(c) = 0$ ។

គ. $f(x) = x^3 - x^2 + x - 2$ , $[0,3 ]$ , $f(c) = 4$ ។

ឃ. $f(x) = \dfrac{x^2 + x}{x - 1}$ , $[\dfrac{5}{2}, 4 ]$ , $f(c) = 6$

**ដំណោះស្រាយ**

ការបង្ហាញ

ក. $f(x) = x^2 + x - 1$ , $[0,5]$ , $f(c) = 11$ ។

គេមាន $f(0) = -1$ និង $f(5) = 25 + 5 - 1 = 29$

ដោយ $f(0) = -1 < f(c) = 11 < f(5) = 29$

ដូចនេះតាមទ្រឹស្តីបទតម្លៃកណ្តាលយ៉ាងហោចណាស់មាន $c$ មួយនៃ$[0,5]$ ដែល $f(c) = 11$ ។

ខ. $f(x)=x^2-6x+8$ , $[0\ ,\ 3\ ]$ , $f(c)=0$ ។

គេមាន $f(0)=8$ និង $f(3)=9-18+8=-1$

ដោយ $f(3)=-1<f(c)=0<f(0)=8$

ដូចនេះតាមទ្រឹស្តីបទតម្លៃកណ្តាលយ៉ាងហោចណាស់មាន c មួយនៃ$[0,3]$

ដែល $f(c)=0$ ។

គ. $f(x)=x^3-x^2+x-2$ , $[0,3\ ]$ , $f(c)=4$ ។

គេមាន $f(0)=-2$ និង $f(3)=27-9+3-2=19$

ដោយ $f(0)=-2<f(c)=4<f(3)=19$

ដូចនេះតាមទ្រឹស្តីបទតម្លៃកណ្តាលយ៉ាងហោចណាស់មាន c មួយនៃ$[0,3]$

ដែល $f(c)=4$ ។

ឃ. $f(x)=\dfrac{x^2+x}{x-1}$ , $[\ \dfrac{5}{2}\ ,\ 4\ ]$ , $f(c)=6$

គេមាន $f(\frac{5}{2})=\dfrac{\frac{25}{4}+\frac{5}{2}}{\frac{5}{2}-1}=\dfrac{\frac{35}{4}}{\frac{3}{2}}=\dfrac{35}{6}$ និង $f(4)=\dfrac{16+4}{4-1}=\dfrac{20}{3}$

ដោយ $f(\dfrac{5}{2})=\dfrac{35}{6}<f(c)=6<f(4)=\dfrac{20}{3}$ ដូចនេះតាមទ្រឹស្តីបទ

តម្លៃកណ្តាលយ៉ាងហោចណាស់មាន c មួយនៃ$[\dfrac{5}{2},4]$ ដែល $f(c)=6$ ។

8-គេឱ្យអនុគមន៍ និង ចន្លោះបិទដូចខាងក្រោម ។ប្រើទ្រឹស្តីបទតម្លៃកណ្តាល រកតម្លៃ $c$ បើគេស្គាល់តម្លៃ $k$ ។

ក. $f(x)=2+x-x^2$ , $[0,3]$ , $k=1$ ។

ខ. $f(x)=\sqrt{25-x^2}$ , $[-45 , 3]$ , $k=3$ ។

**ដំណោះស្រាយ**

រកតម្លៃ $c$

ក. $f(x)=2+x-x^2$ , $[0,3]$ , $k=1$ ។

ដោះស្រាយសមីការ $f(c)=k$ ដែល $c\in[0 , 3]$

គេបាន $2+c-c^2=1$ ឬ $c^2-c-1=0$ , $\Delta=1+4=5$

គេទាញឫស $c_1=\dfrac{1+\sqrt{5}}{2}$ , $c_2=\dfrac{1-\sqrt{5}}{2}<0$

ដូចនេះ $c=\dfrac{1+\sqrt{5}}{2}$ ។

ខ. $f(x)=\sqrt{25-x^2}$ , $[-45 , 3]$ , $k=3$ ។

ចម្លើយ $c=-4$ ( សិស្សដោះស្រាយខ្លួនឯង ) ។

9-ក.ស្រាយបញ្ជាក់ថាសមីការ $x\tan x=\cos x$ យ៉ាងហោចណាស់មាន

ឫសពិតមួយចន្លោះ $[0,\frac{\pi}{4}]$ ។

ខ.ស្រាយបញ្ជាក់ថាសមីការ $(x^n-1)\cos x+\sqrt{2}\sin x-1=0$

យ៉ាងហោចណាស់មានឫសពិតមួយចន្លោះ $(0,1)$ ។

**ដំណោះស្រាយ**

ក.ស្រាយបញ្ជាក់ថាសមីការ $x\tan x=\cos x$ យ៉ាងហោចណាស់មាន

ឫសពិតមួយចន្លោះ $[0,\frac{\pi}{4}]$ ។

តាងអនុគមន៍ $f(x)=x\tan x-\cos x$

គេមាន $f(0)=-1$ និង $f(\frac{\pi}{4})=\frac{\pi}{4}-\frac{\sqrt{2}}{2}>0$

ដោយ $f(0)\times f(\frac{\pi}{4})<-(\frac{\pi}{4}-\frac{\sqrt{2}}{2})<0$ នោះតាមទ្រឹស្តីបទតម្លៃ

កណ្តាលយ៉ាងហោចណាស់មានចំនួនពិត $c$ មួយនៃ $[0,\frac{\pi}{4}]$

ដែល $f(c)=0$ ។ ដូចនេះសមីការ $x\tan x=\cos x$ យ៉ាងហោចណាស់

មានឫសពិតមួយចន្លោះ $[0,\frac{\pi}{4}]$ ។

ខ.ស្រាយបញ្ជាក់ថាសមីការ $(x^n - 1)\cos x + \sqrt{2}\sin x - 1 = 0$

យ៉ាងហោចណាស់មានឫសពិតមួយចន្លោះ $(0, 1)$ ។

តាងអនុគមន៍ $f(x) = (x^n - 1)\cos x + \sqrt{2}\sin x - 1$

គេមាន $f(0) = -2$ និង $f(1) = \sqrt{2}\sin 1 - 1 > \sqrt{2}\sin\frac{\pi}{4} - 1 = 0$

ដោយ $f(0)\times f(1) < 0$ នោះតាមទ្រឹស្តីបទតម្លៃ

កណ្តាលយ៉ាងហោចណាស់មានចំនួនពិត $c$ មួយនៃ $[0, 1]$

ដែល $f(c) = 0$ ។

ដូចនេះសមីការ $(x^n - 1)\cos x + \sqrt{2}\sin x - 1 = 0$

យ៉ាងហោចណាស់មានឫសពិតមួយចន្លោះ $[0, \frac{\pi}{4}]$ ។

## លំហាត់ជំពូកទី១ និង ដំណោះស្រាយ

1-គណនាលីមីតខាងក្រោម

ក. $\lim\limits_{x\to+\infty}(\sqrt{4x^2+x+2}-\sqrt{x^2-x+3})$

ខ. $\lim\limits_{x\to+\infty}(\sqrt{x^2+x+2}-\sqrt{x^2-x+3})$

គ. $\lim\limits_{x\to0}\dfrac{x^2-x\sin x}{x-\sin^2 x}$

ឃ. $\lim\limits_{x\to0}\dfrac{2x-\sin x}{\sqrt{1-\cos x}}$

### ដំណោះស្រាយ

គណនាលីមីតខាងក្រោម

ក. $\lim\limits_{x\to+\infty}(\sqrt{4x^2+x+2}-\sqrt{x^2-x+3})$

$$=\lim_{x\to+\infty}\left(|x|\sqrt{4+\frac{1}{x}+\frac{2}{x^2}}-|x|\sqrt{1-\frac{1}{x}+\frac{3}{x^2}}\right)$$

$$=\lim_{x\to+\infty}|x|\left(\sqrt{4+\frac{1}{x}+\frac{2}{x^2}}-\sqrt{1-\frac{1}{x}+\frac{3}{x^2}}\right)=+\infty$$

ព្រោះ $\lim\limits_{x\to+\infty}\left(\sqrt{4+\frac{1}{x}+\frac{2}{x^2}}-\sqrt{1-\frac{1}{x}+\frac{3}{x^2}}\right)=2-1=1$ ។

ខ. $\lim_{x\to+\infty}(\sqrt{x^2+x+2}-\sqrt{x^2-x+3})$

$$=\lim_{x\to+\infty}\frac{x^2+x+2-x^2+x-3}{\sqrt{x^2+x+2}+\sqrt{x^2-x+3}}$$

$$=\lim_{x\to+\infty}\frac{2x-1}{|x|\sqrt{1+\frac{1}{x}+\frac{2}{x^2}}+|x|\sqrt{1-\frac{1}{x}+\frac{3}{x^2}}}$$

$$=\lim_{x\to+\infty}\frac{x(2-\frac{1}{x})}{|x|(\sqrt{1+\frac{1}{x}+\frac{2}{x^2}}+\sqrt{1-\frac{1}{x}+\frac{3}{x^2}})}$$

$$=\lim_{x\to+\infty}\frac{2-\frac{1}{x}}{\sqrt{1+\frac{1}{x}+\frac{2}{x^2}}+\sqrt{1-\frac{1}{x}+\frac{3}{x^2}}}=\frac{2}{1+1}=1$$

ដូចនេះ $\lim_{x\to+\infty}(\sqrt{x^2+x+2}-\sqrt{x^2-x+3})=1$

គ. $\lim_{x\to0}\frac{x^2-x\sin x}{x-\sin^2 x}$

$$=\lim_{x\to0}\frac{x(x-\sin x)}{x(1-\frac{\sin^2 x}{x})}=\lim_{x\to0}\frac{x-\sin x}{1-\frac{\sin x}{x}.\sin x}=\frac{0-0}{1-1\times0}=0$$

ដូចនេះ $\lim_{x\to0}\frac{x^2-x\sin x}{x-\sin^2 x}=0$ ។

ឃ. $\lim_{x\to 0}\frac{2x-\sin x}{\sqrt{1-\cos x}}$

$$=\lim_{x\to 0}\frac{(2x-\sin x)\sqrt{1+\cos x}}{\sqrt{1-\cos^2 x}}$$

$$=\lim_{x\to 0}\frac{(2x-\sin x)\sqrt{1+\cos x}}{|\sin x|}$$

$$=\lim_{x\to 0}\left(\frac{2x}{|\sin x|}-\frac{\sin x}{|\sin x|}\right)\sqrt{1+\cos x}$$

-បើ $x\to 0^-$ នោះ $|\sin x|=-\sin x$

គេបាន

$$\lim_{x\to 0^-}\frac{2x-\sin x}{\sqrt{1-\cos x}}=\lim_{x\to 0^-}\left(\frac{2x}{-\sin x}+1\right)\sqrt{1+\cos x}=-\sqrt{2}$$ -

បើ $x\to 0^+$ នោះ $|\sin x|=\sin x$

គេបាន

$$\lim_{x\to 0^+}\frac{2x-\sin x}{\sqrt{1-\cos x}}=\lim_{x\to 0^+}\left(\frac{2x}{\sin x}-1\right)\sqrt{1+\cos x}=\sqrt{2}$$

*មេរៀនទី១*

# ដេរីវេនៃអនុគមន៍

## ១_ដេរីវេនៃអនុគមន៍ត្រង់ $x_0$

### ✍ និយមន័យ :

ដេរីវេនៃអនុគមន៍ $y = f(x)$ ជាលីមីត ( បើមាន ) នៃផលធៀប កំនើន $\frac{\Delta y}{\Delta x}$ កាលណា $\Delta x$ ខិតទៅជិត $0$ ។

គេកំនត់សរសេរ

$$y'_0 = \lim_{\Delta x \to 0} \frac{\Delta y}{\Delta x} = \lim_{x \to x_0} \frac{f(x) - f(x_0)}{x - x_0} = \lim_{h \to 0} \frac{f(x_0 + h) - f(x_0)}{h}$$

## ២_ដេរីវេនៃអនុគមន៍បណ្ដាក់

បើ $y = f(u)$ និង $u = g(x)$ នោះគេបាន

$$\frac{dy}{dx} = \frac{dy}{du} \times \frac{du}{dx} = y' \times u'$$

ឬ $\frac{d}{dx} f[u(x)] = f'(u) \times u'(x)$

## ៣_ដេរីវេនៃអនុគមន៍ត្រីកោណមាត្រ

1. $y = \sin x \Rightarrow y' = \cos x$

2. $y = \cos x \Rightarrow y' = -\sin x$

3. $y = \tan x \Rightarrow y' = \frac{1}{\cos^2 x} = 1 + \tan^2 x$

4. $y = \cot x \Rightarrow y' = -\frac{1}{\sin^2 x} = -(1 + \cot^2 x)$

5. $y = \sin u \Rightarrow y' = u'\cos u$

6. $y = \cos u \Rightarrow y' = -\sin u$

7. $y = \tan u \Rightarrow y' = \frac{u'}{\cos^2 u}$

8. $y = \cot u \Rightarrow y' = -\frac{u'}{\sin^2 u}$

## ៤_ដេរីវេលំដាប់ខ្ពស់

បើអនុគមន៍ $y = f(x)$ មានដេរីវេបន្តបន្ទាប់ដល់លំដាប់ $n$

នោះ $y^{(n)} = f^{(n)}(x)$ ហៅថាដេរីវេទី $n$ នៃអនុគមន៍ $y = f(x)$

ហើយ $f^{(n)}(x) = \frac{d}{dx} f^{(n-1)}(x)$ ។

## លំហាត់ និង ដំណោះស្រាយ

1-គណនាដេរីវេនៃអនុគមន៍ខាងក្រោម

ក. $f(x)=(2x+1)^4$

ខ. $f(x)=\sqrt{5x^6-12}$

គ. $f(x)=(x^5-4x^2+8)^8$

ឃ. $f(x)=(3x^4-7x^2+9)^5$

ង. $f(x)=\dfrac{1}{5x^2-6x+2}$

ច. $f(x)=\dfrac{2}{(6x^2+5x+1)^2}$

**ដំណោះស្រាយ**

គណនាដេរីវេនៃអនុគមន៍ខាងក្រោម

ក. $f(x)=(2x+1)^4$

តាមរូបមន្ត $(u^n)'=n.u'.u^{n-1}$

**យើងបាន** $f'(x)=4(2x+1)'(2x+1)^3$

$$=8(2x+1)^3$$

ដូចនេះ $f'(x)=8(2x+1)^3$

ខ. $f(x)=\sqrt{5x^6-12}$

តាមរូបមន្ត $(\sqrt{u})'=\dfrac{u'}{2\sqrt{u}}$

យើងបាន $f'(x)=\dfrac{(5x^6-12)'}{2\sqrt{5x^6-12}}$

$=\dfrac{30x^5}{2\sqrt{5x^6-12}}$

$=\dfrac{15x^5}{\sqrt{5x^6-12}}$

គ. $f(x)=(x^5-4x^2+8)^8$

យើងបាន $f'(x)=8(x^5-4x^2+8)'(x^5-4x^2+8)^7$

$=8(5x^4-8x)(x^5-4x^2+8)^7$

$=8x(5x^3-8)(x^5-4x^2+8)^7$

ឃ. $f(x)=(3x^4-7x^2+9)^5$

យើងបាន $f'(x)=5(3x^4-7x^2+9)'(3x^4-7x^2+9)^4$

$=5(12x^3-14x)(3x^4-7x^2+9)^4$

$=10x(6x^2-7)(3x^4-7x^2+9)^4$

ង. $f(x)=\dfrac{1}{5x^2-6x+2}$

យើងបាន $f'(x)=-\dfrac{(5x^2-6x+2)'}{(5x^2-6x+2)^2}$

$=-\dfrac{10x-6}{(5x^2-6x+2)^2}$

ច. $f(x)=\dfrac{2}{(6x^2+5x+1)^2}$

គេអាចសរសេរ $f(x)=2(6x^2+5x+1)^{-2}$

**គេបាន** $f'(x)=-4(6x^2+5x+1)'(6x^2+5x+1)^{-3}$

$$=\frac{-4(12x+5)}{(6x^2+5x+1)^3}$$

2-គណនាដេរីវេនៃអនុគមន៍ខាងក្រោម

ក. $y=\dfrac{1}{\sqrt{4x^2+1}}$ ខ. $y=\dfrac{1}{\sqrt{5x^3+2}}$

គ. $y=\sqrt{\dfrac{3x+1}{2x-1}}$ ឃ. $y=\left(\dfrac{x+2}{2-x}\right)^3$

ង. $y=(x+2)^3(2x-1)^5$ ច. $y=2(3x+1)^4(5x-3)^2$

**ដំណោះស្រាយ**

ក. $y=\dfrac{1}{\sqrt{4x^2+1}}$

គេអាចសរសេរ $y=(4x^2+1)^{-\frac{1}{2}}$

គេបាន $y'=-\dfrac{1}{2}(4x^2+1)'(4x^2+1)^{-\frac{1}{2}-1}=-\dfrac{4x}{\sqrt{(4x^2+1)^3}}$

ខ. $y = \frac{1}{\sqrt{5x^3+2}}$

គេអាចសរសេរ $y = (5x^3+2)^{-\frac{1}{2}}$

គេបាន $y' = -\frac{1}{2}(5x^3+2)'(5x^3+2)^{-\frac{3}{2}}$

$$= -\frac{15x^2}{2\sqrt{(5x^3+2)^3}}$$

គ. $y = \sqrt{\frac{3x+1}{2x-1}}$

គេបាន $y' = (\frac{3x+1}{2x-1})' . \frac{2}{\sqrt{\frac{3x+1}{2x-1}}}$

$$= \frac{3(2x-1)-2(3x+1)}{(2x-1)^2} . \frac{2\sqrt{2x-1}}{\sqrt{3x+1}}$$

$$= -\frac{10}{(2x-1)\sqrt{(2x-1)(3x+1)}}$$

ឃ. $y = \left(\frac{x+2}{2-x}\right)^3$

គេបាន $y' = 3(\frac{x+2}{2-x})'\left(\frac{x+2}{2-x}\right)^3$

$$= \frac{3(2-x)+3(x+2)}{(2-x)^2} . \left(\frac{x+2}{2-x}\right)^3 = \frac{12(x+2)^3}{(2-x)^5}$$

ង. $y=(x+2)^3(2x-1)^5$

គេបាន $y'=3(x+2)^2(2x-1)^5+10(2x-1)^4(x+2)^3$

$=(x+2)^2(2x-1)^4(6x-3+10x+20)$

$=(16x+17)(x+2)^2(2x-1)^4$

ច. $y=2(3x+1)^4(5x-3)^2$

យើងបាន $y'=24(3x+1)^3(5x-3)^2+30(5x-3)(3x+1)^4$

$=2(5x-3)(3x+1)^3(60x-36+45x+15)$

$=2(5x-3)(105x-21)(3x+1)^3$

3-គណនាដេរីវេនៃអនុគមន៍ $f(x)$ តាមវិធីពីរយ៉ាងគឺ តាមរូបមន្តដេរីវេនៃផលគុណ និងដេរីវេនៃស្វ័យគុណ រួចបង្ហាញថាវិធីទាំងពីរមានលទ្ធផលដូចគ្នា

ក. $f(x)=(3x+5)^2$ ខ. $f(x)=(7-4x)^2$

**ដំណោះស្រាយ**

ក. $f(x)=(3x+5)^2$

គេអាចសរសេរ $f(x)=(3x+5)(3x+5)$

តាមរូបមន្ត $(uv)' = u'v + v'u$

គេបាន $f'(x) = (3x+5)'(3x+5) + (3x+5)'(3x+5)$
$= 3(3x+5) + 3(3x+5)$
$= 9x + 15 + 9x + 15$
$= 18x + 30 = 6(3x+5)$

ម្យ៉ាងទៀតដោយប្រើរូបមន្ត $(u^n)' = nu'.u^{n-1}$

គេបាន $f'(x) = 2(3x+5)'(3x+5)$

$= 6(3x+5)$

ខ. $f(x) = (7-4x)^2$

គេអាចសរសេរ $f(x) = (7-4x)(7-4x)$

គេបាន $f'(x) = (7-4x)'(7-4x) + (7-4x)'(7-4x)$
$= -4(7-4x) - 4(7-4x)$
$= 8(7-4x)$

**ម្យ៉ាងទៀតដោយប្រើរូបមន្ត** $(u^n)' = nu'.u^{n-1}$

**គេបាន** $f'(x) = 2(7-4x)'(7-4x)$

$= -8(7-4x)$ ។

4-គណនាដេរីវេនៃអនុគមន៍ខាងក្រោម

ក. $y = \sin^2 x + \cos^2 x$ ខ. $y = 5x^3 - 2\sin x \cos x$

គ. $y = (2x - \sin x)^3$ ឃ. $y = \sin x - x^2 \cos x$

ង. $y = x^2 - \tan^2 x$ ច. $y = 3x \cot^2 x$

## ដំណោះស្រាយ

គណនាដេរីវេនៃអនុគមន៍ខាងក្រោម

ក. $y = \sin^2 x + \cos^2 x$

ដោយ $\sin^2 x + \cos^2 x = 1$

គេបាន $y = 1 \Rightarrow y' = 0$

ខ. $y = 5x^3 - 2\sin x \cos x$

គេមាន $\sin 2x = 2\sin x \cos x$

គេបាន $y = 5x^3 - \sin 2x$

$$y' = 15x - 2\cos 2x$$

គ. $y = (2x - \sin x)^3$

$$y' = 3(2x - \sin x)'(2x - \sin x)^2$$

$$= 3(2 - \cos x)(2x - \sin x)^2$$

ឃ. $y = \sin x - x^2 \cos x$

$y' = (\sin x)' - (x^2)'\cos x - x^2(\cos x)'$

$= \cos x - 2x\cos x + x^2 \sin x$

$= (1-2x)\cos x + x^2 \sin x$

ង. $y = x^2 - \tan^2 x$

$y' = 2x - 2(\tan x)'\tan x$

$= 2x - 2(1+\tan^2 x)\tan x$

$= 2(x - \tan x - \tan^3 x)$

ច. $y = 3x\cot^2 x$

$y' = (3x)'\cot^2 x + 3x(\cot^2 x)'$

$= 3\cot^2 x - 6x(1+\cot^2 x)\cot x$

$= 3\cot x(\cot x - 2x - 2x\cot^2 x)$

5-គណនាដេរីវេនៃអនុគមន៍ខាងក្រោម

ក. $y = \sin^2 x^2$

ខ. $y = x^3 - \cos^2 5x$

គ. $y = \dfrac{\tan 2x}{1 - \cos x}$

ឃ. $y = x^3 - \sin(x^2 - 5x)$

ង. $y = \sin 3x + \cos(x^3 - 1)$

ច. $y = \tan(2x^3 - 5x)$

## ដំណោះស្រាយ

គណនាដេរីវេនៃអនុគមន៍ខាងក្រោម

ក. $y = \sin^2 x^2$

គេបាន $y' = 2(x^2)' \cos x^2 \sin x^2$

$= 4x \cos x^2 \sin x^2$

$= 2x \sin 2x^2$

ខ. $y = x^3 - \cos^2 5x$

គេបាន $y' = 3x^2 + 10 \sin 5x \cos 5x$

$= 3x^2 + 5 \sin 10x$

គ. $y = \dfrac{\tan 2x}{1 - \cos x}$

$$y' = \frac{2(1 + \tan^2 2x)(1 - \cos x) - \sin x \tan 2x}{(1 - \cos x)}$$

ឃ. $y = x^3 - \sin(x^2 - 5x)$

$$y' = 3x^2 - (x^2 - 5x)'\cos(x^2 - 5x)$$

$$= 3x^2 - (2x - 5)\cos(x^2 - 5x)$$

ង. $y = \sin 3x + \cos(x^3 - 1)$

$$y' = 3\cos 3x - 3x^2 \sin(x^3 - 1)$$

$$= 3(\cos 3x - x^2 \sin(x^3 - 1))$$

ច. $y = \tan(2x^3 - 5x)$

$$y' = \frac{(2x^3 - 5x)'}{\cos^2(2x^3 - 5x)}$$

$$= \frac{6x^2 - 5}{\cos^2(2x^3 - 5x)}$$

6-គណនាដេរីវេទី 2 នៃអនុគមន៍ខាងក្រោម

ក. $y = 3x^2 - \sin 2x$ ខ. $y = -3x^4 + 2x^2$

គ. $y = x + \frac{1}{x}$ ឃ. $y = \frac{x^2}{x+1}$

ង. $y = (x^2 + 4)^3$ ច. $y = (x^3 - 1)^4$

**ដំណោះស្រាយ**

គណនាដេរីវេទី 2 នៃអនុគមន៍ខាងក្រោម

ក. $y = 3x^2 - \sin 2x$

គេបាន $y' = 6x - 2\cos 2x$

$$y' = 3(3x - \cos 2x)$$

ហើយ $y'' = 3(3 + 2\sin 2x)$

ខ. $y = -3x^4 + 2x^2$

គេបាន $y' = 12x^3 + 4x$

ហើយ $y'' = 36x^2 + 4$

គ. $\mathbf{y = x + \frac{1}{x}}$

គេបាន $\mathbf{y' = 1 - \frac{1}{x^2}}$

ហើយ $\mathbf{y'' = \frac{2}{x^3}}$

ឃ. $\mathbf{y = \frac{x^2}{x+1}}$

គេអាចសរសេរ $\mathbf{y = \frac{(x^2-1)+1}{x+1} = x - 1 + \frac{1}{x+1}}$

គេបាន $\mathbf{y' = 1 - \frac{1}{(x+1)^2}}$

ហើយ $\mathbf{y'' = \frac{2}{(x+1)^3}}$ ។

ង. $\mathbf{y = (x^2+4)^3}$

គេបាន $\mathbf{y' = 6x(x^2+4)^2}$

ហើយ $\mathbf{y'' = 6(x^2+4)^2 + 24x^2(x^2+4)}$

$\mathbf{= 6(x^2+4)(x^2+4+4x^2)}$

$\mathbf{= 6(x^2+4)(5x^2+4)}$

ច. $\mathbf{y = (x^3-1)^4}$

$\mathbf{y'' = 12x(11x^3-2)(x^3-1)^2}$ ។

7-រក $y'$ ជាអនុគមន៍នៃ $x$ និង $y$

ក. $x=\tan y$

ខ. $x=\sin y$

គ. $xy+\sin y=0$

ឃ. $x+\sin y=xy$

ង. $x+\tan(xy)=0$

ច. $y^2=\sin^4 2x+\cos^4 2x$

**ដំណោះស្រាយ**

រក $y'$ ជាអនុគមន៍នៃ $x$ និង $y$

ក. $x=\tan y$

ធ្វើដេរីវេលើអង្គទាំងពីរគេបាន

$$(x)'=(\tan y)'$$

$$1=y'\frac{1}{\cos^2 y}\Rightarrow y'=\cos^2 y$$

ខ. $x=\sin y$

ធ្វើដេរីវេលើអង្គទាំងពីរគេបាន

$$(x)'=(\sin y)'$$

$$1=y'\cos y\Rightarrow y'=\frac{1}{\cos y}$$

គ. $xy + \sin y = 0$

ធ្វើដេរីវេលើអង្គទាំងពីរគេបាន

$(xy + \sin y)' = 0$

$y + xy' + y'\cos y = 0$

$$y'(x + \cos y) = -y \Rightarrow y' = -\frac{y}{x + \cos y}$$

ឃ. $x + \sin y = xy$

ធ្វើដេរីវេលើអង្គទាំងពីរគេបាន

$(x + \sin y)' = (xy)'$

$1 + y'\cos y = y + xy'$

$$y'(\cos y - x) = y - 1 \Rightarrow y' = \frac{y - 1}{\cos y - x}$$

ង. $x + \tan(xy) = 0$

ធ្វើដេរីវេលើអង្គទាំងពីរគេបាន

$(x + \tan(xy))' = 0$

$$1 + \frac{(xy)'}{\cos^2(xy)} = 0$$

$$1 + \frac{y + xy'}{\cos^2(xy)} = 0 \Rightarrow y' = -\frac{y + \cos^2(xy)}{x}$$

ច. $y^2 = \sin^4 2x + \cos^4 2x$

គេមាន

$$\sin^4 2x + \cos^4 2x = (\sin^2 2x + \cos^2 2x)^2 - 2\sin^2 2x\cos^2 2x$$
$$= 1 - \frac{1}{2}\sin^2 2x$$

គេបាន $y^2 = 1 - \frac{1}{2}\sin^2 2x$

ធ្វើដេរីវេលើអង្គទាំងពីរគេបាន

$$2yy' = -\sin 2x\cos 2x = -\frac{1}{2}\sin 4x$$

គេទាញ $y' = -\dfrac{\sin 4x}{4y}$ ។

8-រក $y'$ និង $y''$ ជាអនុគមន៍នៃ $x$ និង $y$

ក. $2x^2 + y^2 = 4$

ខ. $2x^3 + y^3 = 8$

គ. $x^2 + xy + y^2 = -1$

ឃ. $x^3 + 2xy - y^2 = 3$

ង. $x^3 + y^3 = 3xy$

ច. $x^3y + xy^3 = 3x^2$

## ដំណោះស្រាយ

រក $y'$ និង $y''$ ជាអនុគមន៍នៃ $x$ និង $y$

ក. $2x^2 + y^2 = 4$

ធ្វើដេរីវេលើអង្គទាំងពីរគេបាន

$$4x + 2yy' = 0 \Rightarrow y' = -\frac{2x}{y}$$

ហើយ $y'' = -\dfrac{2y - 2xy'}{y^2}$

$$= -\frac{2y - 2x(-\frac{2x}{y})}{y^2} = -\frac{2y^2 + 4x^2}{y^3}$$

ដូចនេះ $y' = -\dfrac{2x}{y}$ និង $y'' = -\dfrac{4x^2 + 2y^2}{y^3}$

ខ. $2x^3 + y^3 = 8$

ធ្វើដេរីវេលើអង្គទាំងពីរគេបាន

$$6x^2 + 3y'y^2 = 0 \Rightarrow y' = -\frac{2x^2}{y^2}$$

ហើយ $y'' = -\frac{4xy^2 - 4x^2yy'}{y^4}$

$$= -\frac{4xy - 4x^2y'}{y^3}$$

$$= -\frac{4xy - 4x^2(-\frac{2x^2}{y^2})}{y^3}$$

$$= -\frac{4xy^3 + 8x^4}{y^5}$$

ដូចនេះ $y' = -\frac{2x^2}{y^2}$ និង $y'' = -\frac{4xy^3 + 8x^4}{y^5}$

គ. $x^2 + xy + y^2 = -1$

ធ្វើដេរីវេលើអង្គទាំងពីរគេបាន

$$2x + y + xy' + 2yy' = 0$$

$$(x + 2y)y' = -(2x + y)$$

$$y' = -\frac{2x + y}{x + 2y}$$

ហើយ $y''=-\dfrac{(2+y')(x+2y)-(1+2y')(2x+y)}{(x+2y)^2}$

$$=-\frac{2x+4y+xy'+2yy'-2x-y-4xy'-2yy'}{(x+2y)^2}$$

$$=-\frac{3y-3xy'}{(x+2y)^2}=-\frac{3y-3x(-\frac{2x+y}{x+2y})}{(x+2y)^2}$$

$$=-\frac{3xy+6y^2+6x^2+3xy}{(x+2y)^3}$$

$$=-\frac{6(x^2+xy+y^2)}{(x+2y)^3}$$

ដោយ $x^2+xy+y^2=-1$

ដូចនេះ $y''=\dfrac{6}{(x+2y)^3}$ ។

១-គណនា

ក. $f^{(4)}(x)$ បើ $f(x) = x^3 - 3x^2 + 2x$

ខ. $f^{(6)}(x)$ បើ $f(x) = \frac{1}{7}x^7 - \sin 2x$

គ. $f^{(8)}(x)$ បើ $f(x) = x^8 - 5x^2 + \cos x$

ឃ. $f^{(10)}(x)$ បើ $f(x) = \frac{120}{x^6}$

## ដំណោះស្រាយ

ក. $f^{(4)}(x)$

មាន $f(x) = x^3 - 3x^2 + 2x$

គេបាន $f'(x) = 3x^2 - 6x + 2$

$f''(x) = 6x - 6$

$f^{(3)}(x) = 6$

$f^{(4)}(x) = 0$

ខ. $f^{(6)}(x)$

មាន $f(x) = \frac{1}{7}x^7 - \sin 2x$

គេបាន $f'(x) = x^6 - 2\cos 2x$

$f''(x) = 6x^5 + 4\sin 2x$

$f^{(3)}(x) = 30x^4 + 8\cos 2x$

$f^{(4)}(x) = 120x^3 - 16\sin 2x$

$f^{(5)}(x) = 360x^2 - 32\cos 2x$

$f^{(6)}(x) = 720x + 64\sin 2x$

គ. $f^{(8)}(x)$

មាន $f(x) = x^8 - 5x^2 + \cos x$

គេបាន $f'(x) = 8x^7 - 10x - \sin x$

$f''(x) = 8.7x^6 - 10 - \cos x$

$f^{(3)}(x) = 8.7.6x^5 + \sin x$

$f^{(4)}(x) = 8.7.6.5x^4 + \cos x$

$f^{(5)}(x) = 8.7.6.5.4x^3 - \sin x$

$f^{(6)}(x) = 8.7.6.5.4.3x^2 - \cos x$

$f^{(7)}(x) = 8.7.6.5.4.3.2x + \sin x$

$f^{(8)}(x) = 8! + \cos x$

ឃ. $f^{(10)}(x)$

គេមាន $f(x) = \dfrac{120}{x^6}$

គេបាន $f(x) = \dfrac{15!}{x^{16}}$ ( សិស្សដោះស្រាយខ្លួនឯង )

មេរៀនទី២

# អនុវត្តន៏នៃដេរីវេ

## ១_ល្បឿននៃចលនា

✍ **និយមន័យ :**

ល្បឿននៃចលនាមួយនៅខណៈ t គឺ $\mathbf{V(t) = S'(t) = \frac{dS}{dt}}$

ដែល **S(t)** ជាចម្ងាយនៅខណៈ **t** ។

## ២_សំទុះនៃចលនា

សំទុះនៃចលនាមួយនៅខណះ **t** គឺ $\mathbf{a(t) = \frac{dV(t)}{dt} = V'(t)}$

ដែល **V(t)** ជាល្បឿននៃចលនានៅខណៈ **t** ។

## លំហាត់ និង ដំណោះស្រាយ

1-ពីរ៉ាមីតចតុមុខនិយ័ត **SABCD** មានផ្ទៃក្រលាខាង $S_t$ ។
គណនាផលធៀបរង្វាស់កម្ពស់ **SO** និងជ្រុងមួយនៃបាតដើម្បីឱ្យមាឌពីរ៉ាមីតចតុមុខនិយ័តមានតម្លៃអតិបរមា ។

### ដំណោះស្រាយ

គណនាផលធៀបរង្វាស់កម្ពស់ **SO** និងជ្រុងមួយនៃបាត

តាង $AB = x$ , $x > 0$ ជាប្រវែងជ្រុងបាត ហើយយក **I** ជាចំនុចកណ្តាលនៃ **[AB]** នាំឱ្យ **SI** ជាអាប៉ូតែម ។




គេបានក្រឡាផ្ទៃខាងរបស់ពីរ៉ាមីត

$$S_L = \frac{1}{2}x.SI \times 4 \Rightarrow SI = \frac{S_L}{2x}$$

ត្រីកោណ **SOI** កែងត្រង់**O**

គេបាន$SI^2 = SO^2 + OI^2$

ឬ $SO^2 = \left(\frac{S_L}{2x}\right)^2 - \left(\frac{x}{2}\right)^2$

$$SO^2 = \frac{{S_L}^2 - x^4}{4x^2} \Rightarrow SO = \frac{\sqrt{{S_L}^2 - x^4}}{2x}$$

ដែល ${S_L}^2 - x^4 > 0$ ឬ $x < \sqrt{S_L}$ តែ $x > 0$

ហេតុនេះ $0 < x < \sqrt{S_L}$ ។

តាង $V$ ជាមាឌរបស់ពីរ៉ាមីត $SABCD$

គេបាន $V(x) = \frac{1}{3} S_{ABCD3} \times SO = \frac{1}{3} x^2 \frac{\sqrt{{S_L}^2 - x^4}}{2x}$

$$V(x) = \frac{1}{6} x \sqrt{{S_L}^2 - x^4}$$

យើងបាន $V'(x) = \frac{{S_L}^2 - 3x^4}{6\sqrt{{S_L}^2 - x^4}}$

បើ $V'(x) = 0 \Rightarrow x = \sqrt[4]{\frac{{S_L}^2}{3}}$

| $x$ | $0$ | | $\sqrt[4]{\frac{{S_L}^2}{3}}$ | | $\sqrt{S_L}$ |
|---|---|---|---|---|---|
| $V'(x)$ | | $+$ | $0$ | $-$ | |
| $V(x)$ | | ↗ | អតិបរមា | ↘ | |

តាមតារាងខាងលើយើងឃើញថា $\mathbf{V(x)}$ មានតម្លៃអតិបរមាលុះត្រា

តែ $\mathbf{x = \sqrt[4]{\frac{S_L^{\ 2}}{3}}}$ ។

ដោយ $\mathbf{SO = \frac{\sqrt{S_L^{\ 2} - x^4}}{2x} \Rightarrow \frac{SO}{x} = \frac{\sqrt{S_L^{\ 2} - x^4}}{2x^2}}$

ឬ $\mathbf{\frac{SO}{x} = \frac{\sqrt{S_L^{\ 2} - \frac{S_L^{\ 2}}{3}}}{2\sqrt{\frac{S_L^{\ 2}}{3}}} = \frac{\sqrt{2}}{2}}$ ។

ដូចនេះផលធៀបរង្វាស់កម្ពស់ និងជ្រុងបាតនៃពីរ៉ាមីតគឺ $\mathbf{\frac{\sqrt{2}}{2}}$ ។

2-ផលបូកបរិមាត្រការេមួយ និង រង្វង់មួយមានប្រវែង $L$ ។
គណនាផលធៀបរវាងរង្វាស់កាំរង្វង់ និង ជ្រុងការេដើម្បីឱ្យផលបូក
ផ្ទៃក្រឡាការេនិងរង្វង់មានតម្លៃអប្បបរមា ?

## ដំណោះស្រាយ

គណនាផលធៀបរវាងរង្វាស់កាំរង្វង់ និង ជ្រុងការេ




តាង $a$ ជារង្វាស់ជ្រុងនៃការេ និង $R$ ជារង្វាស់កាំនៃរង្វង់

ដោយ ផលបូកបរិមាត្រការេមួយ និង រង្វង់មួយមានប្រវែង $L$ នោះ

គេបាន $4a + 2\pi R = L \Rightarrow a = \dfrac{L - 2\pi R}{4}$ (1)

តាង $\sum$ ជាផលបូកផ្ទៃក្រឡាការេនិងរង្វង់ ។

គេបាន $\sum = a^2 + \pi R^2$ (2)

យក (1) ជំនួសក្នុង (2) គេបាន

$$\sum(R)=\left(\frac{L-2\pi R}{4}\right)^2+\pi R^2$$

$$=\frac{L^2-4\pi LR+20\pi^2R^2}{16}$$

គេបាន $\sum'(R)=\frac{-4\pi L+40\pi^2R}{16}$

បើ $\sum'(R)=0$ នោះ $-4\pi L+40\pi^2R=0\Rightarrow R=\frac{L}{10\pi}$

ម្យ៉ាងទៀតដោយ $\sum''(R)=\frac{40\pi}{16}=\frac{5\pi}{2}>0$ នាំឱ្យ $\sum(R)$ មាន

តម្លៃអប្បបរមាត្រង់ $R=\frac{L}{10\pi}$ ។

តាម (1) គេបាន $a=\frac{L-2\pi\times\frac{L}{10\pi}}{4}=\frac{L}{5\pi}$

គេបាន $\frac{R}{a}=\frac{\frac{L}{10\pi}}{\frac{L}{5\pi}}=\frac{5}{10}=\frac{1}{2}$ ។

ដូចនេះផលធៀបរវាង រង្វាស់កាំរង្វង់ និង ជ្រុងការេគឺ $\frac{1}{2}$ ។

3-ប្រអប់ត្រង់មួយមានគម្របលើ និង បាតក្រោមជាការេហើយមានមាឌ $250cm^3$ ។ សម្ភារះសម្រាប់ធ្វើគម្របលើ និងបាតក្រោមតម្លៃ **2000** រៀលក្នុងមួយសង្ទីម៉ែត្រការេ ហើយសម្ភារះសម្រាប់ធ្វើផ្ទៃខាងមានតម្លៃ **1000** រៀលក្នុងមួយសង្ទីម៉ែត្រការេ ។ កំនត់រង្វាស់ទ្រនុងនៃប្រអប់ដើម្បីឱ្យប្រាក់ចំណាយលើសម្ភារះមានតម្លៃអប្បរមា រួចគណនាប្រាក់ចំណាយអប្បបរមានោះ ?

**ដំណោះស្រាយ**

កំនត់រង្វាស់ទ្រនុងនៃប្រអប់ និង ប្រាក់ចំណាយអប្បបរមា

តាង **x** ជាជ្រុងបាត និង **y** ជាទ្រនុងខាង

មាឌរបស់ប្រអប់គឺ $V = x^2y = 250$

គេទាញ $y = \frac{250}{x^2}$ **(1)**




ប្រាក់ចំណាយសម្ភារះធ្វើគម្រប និង បាត

របស់ប្រអប់គឺ $2x^2 \times 2000 = 4000x^2$

ប្រាក់ចំណាយសម្ភារះធ្វើផ្ទៃខាងរបស់ប្រអប់គឺ

$4y^2 \times 1000 = 4000y^2$ ។

តាង T ជាអនុគមន៍ប្រាក់ចំណាយសរុបលើសម្ភារៈសម្រាប់ធ្វើប្រអប់

គេបាន $T = 4000x^2 + 4000y^2 = 4000(x^2 + y^2)$    (2)

យក (1) ជំនួសក្នុង (2) គេបាន

$$T(x) = 4000(x^2 + \frac{62500}{x^4})$$

គេបាន $T'(x) = 4000(2x - \frac{250000}{x^5})$

បើ $T'(x) = 0$ នោះ $2x - \frac{250000}{x^5} = 0$

គេទាញ $x = \sqrt[6]{125000} = \sqrt{50} = 5\sqrt{2}$

គេមាន $T''(x) = 4000(2 + \frac{1250000}{x^6})$

ចំពោះ $x = 5\sqrt{2} \Rightarrow T''(5\sqrt{2}) > 0$ នាំឱ្យ $T(x)$ មានតម្លៃអប្បបរមា

ត្រង់ $x = 5\sqrt{2}$ ហើយ $y = \frac{250}{x^2} = \frac{250}{50} = 5$ ។

ដូចនេះទំហំរបស់ប្រអប់គឺ 5cm ។

គណនាប្រាក់ចំណាយអប្បបរមា

ចំពោះ $x = 5\sqrt{2}$ , $y = 5$ គេបាន

$T = 4000(50 + 25) = 30,0000$ រៀល ជាប្រាក់ចំណាយអប្បបរមា

4-ទូកមួយចាប់ផ្តើមចេញដំណើរពីចំនុចត្រួតពិនិត្យ ដែលរយះពេល $t$ នាទីក្រោយមកទូកនោះមានចម្ងាយពីចំនុចត្រួតពិនិត្យដែលតាងដោយអនុគមន៍ $S(t)=t^3+60t$ គិតជាម៉ែត្រ ។

ក. រកល្បឿននៃទូកត្រង់ចំនុចចាប់ផ្តើម ?

ខ. កំនត់ល្បឿននៃទូកខណះ $t=3mn$ ?

**ដំណោះស្រាយ**

ក. រកល្បឿននៃទូកត្រង់ចំនុចចាប់ផ្តើម

តាង $V(t)$ ជាអនុគមន៍ល្បឿននៃទូកនៅខណៈ $t$ នោះគេបាន

$$V(t)=\frac{dS(t)}{dt}=S'(t)=3t^2+60$$

បើ $t=0 \Rightarrow V(t=0)=60m/mn$

ដូចនេះល្បឿននៃទូកត្រង់ចំនុចចាប់ផ្តើមគឺ $V=60m/mn$ ។

ខ. កំនត់ល្បឿននៃទូកខណះ $t=3mn$

បើ $t=3mn$ នោះ $V(3)=3(3)^2+60=87m/mn$

ដូចនេះ ល្បឿននៃទូកខណះ $t=3mn$ គឺ $87m/mn$ ។

5-រថយន្តមួយចាប់ផ្ដើមចេញដំណើរដោយល្បឿនដែលតាងដោយ

អនុគមន៍ $\mathbf{V(t)=\dfrac{100t}{t+15}\ \ (m/s)}$

កំនត់សំទុះនៃរថយន្តខណះពេល

ក. $\mathbf{t=5s}$ គ. $\mathbf{t=20s}$

ខ. $\mathbf{t=10s}$

**ដំណោះស្រាយ**

ក. $\mathbf{t=5s}$

តាង $\mathbf{a(t)}$ ជាអនុគមន៍សំទុះនៃរថយន្តនៅខណៈ $\mathbf{t}$ នោះគេបាន

$$\mathbf{a(t)=\frac{dV(t)}{dt}=V'(t)=\frac{1500}{(t+15)^2}}$$

បើ $\mathbf{t=5s\Rightarrow a(5)=\dfrac{1500}{400}=3.75m/s^2}$

ខ. បើ $\mathbf{t=10s\Rightarrow a(10)=\dfrac{1500}{625}=2.4m/s^2}$

គ. បើ $\mathbf{t=20s\Rightarrow a(20)=\dfrac{1500}{1225}=1.22m/s^2}$

6-រថយន្តមួយផ្តើមចេញដំនើរដោយល្បឿនដែល t វិនាទីតាងដោយ

អនុគមន៍ $\mathbf{V(t) = \dfrac{22t}{0.44t + 3.3}}$ ម៉ែត្រក្នុងមួយវិនាទី ។

កំណត់សំទុះរបស់រថយន្តនៅខណះពេល :

ក- **5** វិនាទី ខ-**10** វិនាទី គ- **20** វិនាទី ឃ- **30** វិនាទី ។

**ដំណោះស្រាយ**

កំណត់សំទុះរបស់រថយន្តនៅខណះពេល

មាន $\mathbf{V(t) = \dfrac{22t}{0.44t + 3.3} = \dfrac{2200t}{44t + 330} = \dfrac{200t}{4t + 10} = \dfrac{100t}{2t + 5}}$

គេបាន $\mathbf{a(t) = V'(t) = \dfrac{500}{(2t + 5)^2}}$

ក- $\mathbf{t = 5s \Rightarrow a(5) = \dfrac{500}{225} = 2.22 m/s^2}$

ខ-$\mathbf{t = 10s \Rightarrow a(10) = \dfrac{500}{625} = 0.80 m/s^2}$

គ- $\mathbf{t = 20s \Rightarrow a(20) = \dfrac{500}{2025} = 0.25 m/s^2}$

ឃ- $\mathbf{t = 30s \Rightarrow a(30) = \dfrac{500}{4225} = 0.12 m/s^2}$

## លំហាត់ជំពូកទី២ និង ដំណោះស្រាយ

1-គណនាដេរីវេនៃអនុគមន៍ខាងក្រោម

ក. $\mathbf{f(x)=(7x+2)^2}$

ខ. $\mathbf{g(x)=(x^2-8)^{-1}}$

គ. $\mathbf{y=(4x^2+9x-2)^3}$

ឃ. $\mathbf{f(x)=\sqrt[3]{5x^3-4}}$

ង. $\mathbf{g(x)=x(4-3x^2)^2}$

ច. $\mathbf{y=\dfrac{\sqrt{5x-2}}{x^3}}$

### ដំណោះស្រាយ

គណនាដេរីវេនៃអនុគមន៍

ក. $\mathbf{f(x)=(7x+2)^2}$

$$\mathbf{f'(x)=2(7x+2)'(7x+2)=14(7x+2)}$$

ខ. $\mathbf{g(x)=(x^2-8)^{-1}}$

$$\mathbf{g'(x)=-(x^2-8)'(x^2-8)^{-2}}$$
$$\mathbf{=-2x(x^2-8)^{-2}}$$

គ. $\mathbf{y=(4x^2+9x-2)^3}$

$$\mathbf{y'=3(4x^2+9x-2)'(4x^2+9x-2)^2}$$
$$\mathbf{=3(8x+9)(4x^2+9x-2)^2}$$

ឃ. $f(x)=\sqrt[3]{5x^3-4}=(5x^3-4)^{\frac{1}{3}}$

$$f'(x)=\frac{1}{3}(5x^3-4)'(5x^3-4)^{\frac{1}{3}-1}$$

$$=5x^2(5x^3-4)^{-\frac{2}{3}}$$

ង. $g(x)=x(4-3x^2)^2$

$$g'(x)=(x)'(4-3x^2)^2+x((4-3x^2)^2)'$$

$$=(4-3x^2)^2-12x^2(4-3x^2)$$

$$=(4-3x^2)(4-15x^2)$$

ច. $y=\dfrac{\sqrt{5x-2}}{x^3}$

$$y'=\frac{(\sqrt{5x-2})'x^3-(x^3)'\sqrt{5x-2}}{x^6}$$

$$=\frac{\dfrac{5x^3}{2\sqrt{5x-2}}-3x^2\sqrt{5x-2}}{x^6}$$

$$=\frac{5x-6(5x-2)}{x^4\sqrt{5x-2}}$$

$$=\frac{5x-30x+12}{x^4\sqrt{5x-2}}$$

$$=\frac{-25x+12}{x^4\sqrt{5x-2}}$$

2-គណនាដេរីវេនៃអនុគមន៍ខាងក្រោម

ក. $y = x^3 \sin 2x$

ខ. $y = 3x^3 - x\cos 3x$

គ. $y = -x\cos(4-3x^2)$

ឃ. $f(x) = \dfrac{\sin^2 3x}{x^2}$

ង. $f(x) = \dfrac{\tan 2x}{x^2-1}$

ច. $f(x) = \cos(\sin^2 3x)$

## ដំណោះស្រាយ

គណនាដេរីវេនៃអនុគមន៍

ក. $y = x^3 \sin 2x$

$$y' = 3x^2 \sin 2x + 2x^3 \cos 2x$$

$$= x^2(3\sin 2x + 2x\cos x)$$

ខ. $y = 3x^3 - x\cos 3x$

$$y' = 9x^2 - \cos 3x + 3x\sin 3x$$

គ. $y = -x\cos(4-3x^2)$

$$y' = -\cos(4-3x^2) - 6x^2\sin(4-3x^2)$$

ឃ. $f(x) = \dfrac{\sin^2 3x}{x^2}$

$$f'(x) = \frac{6x^2 \sin 3x\cos 3x - 2x\sin^2 3x}{x^4} = \frac{3x\sin 6x - 2\sin 3x}{x^3}$$

ឃ. $f(x) = \dfrac{\tan 2x}{x^2 - 1}$

$$f'(x) = \dfrac{\dfrac{2(x^2-1)}{\cos^2 2x} - 2x\tan 2x}{(x^2-1)^2}$$

$$= \dfrac{2(x^2-1) - x\sin 4x}{(x^2-1)^2\cos^2 2x}$$

ច. $f(x) = \cos(\sin^2 3x)$

$$f'(x) = -(\sin^2 3x)'\sin(\sin^2 3x)$$

$$= -6\sin 3x\cos 3x\sin(\sin^2 3x)$$

$$= -3\sin 6x\sin(\sin^2 3x)$$

3-គណនាដេរីវេទី2នៃអនុគមន៍ខាងក្រោម

ក. $f(x) = x^3 - 4x^2 - x + 8$ ខ. $f(x) = x^4 + 6x^{\frac{3}{2}} - 9$

គ. $f(x) = (2x^2 + 7)^{\frac{2}{3}}$ ឃ. $f(x) = 5x + \dfrac{2}{x+1}$

ង. $f(x) = x^2 - \dfrac{14}{x-2}$ ច. $f(x) = \dfrac{7x+2}{x^3}$

## ដំណោះស្រាយ

គណនាដេរីវេទី2នៃអនុគមន៍

ក. $f(x) = x^3 - 4x^2 - x + 8$

គេបាន $f'(x) = 3x^2 - 8x - 1$

និង $f''(x) = 6x - 8 = 2(3x - 4)$

ខ. $f(x) = x^4 + 6x^{\frac{3}{2}} - 9$

គេបាន $f'(x) = 4x^3 + 9x^{\frac{1}{2}}$

និង $f''(x) = 12x^2 + \dfrac{9}{2}x^{-\frac{1}{2}}$

គ. $f(x)=(2x^2+7)^{\frac{2}{3}}$

គេបាន $f'(x)=\frac{2}{3}(2x^2+7)'(2x^2+7)^{-\frac{1}{3}}$

$=\frac{8x}{3}(2x^2+7)^{-\frac{1}{3}}$

ហើយ $f''(x)=\frac{8}{3}(2x^2+7)^{-\frac{1}{3}}-\frac{8x}{9}(2x^2+7)'(2x^2+7)^{-\frac{4}{3}}$

$=\frac{8}{3}(2x^2+7)^{-\frac{1}{3}}-\frac{32x^2}{9}(2x^2+7)^{-\frac{4}{3}}$

ឃ. $f(x)=5x+\frac{2}{x+1}$

គេបាន $f'(x)=5-\frac{2}{(x+1)^2}$

និង $f''(x)=\frac{4}{(x+1)^3}$

ង. $f(x)=x^2-\frac{14}{x-2}$

គេបាន $f'(x)=2x+\frac{14}{(x-2)^2}$

និង $f''(x)=2-\frac{28}{(x-2)^3}$

ច. $f(x)=\frac{7x+2}{x^3}=7x^{-2}+2x^{-3}$

គេបាន $f'(x)=-14x^{-3}-6x^{-4}$ និង $f''(x)=42x^{-4}+24x^{-5}$ ។

4-រក $\mathbf{y'}$ ជាអនុគមន៍នៃ $\mathbf{x}$ និង $\mathbf{y}$

ក. $\mathbf{x^3 + y^3 = 5}$ ខ. $\mathbf{xy^2 = -1}$

គ. $\mathbf{x - \sqrt{y} = 2}$ ឃ. $\mathbf{2y + \sqrt{xy} = 5x^2}$

ង. $\mathbf{x^2 + 4(y+3)^2 = 9}$ ច. $\mathbf{x^3y + xy^3 = 3x^3}$

## ដំណោះស្រាយ

រក $\mathbf{y'}$ ជាអនុគមន៍នៃ $\mathbf{x}$ និង $\mathbf{y}$

ក. $\mathbf{x^3 + y^3 = 5}$

គេបាន $\mathbf{(x^3 + y^3)' = (5)'}$

$$\mathbf{3x^2 + 3y'y^2 = 0}$$

គេទាញ $\mathbf{y' = -\dfrac{x^2}{y^2}}$ ។

ខ. $\mathbf{xy^2 = -1}$

គេបាន $\mathbf{(xy^2)' = (-1)'}$

$$\mathbf{y^2 + 2xy'y = 0}$$

គេទាញ $\mathbf{y' = -\dfrac{y^2}{2xy}}$ ។

គ. $\mathbf{x-\sqrt{y}=2}$

គេបាន $\mathbf{(x-\sqrt{y})'=(2)'}$

$$\mathbf{1-\frac{y'}{2\sqrt{y}}=0}$$

គេទាញ $\mathbf{y'=2\sqrt{y}}$ ។

ឃ. $\mathbf{2y+\sqrt{xy}=5x^2}$

គេបាន $\mathbf{(2y+\sqrt{xy})'=(5x^2)'}$

$$\mathbf{2y'+\frac{(xy)'}{2\sqrt{xy}}=10x}$$

$$\mathbf{2y'+\frac{y+xy'}{2\sqrt{xy}}=10x}$$

គេទាញ $\mathbf{y'=\dfrac{20x\sqrt{xy}-y}{x+4\sqrt{xy}}}$ ។

ង. $\mathbf{x^2+4(y+3)^2=9}$

គេបាន $\mathbf{2x+8y'(y+3)=0\Rightarrow y'=-\dfrac{x}{4(y+3)}}$ ។

ច. $\mathbf{x^3y+xy^3=3x^3}$

គេបាន $\mathbf{3x^2y+x^3y'+y^3+3xy'y^2=9x^2}$

គេទាញ $\mathbf{y'=\dfrac{9x^2-3x^2y-y^3}{x^3+3xy^2}}$ ។

5-រក $y'$ និង $y''$ ជាអនុគមន៍នៃ $x$ និង $y$

ក. $x^2 + xy = 5$

ខ. $x^2y^2 - 2x = 3$

គ. $x^2 - y^2 = 16$

ឃ. $1 - xy = x - y$

ង. $y^2 = x^3$

ច. $y^2 = 4x$

## ដំណោះស្រាយ

រក $y'$ និង $y''$ ជាអនុគមន៍នៃ $x$ និង $y$

ក. $x^2 + xy = 5$

គេបាន $2x + y + xy' = 0$

ហើយ $2 + y' + y' + xy'' = 0$

គេទាញ $y'' = -\dfrac{2(1+y')}{x}$

ដោយ $2x + y + xy' = 0 \Rightarrow y' = -\dfrac{2x+y}{x}$

គេបាន $y'' = -\dfrac{2(1-\frac{2x+y}{x})}{x} = \dfrac{2(x+y)}{x^2}$

ដូចនេះ $y'' = \dfrac{2(x+y)}{x^2}$ ។

ខ. $x^2y^2 - 2x = 3$

គេបាន $2xy^2 + 2x^2y'y - 2 = 0$

ឬ $xy^2 + x^2yy' - 1 = 0 \Rightarrow y' = \dfrac{1 - xy^2}{x^2y} = \dfrac{1}{x^2y} - \dfrac{y}{x}$

ហើយ $y'' = -\dfrac{2xy + x^2y'}{x^4y^2} - \dfrac{y'x - y}{x^2}$

$$= -\frac{2}{x^3y} - \frac{y'}{x^2y^2} - \frac{y'}{x} + \frac{y}{x^2}$$

$$= \frac{xy^2 - 2}{x^3y} - \frac{xy^2 + 1}{x^2y^2}y'$$

$$= \frac{xy^2 - 2}{x^3y} - \frac{xy^2 + 1}{x^2y^2} \cdot \frac{1 - xy^2}{x^2y}$$

$$= \frac{xy^2 - 2}{x^3y} - \frac{1 - x^2y^4}{x^4y^3}$$

$$= \frac{x^2y^4 - 2xy^2 - 1 + x^2y^4}{x^4y^3} = \frac{2x^2y^4 - 2xy^2 - 1}{x^4y^3}$$

ដូចនេះ $y'' = \dfrac{2x^2y^4 - 2xy^2 - 1}{x^4y^3}$ ។

គ. $x^2 - y^2 = 16$

គេបាន $2x - 2y'y = 0 \Rightarrow y' = \dfrac{x}{y}$

ហើយ $y''=\frac{y-xy'}{y^2}=\frac{y-\frac{x^2}{y}}{y^2}=\frac{y^2-x^2}{y^3}$ ។

ឃ. $1-xy=x-y$

គេបាន $-y-xy'=1-y'\Rightarrow y'=\frac{1+y}{1-x}$

ហើយ $y''=\frac{y'(1-x)+1+y}{(1-x)^2}=\frac{(1-x)\frac{1+y}{1-x}+1+y}{(1-x)^2}$

ដូចនេះ $y''=\frac{2(1+y)}{(1-x)^2}$ ។

ង. $y^2=x^3$

គេបាន $2y'y=3x^2\Rightarrow y'=\frac{3x^2}{2y}$

ហើយ $2y''y+2y'^2=6x\Rightarrow y''=\frac{6x-2y'^2}{2y}$

ឬ $y''=\frac{6x-2.\frac{9x^4}{4y^2}}{2y}=\frac{12xy^2-9x^4}{8y^3}$ ។

ច. $y^2=4x$ នាំឱ្យ $2yy'=4\Rightarrow y'=\frac{2}{y}$

ហើយ $y''=-\frac{2y'}{y^2}=-\frac{4}{4xy}=-\frac{1}{xy}$ ។

6-ត្រីកោណសមបាត **ABC** មួយមានបរិមាត្រ **2p** វិលជុំវិញកម្ពស់ដែលគូសចេញពីកំពូល **A** កំនត់បានលូលីតមួយមានមាឌធំបំផុត ។ គណនារង្វាស់ជ្រុង និង កម្ពស់នៃត្រីកោណសមបាតនោះ ?

## ដំណោះស្រាយ

គណនាជ្រុង និង កម្ពស់នៃត្រីកោណសមបាត




តាង $\mathbf{AB = AC = x}$

និង $\mathbf{AH = h}$ ដែល $\mathbf{x > 0\ ;\ h > 0}$

គេបាន $\mathbf{2p = x + x + BC}$

ឬ $\mathbf{BC = 2(p - x)}$ ។

ត្រីកោណសមបាត **ABC** វិលជុំវិញកម្ពស់ **AH** បង្កើតបានជាសូលីដបរិវត្តន៍មួយគឺជាកោណដែលមានកម្ពស់ **AH** ជនេត្រ $\mathbf{AB = AC}$ និងថាសបាតជារង្វង់មានកាំ

$$\mathbf{BH = HC = \frac{BC}{2} = p - x} \quad ។$$

យក **V** ជាមាឌរបស់កោណ និង **S** ជាផ្ទៃក្រឡាថាសបាត ។

យើងបាន $V = \frac{1}{3} S \times h$

ដោយ $S = \pi (p - x)^2$

ក្នុងត្រីកោណកែង AHB គេមាន $AB^2 = AH^2 + HB^2$

គេទាញ $h^2 = x^2 - (p - x)^2 = 2px - p^2$

នាំឱ្យ $h = \sqrt{2px - p^2}$ ដែល $2px - p^2 > 0$ ឬ $x > \frac{p}{2}$ ។

គេបាន $V = \frac{\pi}{3}(p - x)^2 \sqrt{2px - p^2}$

យើងបាន $V' = \frac{\pi p}{3} \cdot \frac{5x^2 - 8px + 3p^2}{\sqrt{2px - p^2}}$

បើ $V' = 0 \Rightarrow x_1 = p$ ; $x_2 = \frac{3p}{5}$ ។

| $x$ | $\frac{p}{2}$ | | $\frac{3p}{5}$ | | $p$ |
|---|---|---|---|---|---|
| $V'(x)$ | | + | 0 | − | |
| $V(x)$ | ↗ | | អតិបរមា | ↘ | |

តាមតារាងអថេរភាពខាងលើ ជាមួយនឹងលក្ខខណ្ឌកំណត់គេបាន

$x=\frac{3p}{5}$ ជាតម្លៃដែលធ្វើឱ្យ $V$ មានតម្លៃអតិបរមា ។

ចំពោះ $x=\frac{3p}{5}\Rightarrow BC=2(p-\frac{3p}{5})=\frac{4p}{5}$

ហើយ $AH=h=\sqrt{2px-p^2}=\sqrt{\frac{6p^2}{5}-p^2}=\frac{p\sqrt{5}}{5}$

ដូចនេះ $AB=AC=\frac{3p}{5}$ , $BC=\frac{4p}{5}$ , $AH=\frac{p\sqrt{5}}{5}$ ។

7-រថយន្តមួយចាប់ផ្ដើមចេញដំណើរពីចំនុចត្រួតពិនិត្យមួយ ។ នៅខណៈ $t$ វិនាទីរថយន្តនោះឃ្លាតពីចំនុចត្រួតពិនិត្យដែលតាងដោយអនុគមន៍ចម្ងាយចរ $S(t)=4.4t^2$ គិតជាម៉ែត្រ ហើយ $0\le t\le 10$ ។

ប្រើអនុគមន៍ខាងលើរួចបំពេញតារាងខាងក្រោម

| $t$ | 0 | 2 | 4 | 6 | 8 | 10 |
|---|---|---|---|---|---|---|
| $S(t)$ | | | | | | |
| $V(t)$ | | | | | | |
| $a(t)$ | | | | | | |

## ដំណោះស្រាយ

បំពេញតារាង

គេមាន $\mathbf{S(t) = 4.4t^2}$ គិតជាម៉ែត្រ ហើយ $\mathbf{0 \le t \le 10}$

គេបាន $\mathbf{V(t) = S'(t) = 8.8t}$

និង $\mathbf{a(t) = S''(t) = 8.8}$ ថេរ ។

| **t** | 0 | 2 | 4 | 6 | 8 | 10 |
|---|---|---|---|---|---|---|
| **S(t)** | 0 | 17.6 | 70.4 | 158.4 | 281.6 | 440 |
| **V(t)** | 0 | 17.6 | 35.2 | 52.8 | 70.4 | 88 |
| **a(t)** | 8.8 | 8.8 | 8.8 | 8.8 | 8.8 | 8.8 |

*មេរៀនទី១*

# អនុគមន៍សនិទាន

**១_សិក្សាអនុគមន៍** $y = \dfrac{ax^2 + bx + c}{px + q}$

ដែល $p \neq 0$ , $a \neq 0$ និង $a{x_0}^2 + bx_0 + c \neq 0$ ចំពោះ $x_0 = -\dfrac{q}{p}$

◆ ដែនកំនត់ $D = IR - \{-\dfrac{q}{p}\}$

◆ ទិសដៅអថេរភាព

-ដេរីវេ $y' = \dfrac{apx^2 + 2aqx + bq - cp}{(px + q)^2}$

-បើ $y' = 0$ មានឫសពីរខុសគ្នានោះអនុគមន៏មានអតិបរមាធៀបមួយ និង អប្បបរមាធៀបមួយ ។

-បើ $y' = 0$ មានឫសឌុបនោះអនុគមន៏ក្លាយជាដឺក្រេទីមួយ

-បើ $y' = 0$ គ្មានឫសនោះអនុគមន៏គ្មានបរមាទេ

◆ អាស៊ីមតូត

-បន្ទាត់ $x = -\dfrac{q}{p}$ ជាអាស៊ីមតូតឈរ

-អនុគមន៍អាចសរសេរ $y=\alpha x+\beta+\dfrac{\gamma}{px+q}$

ដែល $\lim\limits_{x\to\infty}\dfrac{\gamma}{px+q}=0$ នោះបន្ទាត់ $y=\alpha x+\beta$ ជាអាស៊ីមតូតទ្រេត

◆ មានក្រាបជាអ៊ីពែបូលដែលមានផ្ចិតឆ្លុះជាចំនុចប្រសព្វរវាងអាស៊ីមតូទាំងពីរ ។

## ២_សិក្សាអនុគមន៍ $y=\dfrac{ax^2+bx+c}{px^2+qx+r}$

ដែល $p\neq 0$ , $a , b , c , p , q , r \in IR$ ។

◆ មានអាស៊ីមតូតដេកមួយជានិច្ច

◆ ចំនួនអាស៊ីមតូតឈរគឺអាស្រ័យនឹងឫសសមីការ $px^2+qx+r=0$

-បើ $\Delta=q^2-4pr<0$ គ្មានអាស៊ីមតូតឈរទេ និងក្រាបមានមែកតែមួយ ។

-បើ $\Delta=q^2-4pr=0$ មានអាស៊ីមតូតឈរមួយ $x=-\dfrac{q}{2p}$ និងក្រាបមានមែកពីរ ។

-បើ $\Delta=q^2-4pr>0$ មានអាស៊ីតូតឈរពីរគឺ $x=\dfrac{-q+\sqrt{\Delta}}{2p}$ និង $x=\dfrac{-q-\sqrt{\Delta}}{2p}$ ហើយក្រាបមានមែកបី ។

## លំហាត់ និង ដំណោះស្រាយ

1-រកអាស៊ីមតូតនៃអនុគមន៍ខាងក្រោម

ក. $y=\dfrac{x^2+4x+1}{x+2}$

ខ. $y=\dfrac{x^2+3x+1}{x^2-1}$

គ. $y=-x+3+\dfrac{3}{x-1}$

### ដំណោះស្រាយ

រកអាស៊ីមតូតនៃអនុគមន៍ខាងក្រោម

ក. $y=\dfrac{x^2+4x+1}{x+2}$

គេបាន $y=\dfrac{(x^2+2x)+(2x+4)-3}{x+2}$

$$=\frac{x(x+2)+2(x+2)-3}{x+2}=x+2-\frac{3}{x+2}$$

ដោយ $\lim\limits_{x\to 2} y=\lim\limits_{x\to 2}(x+2-\dfrac{3}{x+2})=\pm\infty$ នាំឱ្យបន្ទាត់ $x=-2$ ជាអាស៊ីមតូតឈរ ហើយ $\lim\limits_{x\to\pm\infty}\dfrac{3}{x+2}=0$ នាំឱ្យបន្ទាត់$y=x+2$ ជាអាស៊ីមតូតទ្រេត ។

ខ. $y = \dfrac{x^2 + 3x + 1}{x^2 - 1}$

គេមាន $y = \dfrac{x^2 + 3x + 1}{(x+1)(x-1)}$

ដោយ $\lim\limits_{x \to -1} \dfrac{x^2 + 3x + 1}{(x+1)(x-1)} = \pm\infty$ និង $\lim\limits_{x \to 1} \dfrac{x^2 + 3x + 1}{(x+1)(x-1)} = \pm\infty$

ដូចនេះបន្ទាត់ $x = -1$ , $x = 1$ ជាអាស៊ីមតូតឈរ ។

ហើយ $\lim\limits_{x \to \pm\infty} \dfrac{x^2 + 3x + 1}{x^2 - 1} = 1$ នាំឱ្យបន្ទាត់ $y = 1$ ជាអាស៊ីមតូតដេក

គ. $y = -x + 3 + \dfrac{3}{x-1}$

គេមាន $\lim\limits_{x \to 1}\left(-x + 3 + \dfrac{3}{x-1}\right) = \pm\infty$ នាំឱ្យបន្ទាត់ $x = 1$ ជាអាស៊ីមតូតឈរ និង $\lim\limits_{x \to \pm\infty} \dfrac{3}{x-1} = 0$ នាំឱ្យបន្ទាត់ $y = -x + 3$ ជាអាស៊ីមតូតទ្រេត ។

2-សិក្សាអថេរភាព និង សង់ក្រាបនៃអនុគមន៍ខាងក្រោម

ក. $y=\dfrac{x^2-2x+6}{2x+2}$

ខ. $y=\dfrac{x^2-4x+3}{x^2-3x+2}$

គ. $y=\dfrac{x^2-9}{4-x^2}$

**ដំណោះស្រាយ**

សិក្សាអថេរភាព និង សង់ក្រាបនៃអនុគមន៍ខាងក្រោម

ក. $y=\dfrac{x^2-2x+6}{2x+2}$

. ដែនកំណត់ $D=IR-\{-1\}$

. សរសេរជារាងកាណូនិច $y=\dfrac{x-3}{2}+\dfrac{9}{2x+2}$

. ទិសដៅអថេរភាព

-ដេរីវេ $y'=\dfrac{1}{2}-\dfrac{9}{2(x+1)^2}=\dfrac{(x+1)^2-9}{2(x+1)^2}=\dfrac{(x+4)(x-2)}{2(x+1)^2}$

បើ $y'=0\Rightarrow x_1=-4\ ,\ x_2=2$

-បរមានៃអនុគមន៍ y

ចំពោះ $x = -4$ អនុគមន៍មានអតិបរមាធៀប $y = f(-4) = -5$

ចំពោះ $x = 2$ អនុគមន៍មានអប្បបរមាធៀប $y = f(2) = 1$ ។

-គណនាលីមីត

$$\lim_{x \to \pm\infty}\left(\frac{x-3}{2} + \frac{9}{2x+2}\right) = \pm\infty$$

$$\lim_{x \to -1^-}\left(\frac{x-3}{2} + \frac{9}{2x+2}\right) = -\infty$$

$$\lim_{x \to -1^+}\left(\frac{x-3}{2} + \frac{9}{2x+2}\right) = +\infty$$

-អាស៊ីមតូត

ដោយ $\lim_{x \to -1}\left(\frac{x-3}{2} + \frac{9}{2x+2}\right) = \pm\infty$

នោះបន្ទាត់ $x = -1$ ជាអាស៊ីមតូតឈរ ។

ហើយ $\lim_{x \to \infty} \frac{9}{2x+2} = 0$ នោះបន្ទាត់ $y = \frac{x-3}{2}$ ជាអាស៊ីមតូតទ្រេត ។

-តារាងអថេរភាព

| x | $-\infty$ | | $-4$ | | $-1$ | | $2$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| y' | | + | 0 | − | ‖ | − | 0 | + | |
| y | $-\infty$ | ↗ | $-5$ | ↘ $-\infty$ | ‖ | $+\infty$ ↘ | $1$ | ↗ | $+\infty$ |

.សំណង់ក្រាប

-ចំណុចប្រសព្វរវាងក្រាបជាមួយអក្ស័កូអរដោនេ

បើ $x=0$ នោះ $y=3$ នាំឱ្យក្រាបកាត់អក្ស័ (oy) ត្រង់ $(0,3)$

បើ $y=0 \Rightarrow x^2-2x+6=(x-1)^2+5=0$ ( គ្មានឫស )

នាំឱ្យក្រាបមិនកាត់អក្ស័ (ox) ទេ ។

-ផ្ចិតឆ្លុះ

អាស៊ីមតូតឈរ $x=-1$ ប្រសព្វជាមួយអាស៊ីមតូតទ្រេត $y=\frac{x-3}{2}$

ត្រង់ចំនុច $I(-1\,,\,-2)$ គឺជាផ្ចិតឆ្លុះនៃក្រាបតាង $y=\frac{x^2-2x+6}{2x+2}$




ខ. $y = \dfrac{x^2 - 4x + 3}{x^2 - 3x + 2}$

.ដែនកំនត់ $D = IR - \{ 1 ; 2 \}$

. គេមាន $y = \dfrac{(x-1)(x-3)}{(x-1)(x-2)} = \dfrac{x-3}{x-2}$

.ទិសដៅអថេរភាព

-ដេរីវេ $y'=\dfrac{1}{(x-2)^2}>0$ នាំឱ្យ y ជាអនុគមន៍កើន ។

-គណនាលីមីត

$$\lim_{x\to\pm\infty}\frac{x-3}{x-2}=1 \quad \text{និង} \quad \lim_{x\to 2}\frac{x-3}{x-2}=\pm\infty$$

-អាស៊ីមតូត

ដោយ $\lim\limits_{x\to\pm\infty}\dfrac{x-3}{x-2}=1$ នាំឱ្យបន្ទាត់ $y=1$ ជាអសុីមតូតដេក

ហើយ $\lim\limits_{x\to 2}\dfrac{x-3}{x-2}=\pm\infty$ នាំឱ្យបន្ទាត់ $x=2$ ជាអសុីមតូតឈរ ។

-តារាងអថេរភាព

| x | $-\infty$ | | $2$ | | $+\infty$ |
|---|---|---|---|---|---|
| y' | | + | \|\| | + | |
| y | $1$ | ↗ | $+\infty$ \|\| $-\infty$ | ↗ | $1$ |

.សំណង់ក្រាប

-បើ $x=o$ នោះ $y=\dfrac{3}{2}$ នាំឱ្យក្រាបកាត់ $(oy)$ ត្រង់ $(0\ ,\ \dfrac{3}{2})$ ។

-បើ $y = 0 \Rightarrow x = 3$ នាំឱ្យក្រាបកាត់ (ox) ត្រង់ (3 ;0) ។

-ផ្ចិតឆ្លុះ

អាស៊ីមតូតឈរ $x = 2$ កាត់អាស៊ីមតូតដេក $y = 1$ ត្រង់ I(2 , 1 ) ជាផ្ចិតឆ្លុះនៃក្រាប ។



គ. $y = \dfrac{x^2 - 9}{4 - x^2}$

.ដែនកំណត់ $D = IR - \{ -2 ; 2 \}$

.ទិសដៅអថេរភាព

-ដេរីវេ $y' = \dfrac{-10x}{(4 - x^2)^2}$

-បើ $y' = 0 \Rightarrow x = 0$

-បរមានៃ $y = \dfrac{x^2 - 9}{4 - x^2}$

ចំពោះ $x = 0$ អនុគមន៍មានអតិបរមា $y = -\dfrac{9}{4}$

-គណនាលីមីត

$$\lim_{x \to \pm\infty} \frac{x^2 - 9}{4 - x^2} = \lim_{x \to \pm\infty} \frac{x^2}{-x^2} = -1$$

$$\lim_{x \to -2^-} \frac{x^2 - 9}{4 - x^2} = \lim_{x \to -2^-} \frac{x^2 - 9}{(2 - x)(2 + x)} = -\infty$$

$$\lim_{x \to -2^+} \frac{x^2 - 9}{4 - x^2} = \lim_{x \to -2^+} \frac{x^2 - 9}{(2 - x)(2 + x)} = +\infty$$

$$\lim_{x \to 2^-} \frac{x^2 - 9}{4 - x^2} = \lim_{x \to 2^-} \frac{x^2 - 9}{(2 - x)(2 + x)} = -\infty$$

$$\lim_{x \to 2^+} \frac{x^2 - 9}{4 - x^2} = \lim_{x \to 2^+} \frac{x^2 - 9}{(2 - x)(2 + x)} = +\infty$$

-អាស៊ីមតូត

ដោយ $\lim\limits_{x\to -2}\frac{x^2-9}{4-x^2}=\pm\infty$ និង $\lim\limits_{x\to 2}\frac{x^2-9}{4-x^2}=\pm\infty$

នាំឱ្យបន្ទាត់ $x=-2$ និង $x=2$ ជាអាស៊ីមតូតឈរ ។

ហើយ $\lim\limits_{x\to \pm\infty}\frac{x^2-9}{4-x^2}=-1$ នាំឱ្យបន្ទាត់ $y=-1$ ជាអាស៊ីមតូតដេក

-តារាងអថេរភាព




.សំណង់ក្រាប $y=\frac{x^2-9}{4-x^2}$

-កូអរដោនេចំនុចប្រសព្វរវាងក្រាបជាមួយអក្ស័កូអរដោនេ

បើ $x=0$ នោះ $y=-\frac{9}{4}$ នាំឱ្យក្រាប(c) កាត់អក្ស័(oy) ត្រង់ចំនុច

មានកូអរដោនេ $(0\,;-\frac{9}{4})$ ។

បើ $y = 0$ គេបាន $x^2 - 9 = 0 \Rightarrow x_1 = -3\ ,\ x_2 = 3$

ដូចនេះក្រាបកាត់ **(ox)** ត្រង់ $(-3, 0)$ និង $(3\ ,\ 0\ )$ ។

-អក្សឆ្លុះ

អនុគមន៍ $y = \dfrac{x^2 - 9}{4 - x^2}$ ជាអនុគមន៍គូ ។

ដូចនេះអក្ស **(oy)** ជាអក្សឆ្លុះរបស់ក្រាប ។



3-ក. សិក្សាអថេរភាព និង សង់ក្រាបនៃអនុគមន៍ $y=\frac{x^2-4x+8}{x-2}$

ខ. សិក្សាទៅតាមតម្លៃ $m$ អត្ថិភាព និង សញ្ញានៃឫសសមីការ

$x^2-(m+4)x+2m+8=0$ ដោយប្រើក្រាបតាង $y$ ។

**ដំណោះស្រាយ**

ក. សិក្សាអថេរភាព និង សង់ក្រាបនៃអនុគមន៍

$$y=\frac{x^2-4x+8}{x-2}$$

. ដែនកំណត់ $D=IR-\{2\}$

. សរសេរជារាងកាណូនិច $y=x-2+\frac{4}{x-2}$

. ទិសដៅអថេរភាព

-ដេរីវេ $y'=1-\frac{4}{(x-2)^2}=\frac{x(x-4)}{(x-2)^2}$

បើ $y'=0\Rightarrow x_1=0\ ,\ x_2=4$

-បរមានៃអនុគមន៍ $y$

ចំពោះ $x=0$ អនុគមន៍មានអតិបរមាធៀប $y=f(0)=-4$

ចំពោះ $x=4$ អនុគមន៍មានអប្បបរមាធៀប $y=f(4)=4$ ។

-គណនាលីមីត

$$\lim_{x\to\pm\infty}\left(x-2+\frac{4}{x-2}\right)=\pm\infty$$

$$\lim_{x\to 2^-}\left(x-2+\frac{4}{x-2}\right)=-\infty$$

$$\lim_{x\to 2^+}\left(x-2+\frac{4}{x-2}\right)=+\infty$$

-អាស៊ីមតូត

ដោយ $\lim_{x\to 2}\left(x-2+\frac{4}{x-2}\right)=\pm\infty$

នោះបន្ទាត់ $x=2$ ជាអាស៊ីមតូតឈរ ។

ហើយ $\lim_{x\to\infty}\frac{4}{x-2}=0$ នោះបន្ទាត់ $y=x-2$ ជាអាស៊ីមតូតទ្រេត ។

-តារាងអថេរភាព

| $x$ | $-\infty$ | | $0$ | | $2$ | | $4$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $y'$ | | $+$ | $0$ | $-$ | ‖ | $-$ | $0$ | $+$ | |
| $y$ | $-\infty$ | ↗ | $-4$ | ↘ $-\infty$ | ‖ | $+\infty$ ↘ | $4$ | ↗ | $+\infty$ |

.សំណង់ក្រាប

-ចំណុចប្រសព្វរវាងក្រាបជាមួយអក្ស័កូអរដោនេ

បើ $\mathbf{x = 0}$ នោះ $\mathbf{y = -4}$ នាំឱ្យក្រាបកាត់អក្ស័ **(oy)** ត្រង់ $\mathbf{(0, -4)}$

បើ $\mathbf{y = 0 \Rightarrow x^2 - 4x + 8 = (x-2)^2 + 4 = 0}$ ( គ្មានឫស )

នាំឱ្យក្រាបមិនកាត់អក្ស័ **(ox)** ទេ ។

-ផ្ចិតឆ្លុះ

អាស៊ីមតូតឈរ $\mathbf{x = 2}$ ប្រសព្វជាមួយអាស៊ីមតូតទ្រេត $\mathbf{y = x - 2}$

ត្រង់ចំនុច **I(2 , 0 )** គឺជាផ្ចិតឆ្លុះនៃក្រាបតាង $\mathbf{y = \dfrac{x^2 - 4x + 8}{x - 2}}$ ។



4-កំនត់តម្លៃ **a** ដើម្បីឱ្យអនុគមន៍ $y=\dfrac{x^2-2ax+3a^2}{x-2a}$

កើនលើចន្លោះ $(1\,,+\infty)$ ។

## ដំណោះស្រាយ

កំនត់តម្លៃ **a**

$$y=\frac{x^2-2ax+3a^2}{x-2a}$$

ដែនកំណត់ $D=IR-\{2a\}$

គេមាន $y=f(x)=\dfrac{x(x-2a)+3a^2}{x-2a}=x+\dfrac{3a^2}{x-2a}$

គេបាន $y'=f'(x)=1-\dfrac{3a^2}{(x-2a)^2}=\dfrac{(x-2a)^2-3a^2}{(x-2a)^2}$

ដើម្បីឱ្យអនុគមន៍ $y=\dfrac{x^2-2ax+3a^2}{x-2a}$ កើនលើចន្លោះ $(1\,,+\infty)$

លុះត្រាតែ $f'(x)>0$ ចំពោះគ្រប់ $x$ លើចន្លោះ $(1\,,+\infty)$ ពោលគឺ

គេត្រូវឱ្យ $(x-2a)^2-3a^2>0\ ,\ \forall x>1$ ។

5-គេឱ្យអនុគមន៍ $y = \frac{mx^2 + 3mx + 2m + 1}{x + 2}$

ក. ស្រាយបញ្ជាក់ថាអាស៊ីមតូតទ្រេតកាត់តាមចំនុចនឹងមួយចំពោះគ្រប់តម្លៃប៉ារ៉ាម៉ែត្រ $m$ ដែលត្រូវកំនត់កូអរដោនេ ។

ខ. រកតម្លៃ $m$ ដើម្បីឱ្យបន្ទាត់ $y = m$ ប៉ះនឹងក្រាប ។

គ. សិក្សាអថេរភាព និងសង់ក្រាបចំពោះ $m = -1$ ។

## ដំណោះស្រាយ

ក. ស្រាយបញ្ជាក់ថាអាស៊ីមតូតទ្រេតកាត់តាមចំនុចនឹងមួយ

គេមាន $y = \frac{mx^2 + 3mx + 2m + 1}{x + 2}$

ដែនកំនត់ $D = IR - \{-2\}$

អនុគមន៍អាចសរសេរ

$$y = \frac{(mx^2 + 2mx) + (mx + 2m) + 1}{x + 2}$$

$$= mx + m + \frac{1}{x + 2}$$

ដោយ $\lim\limits_{x \to \infty} \frac{1}{x + 2} = 0$ នាំឱ្យ $y = mx + m$ ជាអាស៊ីមតូតទ្រេត

ហើយដោយ $y = m(x+1)$ សមីការនេះផ្ទៀងផ្ទាត់គ្រប់ $m \in IR$

លុះត្រាតែ $x+1=0$ ឬ $x=-1$ និង $y=0$ ។

ដូចនេះអាស៊ីមតូតទ្រេតនៃក្រាបកាត់តាមចំនុចនឹង $I(-1\ ,\ 0\ )$ ចំពោះ

គ្រប់តម្លៃប៉ារ៉ាម៉ែត្រ $m$ ។

ខ. រកតម្លៃ $m$ ដើម្បីឱ្យបន្ទាត់ $y=m$ ប៉ះនឹងក្រាប

សមីការអាប់ស៊ីស

$$\frac{mx^2+3mx+2m+1}{x+2}=m$$

$$mx^2+3mx+2m+1=mx+2m$$

$$mx^2+2mx+1=0$$

$$\Delta'=m^2-m=m(m-1)$$

ដើម្បីឱ្យបន្ទាត់ $y=m$ ប៉ះនឹងក្រាបលុះត្រាតែ $\begin{cases} m\neq 0 \\ \Delta'=m(m-1)=0 \end{cases}$

គេទាញបាន $m=1$ ។

គ. សិក្សាអថេរភាព និងសង់ក្រាបចំពោះ $m=-1$

ចំពោះ $m=-1$ គេបាន $y=-x-1+\dfrac{1}{x+2}$

ដែនកំណត់ $D=IR-\{\ -2\ \}$ ។

. ទិសដៅអថេរភាព

-ដេរីវេ $y' = -1 - \frac{1}{(x+2)^2} = -\frac{(x+2)^2+1}{(x+2)^2} < 0$

នាំឱ្យអនុគមន៍ f ចុះជានិច្ចលើដែនកំណត់ នាំឱ្យវាគ្មានបរមាទេ ។

-គណនាលីមីត

$$\lim_{x \to \pm\infty}\left(-x-1+\frac{1}{x+2}\right) = \pm\infty$$

$$\lim_{x \to -2^-}\left(-x-1+\frac{1}{x+2}\right) = -\infty$$

$$\lim_{x \to -2^+}\left(-x-1+\frac{1}{x+2}\right) = +\infty$$

-អាស៊ីមតូត

ដោយ $\lim_{x \to -2}\left(-x-1+\frac{1}{x+2}\right) = \pm\infty$

នោះបន្ទាត់ $x = -2$ ជាអាស៊ីមតូតឈរ ។

ហើយ $\lim_{x \to \infty}\frac{1}{x+2} = 0$ នោះបន្ទាត់ $y = -x-1$ ជាអាស៊ីមតូតទ្រេត ។

-តារាងអថេរភាព

| $x$ | $-\infty$ | | $-2$ | | $+\infty$ |
|---|---|---|---|---|---|
| $y'$ | | $-$ | ‖ | $-$ | |
| $y$ | $+\infty$ ↘ | $-\infty$ | ‖ | $+\infty$ ↘ | $-\infty$ |

.សំណង់ក្រាប

-ចំណុចប្រសព្វរវាងក្រាបជាមួយអក្សកូអរដោនេ

បើ $x=0$ នោះ $y=-\frac{1}{2}$ នាំឱ្យក្រាបកាត់អក្ស $(oy)$ ត្រង់ $(0,-\frac{1}{2})$

បើ $y=0 \Rightarrow -x-1+\frac{1}{x+2}=0$

$$-x^2-3x-1=0$$

$$\Delta=9+4=5 \Rightarrow x_1=\frac{-3-\sqrt{5}}{2}\ ,\ x_2=\frac{-3+\sqrt{5}}{2}$$

-ផ្ចិតឆ្លុះ

អាស៊ីមតូតឈរ $x=-2$ ប្រសព្វជាមួយអាស៊ីមតូតទ្រេត $y=-x-1$

ត្រង់ចំនុច $I(-2\ ,\ 1\ )$ គឺជាផ្ចិតឆ្លុះនៃក្រាបតាង $y=-x-1+\frac{1}{x+2}$ ។




6-រកតម្លៃបរមាធៀបរបស់អនុគមន៍ $y=\dfrac{20x^2+10x+3}{3x^2+2x+1}$

**ដំណោះស្រាយ**

រកតម្លៃបរមាធៀប

$$y=\frac{20x^2+10x+3}{3x^2+2x+1}$$

ដែនកំណត់ $D = IR$

អនុគមន៍អាចសរសេរ $y(3x^2 + 2x + 1) = 20x^2 + 10x + 3$

ឬ $3x^2y + 2xy + y - 20x^2 - 10x - 3 = 0$

$$(3y - 20)x^2 + 2(y - 5)x + y - 3 = 0 \quad (E)$$

$$\begin{aligned}\Delta' &= (y-5)^2 - (y-3)(3y-20) \\ &= y^2 - 10y + 25 - 3y^2 + 20y + 9y - 60 \\ &= -2y^2 + 19y - 35\end{aligned}$$

បើ $\Delta' = 0 \Rightarrow -2y^2 + 19y - 35 = 0$

មានឬស $y_1 = 7$ ; $y_2 = \dfrac{5}{2}$ ។

ដើម្បីឱ្យអនុគមន៍ $y = \dfrac{20x^2 + 10x + 3}{3x^2 + 2x + 1}$ មានតម្លៃបរមាធៀបលុះត្រា

តែសមីការ (E) មានឬស ពោលគឺគេត្រូវឱ្យ $\Delta' = -2y^2 + 19y - 35 \geq 0$

គេទាញ $\dfrac{5}{2} \leq y \leq 7$ ។

ដូចនេះតម្លៃអតិបរមាធៀបគឺ 7 និងតម្លៃអប្បរមាធៀបគឺ $\dfrac{5}{2}$ ។

7- រកតម្លៃបរមាធៀបរបស់អនុគមន៍ $y = x^2 + 2x + 1 + \frac{a^2}{(x+1)^2}$

ដែល **a** ជាប៉ារ៉ាម៉ែត្រខុសពីសូន្យ ។

**ដំណោះស្រាយ**

រកតម្លៃបរមាធៀប

គេមាន $y = x^2 + 2x + 1 + \frac{a^2}{(x+1)^2} = (x+1)^2 + \frac{a^2}{(x+1)^2}$

តាមវិសមភាព មធ្យមនព្វន្ត-មធ្យមធរណីមាត្រគេបាន

$$y = (x+1)^2 + \frac{a^2}{(x+1)^2} \geq 2\sqrt{(x+1)^2 \times \frac{a^2}{(x+1)^2}} = 2|a|$$

ដូចនេះអនុគមន៍មានតម្លៃអប្បបរមាធៀបស្មើនឹង $2|a|$ ។

៨-សិក្សាអថេរភាព និង សង់ក្រាបនៃអនុគមន៍ $y = x + 1 + \frac{1}{x+1}$

## ដំណោះស្រាយ

សិក្សាអថេរភាព និង សង់ក្រាបនៃអនុគមន៍

$$y = x + 1 + \frac{1}{x+1}$$

. ដែនកំណត់ $D = IR - \{-1\}$

. ទិសដៅអថេរភាព

-ដេរីវេ $y' = 1 - \frac{1}{(x+1)^2} = \frac{x(x+2)}{(x+1)^2}$

បើ $y' = 0 \Rightarrow x_1 = 0$ , $x_2 = -2$

-បរមានៃអនុគមន៍ $y$

ចំពោះ $x = -2$ អនុគមន៍មានអតិបរមាធៀប $y = f(-2) = -2$

ចំពោះ $x = 0$ អនុគមន៍មានអប្បបរមាធៀប $y = f(0) = 2$ ។

-គណនាលីមីត

$$\lim_{x\to\pm\infty}\left(x+1+\frac{1}{x+1}\right)=\pm\infty$$

$$\lim_{x\to-1^-}\left(x+1+\frac{1}{x+1}\right)=-\infty$$

$$\lim_{x\to-1^+}\left(x+1+\frac{1}{x+1}\right)=+\infty$$

-អាស៊ីមតូត

ដោយ $\lim_{x\to-1}\left(x+1+\frac{1}{x+1}\right)=\pm\infty$

នោះបន្ទាត់ $x=-1$ ជាអាស៊ីមតូតឈរ ។

ហើយ $\lim_{x\to\infty}\frac{1}{x+1}=0$ នោះបន្ទាត់ $y=x+1$ ជាអាស៊ីមតូតទ្រេត ។

-តារាងអថេរភាព

| x | $-\infty$ | | $-2$ | | $-1$ | | $0$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| y' | | + | 0 | − | ‖ | − | 0 | + | |
| y | $-\infty$ | ↗ | $-2$ | ↘ | $-\infty$ ‖ $+\infty$ | ↘ | $2$ | ↗ | $+\infty$ |

.សំណង់ក្រាប

-ចំណុចប្រសព្វរវាងក្រាបជាមួយអក្ស័កូអរដោនេ

បើ $\mathbf{x = 0}$ នោះ $\mathbf{y = 2}$ នាំឱ្យក្រាបកាត់អក្ស័ **(oy)** ត្រង់ **(0, 2 )**

បើ $\mathbf{y = 0 \Rightarrow x + 1 + \frac{1}{x+1} = \frac{(x+1)^2 + 1}{x+1} = 0}$ ( គ្មានឫស )

នាំឱ្យក្រាបមិនកាត់អក្ស័ **(ox)** ទេ ។

-ផ្ចិតឆ្លុះ

អាស៊ីមតូតឈរ $\mathbf{x = -1}$ ប្រសព្វជាមួយអាស៊ីមតូតទ្រេត $\mathbf{y = x + 1}$ ត្រង់ចំនុច **I(–1 , 0 )** គឺជាផ្ចិតឆ្លុះនៃក្រាបតាង $\mathbf{y = x + 1 + \frac{1}{x+1}}$ ។



៩-គេឱ្យ $C_m$ ជាក្រាបតាងអនុគមន៍ $y = x + 1 + \frac{4}{(x+m)^2}$

ក.តើមានក្រាប $C_m$ ចំនួនប៉ុន្មានដែលកាត់តាមចំនុច $A(1\ ,\ 3\ )$

ខ. ស្រាយបញ្ជាក់ថា បន្ទាត់ប៉ះក្រាប $C_m$ ត្រង់ចំនុចមានអាប់ស៊ីស $x = 2 - m$ ស្របនឹងអក្ស័ $ox$ ។

**ដំណោះស្រាយ**

ក.តើមានក្រាប $C_m$ ចំនួនប៉ុន្មានដែលកាត់តាមចំនុច $A(1\ ,\ 3\ )$

យកកូអរដោនេនៃចំនុច $A$ ផ្ទៀងផ្ទាត់ក្នុងសមីការ $C_m$ គេបាន

$$3 = 2 + \frac{4}{(m+1)^2} \Rightarrow (m+1)^2 = 4$$

គេទាញបាន $m_1 = -3\ ,\ m_2 = 1$ ។

ដូចនេះមានក្រាប $C_m$ ពីរដែលកាត់តាម$A(1\ ,\ 3\ )$ មានសមីការរៀងគ្នា

$$y = x + 1 + \frac{4}{(x-3)^2} \quad \text{និង} \quad y = x + 1 + \frac{4}{(x+1)^2}$$

ខ. ស្រាយបញ្ជាក់ថា បន្ទាត់ប៉ះក្រាប $C_m$ ត្រង់ចំនុចមានអាប់ស៊ីស $x = 2 - m$ ស្របនឹងអក្ស័ $ox$

គេមាន $y = x + 1 + \frac{4}{(x+m)^2}$

ដែនកំនត់ $D = IR - \{-m\}$

ដេរីវេ $y' = 1 - \frac{8}{(x+m)^3}$

មេគុណប្រាប់ទិសនៃបន្ទាត់ប៉ះ $C_m$ ត្រង់ $x = 2-m$ គឺជាចំនួនដេរីវេ

ត្រង់ $x = 2-m$ ដែលកំណត់ដោយ $a = f'(2-m)$ ។

គេបាន $a = f(2-m) = 1 - \frac{8}{(2-m+m)^3} = 1 - 1 = 0$

លទ្ធផលនេះបញ្ជាក់ថា បន្ទាត់ប៉ះក្រាប $C_m$ ត្រង់ចំនុចមានអាប់ស៊ីស

$x = 2-m$ ស្របនឹងអក្ស័ $ox$ ។

មេរៀនទី២

# អនុគមន៍អិចស្ប៉ូណង់ស្យែល

- ចំនួន e ឬគោល e ដែលគេនិយមប្រើមានតម្លៃ $e = 2.718281$

  ដែល $e = \lim_{n \to +\infty} \left(1 + \frac{1}{n}\right)^n$ ។

- អនុគមន៍ $f(x) = e^x$ ហៅថាអនុគមន៍អិុស្ប៉ូណង់ស្យែលគោល e ។

- ដេរីវេ

  -បើ $y = e^x$ នោះ $y' = e^x$

  -បើ $y = e^{u(x)}$ នោះ $y' = u'(x).e^{u(x)}$

- ក្រាបនៃអនុគមន៍ $y = e^x$



## លំហាត់ និង ដំណោះស្រាយ

1-គណនាលីមីតខាងក្រោម

ក. $\lim_{x \to +\infty} e^{3x}$

ខ. $\lim_{x \to -\infty} e^{5x}$

គ. $\lim_{x \to +\infty} 6e^{2x}$

**ដំណោះស្រាយ**

ក. $\lim_{x \to +\infty} e^{3x} = +\infty$

ខ. $\lim_{x \to -\infty} e^{5x} = 0$

គ. $\lim_{x \to +\infty} 6e^{2x} = 6 \lim_{x \to +\infty} e^{2x} = +\infty$

2-គណនាលីមីតខាងក្រោម

ក. $\lim_{x\to+\infty} xe^{x+1}$

ខ. $\lim_{x\to-\infty} x^2e^{4x}$

គ. $\lim_{x\to+\infty} (1+\frac{n}{x})^x$

## ដំណោះស្រាយ

គណនាលីមីតខាងក្រោម

ក. $\lim_{x\to+\infty} xe^{x+1} = e\lim_{x\to+\infty}(x)\times\lim_{x\to+\infty} e^x = +\infty$

ព្រោះ $\lim_{x\to+\infty} x = +\infty$ និង $\lim_{x\to+\infty} e^x = +\infty$

ខ. $\lim_{x\to-\infty} x^2e^{4x} = 0$ ព្រោះ $\lim_{x\to-\infty} e^{4x} = 0$ ។

គ. $\lim_{x\to+\infty} (1+\frac{n}{x})^x = \lim_{x\to+\infty}\left[\left(1+\frac{n}{x}\right)^{\frac{x}{n}}\right]^n = e^n$

ព្រោះ $\lim_{x\to+\infty}\left(1+\frac{n}{x}\right)^{\frac{x}{n}} = e$ ។

3-គណនាលីមីតខាងក្រោម

ក. $\lim\limits_{x\to+\infty} \dfrac{3e^{x-2}}{x^3}$

ខ. $\lim\limits_{x\to+\infty} \left(\dfrac{x+3}{x-1}\right)^{x+2}$

គ. $\lim\limits_{x\to 0} \left(\dfrac{e^x - e^{-x}}{x}\right)$

## ដំណោះស្រាយ

គណនាលីមីតខាងក្រោម

ក. $\lim\limits_{x\to+\infty} \dfrac{3e^{x-2}}{x^3} = \dfrac{3}{e^2} \lim\limits_{x\to+\infty} \dfrac{e^x}{x^3} = +\infty$

ខ. $\lim\limits_{x\to+\infty} \left(\dfrac{x+3}{x-1}\right)^{x+2} = \lim\limits_{x\to+\infty} \left(1 + \dfrac{4}{x-1}\right)^{x+2}$

$$= \lim_{x\to+\infty} \left[\left(1+\frac{4}{x-1}\right)^{\frac{x-1}{4}}\right]^{\frac{4(x+2)}{x-1}} = e^4$$

ព្រោះ $\lim\limits_{x\to+\infty} \left(1+\dfrac{4}{x-1}\right)^{\frac{x-1}{4}} = e$ និង $\lim\limits_{x\to+\infty} \dfrac{4(x+2)}{x-1} = 4$ ។

គ. $\lim_{x\to 0}\left(\frac{e^x - e^{-x}}{x}\right) = \lim_{x\to 0}\frac{e^{2x}-1}{xe^x}$

$$= \lim_{x\to 0}\frac{e^{2x}-1}{2x}\cdot\frac{2}{e^x} = 2$$

ដូចនេះ $\lim_{x\to 0}\left(\frac{e^x - e^{-x}}{x}\right) = 2$ ។

4-គណនាដេរីវេខាងក្រោម

ក. $y = xe^{-x}$

ខ. $f(x) = x^2e^x$

គ. $g(x) = \frac{e^x - e^{-x}}{e^x + e^{-x}}$

## ដំណោះស្រាយ

គណនាដេរីវេខាងក្រោម

ក. $y = xe^{-x}$

គេបាន $y' = e^{-x} - xe^{-x} = (1-x)e^{-x}$

ដូចនេះ $y' = (1-x)e^{-x}$ ។

ខ. $f(x)=x^2e^x$

គេបាន $f'(x)=2xe^x+x^2e^x=x(2+x)e^x$

ដូចនេះ $f'(x)=x(x+2)e^x$ ។

គ. $g(x)=\dfrac{e^x-e^{-x}}{e^x+e^{-x}}$

គេបាន $$g'(x)=\frac{(e^x+e^{-x})^2-(e^x-e^{-x})^2}{(e^x+e^{-x})^2}$$

$$=\frac{e^{2x}+2+e^{-2x}-e^{2x}+2-e^{-2x}}{(e^x+e^{-x})^2}$$

$$=\frac{4}{(e^x+e^{-x})^2}$$

5-គណនាដេរីវេខាងក្រោម

ក. $y=\dfrac{e^x+e^{-x}}{2}$

ខ. $f(x)=\dfrac{e^x(1+\cos x)}{1-\cos x}$

គ. $g(x)=e^{\frac{x-1}{x+1}}$

## ដំណោះស្រាយ

គណនាដេរីវេខាងក្រោម

ក. $\mathbf{y = \frac{e^x + e^{-x}}{2}}$

គេបាន $\mathbf{y' = \frac{e^x - e^{-x}}{2}}$

ខ. $\mathbf{f(x) = \frac{e^x(1+\cos x)}{1-\cos x}}$

គេបាន

$$\mathbf{f'(x) = \frac{e^x(1-\cos^2 x) - e^x \sin x(1-\cos x) - \sin x e^x(1-\cos x)}{(1-\cos x)^2}}$$

$$\mathbf{= \frac{e^x(\sin^2 x - \sin x + \sin x\cos x - \sin x + \sin x \cos x)}{(1-\cos x)^2}}$$

$$\mathbf{= \frac{(\sin x + 2\cos x - 2)\sin x e^x}{(1-\cos x)^2}}$$

គ. $\mathbf{g(x) = e^{\frac{x-1}{x+1}}}$

គេបាន $\mathbf{g'(x) = \left(\frac{x-1}{x+1}\right)' e^{\frac{x-1}{x+1}} = \frac{2}{(x+1)^2} e^{\frac{x-1}{x+1}}}$

ដូចនេះ $\mathbf{g'(x) = \frac{2}{(x+1)^2} e^{\frac{x-1}{x+1}}}$ ។

6-សិក្សាអថេរភាព និង សង់ក្រាបនៃអនុគមន៍ខាងក្រោម

ក. $y = x^2e^{-x}$

ខ. $y = 5 + 2e^{-x}$

គ. $g(x) = e^x - x^2$

**ដំណោះស្រាយ**

សិក្សាអថេរភាព និង សង់ក្រាបនៃអនុគមន៍ខាងក្រោម

ក. $y = x^2e^{-x}$

.ដែនកំណត់ $D = IR$

.ទិសដៅអថេរភាព

-ដេរីវេ $y' = 2xe^{-x} - x^2e^{-x} = x(2-x)e^{-x}$

-បើ $y' = 0 \Rightarrow x_1 = 0 \; ; \; x_2 = 2$

ចំពោះ $x = 0$ អនុគមន៍មានអប្បបរមាធៀប $y = f(0) = 0$

ចំពោះ $x = 2$ អនុគមន៍មានអតិបរមាធៀប $y = \frac{4}{e^2}$

-គណនាលីមីត

$\lim\limits_{x \to -\infty} x^2e^{-x} = +\infty$ និង $\lim\limits_{x \to +\infty} x^2e^{-x} = 0$

-អាស៊ីមតូត

ដោយ $\lim\limits_{x\to+\infty} x^2e^{-x}=0$ នាំឱ្យបន្ទាត់ $y=0$ ជាអាស៊ីមតូតដេក ។

-តារាងអថេរភាព

| $x$ | $-\infty$ | | $0$ | | $2$ | | $+\infty$ |
|---|---|---|---|---|---|---|---|
| $y'$ | | $-$ | $0$ | $+$ | $0$ | $-$ | |
| $y$ | $+\infty$ | ↘ | $0$ | ↗ | $\frac{4}{e^2}$ | ↘ | $-\infty$ |

.សំណង់ក្រាប $(C): y=x^2e^{-x}$



ខ. $y = 5 + 2e^{-x}$

.ដែនកំណត់ $D = IR$

.ទិសដៅអថេរភាព

-ដេរីវេ $y' = -2e^{-x} < 0$ , $\forall x \in IR$

**នាំឱ្យអនុគមន៍ f ចុះជានិច្ច ។ នាំឱ្យអនុគមន៍គ្មានចំនុចបរមាធៀបទេ ។**

**-គណនាលីមីត**

$\lim_{x \to -\infty}(5 + 2e^{-x}) = +\infty$ និង $\lim_{x \to +\infty}(5 + 2e^{-x}) = 5$

-អាស៊ីមតូត

ដោយ $\lim_{x \to +\infty}(5 + 2e^{-x}) = 5$ នាំឱ្យបន្ទាត់ $y = 5$ ជាអាស៊ីមតូតដេក ។

-តារាងអថេរភាព

| | | |
|---|---|---|
| $x$ | $-\infty$ | $+\infty$ |
| $y'$ | $-$ | |
| $y$ | $+\infty$ ↘ | $5$ |

.សំណង់ក្រាប $(C): y = 5 + 2e^{-x}$




គ. $g(x) = e^{x} - x^{2}$



7-សិក្សាអថេរភាព និង សង់ក្រាបនៃអនុគមន៍ខាងក្រោម

ក. $f(x)=\dfrac{1}{2-e^{-x}}$

ខ. $g(x)=\dfrac{e^{x}}{x^{2}}$

គ. $g(x)=\dfrac{x}{e^{x}}$

**ដំណោះស្រាយ**

សិក្សាអថេរភាព និង សង់ក្រាបនៃអនុគមន៍ខាងក្រោម

ក. $f(x)=\dfrac{1}{2-e^{-x}}$

.ដែនកំណត់ $D=IR-\{-\ln 2\}$

.ទិសដៅអថេរភាព

-ដេរីវេ $y'=-\dfrac{e^{-x}}{(2-e^{-x})^{2}}<0$

នាំឱ្យអនុគមន៍ $f$ ចុះជានិច្ច ។ នាំឱ្យអនុគមន៍គ្មានចំនុចបរមាធៀបទេ ។

-គណនាលីមីត

$\lim\limits_{x\to-\infty}\dfrac{1}{2-e^{-x}}=0$ និង $\lim\limits_{x\to+\infty}\dfrac{1}{2-e^{-x}}=\dfrac{1}{2}$

-អាស៊ីមតូត ដោយ $\lim\limits_{x\to-\infty}\dfrac{1}{2-e^{-x}}=0$ និង $\lim\limits_{x\to+\infty}\dfrac{1}{2-e^{-x}}=\dfrac{1}{2}$

នាំឱ្យ $y=0$ និង $y=\dfrac{1}{2}$ ជាអាស៊ីមតូតដេកនៃក្រាប ។

-តារាងអថេរភាព

| x | $-\infty$ | | $-\ln 2$ | | $+\infty$ |
|---|---|---|---|---|---|
| y' | | $-$ | ‖ | $-$ | |
| y | $0$ ↘ | $-\infty$ | ‖ | $+\infty$ ↘ | $\frac{1}{2}$ |

.សំណង់ក្រាប $(C): y=\dfrac{1}{2-e^{-x}}$



ខ. $g(x)=\frac{e^x}{x^2}$




គ. $g(x)=\frac{x}{e^x}$



៨-ឧបមាថាគេយកប្រាក់ **5000** ដុល្លា ទៅផ្ញើនៅធនាគារមួយដោយទទួលបានអត្រាការប្រាក់សមាស **11%** ក្នុងមួយឆ្នាំ ។
បើគេផ្ញើរយៈពេល 10 ឆ្នាំ តើគេទទួលបានប្រាក់សរុបទាំងអស់ចំនួនប៉ុន្មានបើការទូទាត់ច្រើនដងក្នុងមួយឆ្នាំ ?

**ដំណោះស្រាយ**

គណនាប្រាក់សរុបដែលគេទទួលបាន

ដោយការទូទាត់មានច្រើនដងក្នុងមួយឆ្នាំនោះតាមរូបមន្ត

$\mathbf{A = p\,e^{r.t}}$ ដែល **A :** ជាប្រាក់សរុប

**p :** ជាប្រាក់ដើម

**r :** ជាអត្រាការប្រាក់សមាស

**t :** ជារយៈពេលដាក់ប្រាក់សន្សំ

គេបាន $\mathbf{A = 5000 \times (2.718)^{(0.11)(10)} = 15019}$ ដុល្លា ។

មេរៀនទី៣

# អនុគមន៍លោការីត

◆ លោការីតនេពែនៃចំនួនវិជ្ជមាន $k$ គឺជានិទស្សន្ត $x$ នៃ $e$ ដែល $e^x = k$

គេកំនត់សរសេរ $x = \ln k$ ហើយ $x = \ln k \Leftrightarrow e^x = k$ ។

◆ អនុគមន៍ $f(x) = \ln x$ ហៅថាអនុគមន៍លោការីតនេពែនៃ $x > 0$ ។

◆ លីមីត

1. $\lim\limits_{x \to 0^+} \ln x = -\infty$

2. $\lim\limits_{x \to 0^+} x^n \ln x = 0$ , $n > 0$

3. $\lim\limits_{x \to +\infty} \ln x = +\infty$

4. $\lim\limits_{x \to +\infty} \dfrac{\ln x}{x^n} = +\infty$

◆ ដេរីវេ

-បើ $y = \ln x$ នោះ $y' = \dfrac{1}{x}$

-បើ $y = \ln u(x)$ នោះ $y' = \dfrac{u'(x)}{u(x)}$

◆ ក្រាបនៃអនុគមន៍ $y = \ln x$



## លំហាត់ និង ដំណោះស្រាយ

1-គណនាតម្លៃនៃកន្សោមខាងក្រោម

ក. $e^{\ln 7}$

ខ. $\ln e^{x-2}$

គ. $\ln e^{7x}$

### ដំណោះស្រាយ

គណនាតម្លៃនៃកន្សោមខាងក្រោម

ក. $e^{\ln 7} = 7$

ខ. $\ln e^{x-2} = x - 2$

គ. $\ln e^{7x} = 7x$

2-សង់ក្រាបនៃអនុគមន៍ខាងក្រោម

ក. $y = 3 - \ln x$

ខ. $y = \ln(x-3)$

គ. $y = \ln(2+e^x)$

**ដំណោះស្រាយ**

សង់ក្រាបនៃអនុគមន៍ខាងក្រោម

ក. $y = 3 - \ln x$

.ដែនកំណត់ $D = (\ 0\ ;+\infty\ )$

.ទិសដៅអថេរភាព

-ដេរីវេ $y' = -\frac{1}{x} < 0\ \forall x \in (0,+\infty)$

នាំឱ្យវាជាអនុគមន៍ចុះជានិច្ចលើដែនកំនត់ និងគ្មានចំនុចបរមាធៀបទេ ។

-គណនាលីមីត

$\lim\limits_{x\to+\infty}(3-\ln x) = -\infty$ និង $\lim\limits_{x\to0^+}(3-\ln x) = +\infty$

-អាស៊ីមតូត

ដោយ $\lim\limits_{x\to0^+}(3-\ln x) = +\infty$ នាំឱ្យអក្ស៊ (oy) ជាអាស៊ីមតូតឈរ ។

-តារាងអថេរភាព

| x | $0$ | | $+\infty$ |
| --- | --- | --- | --- |
| y' | | $-$ | |
| y | $+\infty$ | ↘ | $-\infty$ |

.សំណង់ក្រាប $\mathbf{y = 3 - \ln x}$



ខ. $y = \ln(x-3)$




គ. $y = \ln(2+e^x)$



3-គណនាលីមីតនៃអនុគមន៍ខាងក្រោម

ក. $\lim\limits_{x\to+\infty} x^{-5}\ln x$

ខ. $\lim\limits_{x\to+\infty} \dfrac{1+\ln x}{x^2}$

គ. $\lim\limits_{x\to 0} x\ln x$

## ដំណោះស្រាយ

គណនាលីមីតនៃអនុគមន៍ខាងក្រោម

ក. $\lim\limits_{x\to+\infty} x^{-5}\ln x = \lim\limits_{x\to+\infty} \dfrac{\ln x}{x^5} = 0$

ខ. $\lim\limits_{x\to+\infty} \dfrac{1+\ln x}{x^2} = \lim\limits_{x\to+\infty}\left(\dfrac{1}{x^2}+\dfrac{\ln x}{x^2}\right) = 0$

គ. $\lim\limits_{x\to 0} x\ln x = 0$

4-គណនាដេរីវេនៃអនុគមន៍ខាងក្រោម

ក. $y = \sqrt{x}.\ln x$

ខ. $y = x\sqrt[3]{\ln x}$

គ. $y = \ln(x+\sqrt{1+x^2})$

**ដំណោះស្រាយ**

គណនាដេរីវេនៃអនុគមន៍ខាងក្រោម

ក. $\mathbf{y = \sqrt{x}.\ln x}$

គេបាន $\mathbf{y' = \frac{1}{2\sqrt{x}}\ln x + \frac{\sqrt{x}}{x}}$

ខ. $\mathbf{y = x\sqrt[3]{\ln x} = x(\ln x)^{\frac{1}{3}}}$

គេបាន $\mathbf{y' = (\ln x)^{\frac{1}{3}} + (\ln x)^{-\frac{2}{3}}}$

គ. $\mathbf{y = \ln(x + \sqrt{1+x^2})}$

គេបាន $\mathbf{y' = \dfrac{1 + \dfrac{2x}{2\sqrt{1+x^2}}}{x + \sqrt{1+x^2}}}$

$$\mathbf{= \frac{\sqrt{1+x^2} + x}{(x + \sqrt{1+x^2})\sqrt{1+x^2}} = \frac{1}{\sqrt{1+x^2}}}$$

ដូចនេះ $\mathbf{y' = \frac{1}{\sqrt{1+x^2}}}$ ។

5-គណនាដេរីវេនៃអនុគមន៍ខាងក្រោម

ក. $y=\ln\dfrac{e^x}{e^x+1}$

ខ. $y=x\ln x-x$

គ. $y=x^2\ln\dfrac{1}{x^2}$

**ដំណោះស្រាយ**

គណនាដេរីវេនៃអនុគមន៍ខាងក្រោម

ក. $y=\ln\dfrac{e^x}{e^x+1}=\ln e^x-\ln(e^x+1)=x-\ln(e^x+1)$

គេបាន $y'=1-\dfrac{e^x}{e^x+1}=\dfrac{1}{e^x+1}$

ខ. $y=x\ln x-x$

គេបាន $y'=\ln x-x.\dfrac{1}{x}-1=\ln x-2$

គ. $y=x^2\ln\dfrac{1}{x^2}=-x^2\ln x^2$

គេបាន $y'=-2x\ln x^2-x^2.\dfrac{2x}{x^2}=-2x(2\ln|x|+1)$

មេរៀនទី១

# ព្រីមីទីវ និង អាំងតេក្រាលមិនកំនត់

## ◆ និយមន័យ

$F(x)$ ជាព្រីមីទីវនៃ $f(x)$ កាលណា $F'(x)$ ចំពោះគ្រប់តម្លៃ $x$ ក្នុងដែនកំនត់នៃអនុគនី $f(x)$ ។

## ◆ ទ្រឹស្តីបទ

បើ $F(x)$ ជាព្រីមីទីវមួយនៃ $f(x)$ នោះព្រីមីទីវទាំងអស់នៃ $f(x)$ មានទម្រង់ទូទៅ $F(x)+C$ ដែល $C$ ជាចំនួនពិតថេរ ។

## ◆ និយមន័យអាំងតេក្រាលមិនកំនត់

បើ $F(x)$ ជាព្រីមីទីវមួយនៃ $f(x)$ នោះអាំងតេក្រាលមិនកំនត់នៃ $f(x)$ កំនត់ដោយ $\int f(x).dx = F(x) + C$

ដែល $C$ ជាចំនួនពិតថេរ ។

## ◆ លក្ខណៈអាំងតេក្រាលមិនកំនត់

1. $\int kf(x).dx = k.\int f(x).dx$ ដែល $k$ ជាចំនួនពិតថេរ ។

2. $\int [f(x) \pm g(x)].dx = \int f(x).dx \pm \int g(x).dx$

## ◆ រូបមន្តអាំងតេក្រាលមិនកំនត់

1. $\int k.dx = kx + C$

2. $\int x^n.dx = \frac{1}{n+1}x^{n+1} + C$ , $C \in IR$ , $n \neq -1$

3. $\int \frac{1}{x}.dx = \ln|x| + C$

4. $\int \frac{1}{x^2}.dx = -\frac{1}{x} + C$

5. $\int \frac{1}{\sqrt{x}}.dx = 2\sqrt{x} + C$

6. $\int e^x.dx = e^x + C$

7. $\int \sin x.dx = -\cos x + C$

8. $\int \cos x.dx = \sin x + C$

9. $\int \frac{1}{\cos^2 x}.dx = \tan x + C$

10. $\int \frac{1}{\sin^2 x}.dx = -\cot x + C$

11. $\int k.f'(x).dx = k.f(x) + C$

12. $\int f^n(x).f'(x).dx = \frac{1}{n+1}f^{n+1}(x) + C$

13. $\int f'(x).e^{f(x)}.dx = e^{f(x)} + C$

14. $\int \frac{f'(x)}{f(x)}.dx = \ln|f(x)| + C$

15. $\int \frac{f'(x)}{f^n(x)}.dx = -\frac{1}{(n-1)f^{n-1}(x)} + C$

16. $\int \frac{f'(x)}{f^2(x)}.dx = -\frac{1}{f(x)} + C$

17. $\int \frac{f'(x)}{\sqrt{f(x)}}.dx = 2\sqrt{f(x)} + C$

18. $\int \sin[f(x)].f'(x).dx = -\cos[f(x)] + C$

19. $\int \cos[f(x)].f'(x).dx = \sin[f(x)] + C$

20. $\int \frac{f'(x)}{\cos^2[f(x)]}.dx = \tan[f(x)] + C$

21. $\int \frac{f'(x)}{\sin^2 f(x)}.dx = -\cot[f(x)] + C$

◆ រូបមន្តអាំងតេក្រាលដោយផ្នែក

$$\int f(x).g'(x).dx = f(x).g(x) - \int g(x).f'(x).dx$$

## លំហាត់ និង ដំណោះស្រាយ

1-បង្ហាញថា $F(x)$ ជាព្រីមីទីវនៃ $f(x)$ , $\forall x \in IR$ ដែល

ក. $F(x) = -7x + 4$ និង $f(x) = -7$

ខ. $F(x) = 3x^3 - 7x$ និង $f(x) = 9x^2 - 7$

គ. $F(x) = 3e^{x^2-1} - 7$ និង $f(x) = 6xe^{x^2-1}$

ឃ. $F(x) = \ln(e^{3x} - x) + \sqrt{11}$ និង $f(x) = \dfrac{3e^{3x} - 1}{e^{3x} - x}$

### ដំណោះស្រាយ

បង្ហាញថា $F(x)$ ជាព្រីមីទីវនៃ $f(x)$ , $\forall x \in IR$

ក. $F(x) = -7x + 4$ និង $f(x) = -7$

គេមាន $F'(x) = -7 = f(x)$ , $\forall x \in IR$

ដូចនេះ $F(x) = -7x + 4$ ជាព្រីមីទីវនៃ $f(x) = -7$ ។

ខ. $F(x) = 3x^3 - 7x$ និង $f(x) = 9x^2 - 7$

គេមាន $F'(x) = 9x^2 - 7 = f(x)$ , $\forall x \in IR$

ដូចនេះ $F(x) = 3x^3 - 7x$ ជាព្រីមីទីវនៃ $f(x) = 9x^2 - 7$ ។

គ. $F(x)=3e^{x^2-1}-7$ និង $f(x)=6xe^{x^2-1}$

គេមាន $F'(x)=6xe^{x^2-1}=f(x)\ ,\ \forall x\in IR$

ដូចនេះ $F(x)=3e^{x^2-1}-7$ ជាព្រីមីទីវនៃ $f(x)=6xe^{x^2-1}$ ។

ឃ. $F(x)=\ln(e^{3x}-x)+\sqrt{11}$ និង $f(x)=\dfrac{3e^{3x}-1}{e^{3x}-x}$

គេមាន $F'(x)=\dfrac{(e^{3x}-x)'}{e^{3x}-x}=\dfrac{3e^{3x}-1}{e^{3x}-x}f(x)\ ,\ \forall x\in IR$

ដូចនេះ $F(x)=\ln(e^{3x}-x)+\sqrt{11}$ ជាព្រីមីទីវនៃ $f(x)=\dfrac{3e^{3x}-1}{e^{3x}-x}$

2-រកព្រីមីទីវ $F(x)$ នៃ $f(x)$ កំណត់និងជាប់លើចន្លោះ $I$ ដោយ

ក. $f(x)=5\ \ ,\ I=IR$ ខ. $f(x)=-4x+3\ ,\ I=IR$

គ. $f(x)=-x^2+3x+5\ ,\ I=IR$

ឃ. $f(x)=\dfrac{2}{x}\ ;\ I=(0\ ,+\infty)$

ង. $f(x)=\dfrac{1}{3x+2}\ ,\ I=(-\dfrac{2}{3}\ ,+\infty)$

ច. $f(x)=\dfrac{x}{x^2+5}$ ឆ. $f(x)=e^{3x-2}$

ជ. $f(x)=xe^{x^2}\ \ ,\ I=IR$ ។

**ដំណោះស្រាយ**

រកព្រីមីទីវ $\mathbf{F(x)}$ នៃ $\mathbf{f(x)}$

ក. $\mathbf{f(x)=5 \quad , I = IR}$

តាមនិយមន័យគេបាន $\mathbf{F'(x)=f(x)=5}$

គេទាញ $\mathbf{F(x)=\int 5dx = 5x+C \quad , \quad C \in IR}$

ខ. $\mathbf{f(x)=-4x+3 \ , I = IR}$

តាមនិយមន័យគេបាន $\mathbf{F'(x)=f(x)=-4x+3}$

គេទាញ $\mathbf{F(x)=\int (-4x+3)dx = -2x^2+3x+C \quad , \quad C \in IR}$

គ. $\mathbf{f(x)=-x^2+3x+5 \ , I = IR}$

តាមនិយមន័យគេបាន $\mathbf{F'(x)=f(x)=-x^2+3x+5}$

គេទាញ

$$\mathbf{F(x)=\int (-x^2+3x+5).dx}$$

$$\mathbf{=-\frac{x^3}{3}+\frac{3x^2}{2}+5x+C \quad , \quad C \in IR}$$

ឃ. $\mathbf{f(x)=\frac{2}{x} \ ; \ I=(0 \ , +\infty)}$

តាមនិយមន័យគេបាន $\mathbf{F'(x)=f(x)=\frac{2}{x}}$

គេទាញ $F(x)=\int \frac{2}{x}dx = 2\ln x + C$ , $C \in IR$

ង. $f(x)=\frac{1}{3x+2}$ , $I=(-\frac{2}{3},+\infty)$

តាមនិយមន័យគេបាន $F'(x)=f(x)=5$

គេទាញ $F(x)=\int \frac{1}{3x+2}dx = \frac{1}{3}\ln(3x+2)+C$ , $C \in IR$

ច. $f(x)=\frac{x}{x^2+5}$

តាមនិយមន័យគេបាន $F'(x)=f(x)=\frac{x}{x^2+5}$

គេទាញ $F(x)=\int \frac{x}{x^2+5}dx = \frac{1}{2}\ln(x^2+5)+C$ , $C \in IR$

ឆ. $f(x)=e^{3x-2}$

តាមនិយមន័យគេបាន $F'(x)=f(x)=e^{3x-2}$

គេទាញ $F(x)=\int e^{3x-2}dx = \frac{1}{3}e^{3x-2}+C$ , $C \in IR$

ជ. $f(x)=xe^{x^2}$ , $I=IR$

តាមនិយមន័យគេបាន $F'(x)=f(x)=xe^{x^2}$

គេទាញ $F(x)=\int xe^{x^2}dx = \frac{1}{2}e^{x^2}+C$ , $C \in IR$ ។

3-រកព្រីមីទីវ $F(x)$ នៃអនុគមន៍ $f$ ដែលកំនត់ដោយ

ក.$f(x)=\frac{3}{\cos^2 x}$ និង $F(\frac{\pi}{4})=-1$

ខ.$f(x)=x^2-x$ និង $F(o)=1$

គ. $f(x)=x^2-e^x$ និង $F(0)=1$

ឃ.$f(x)=x^2-xe^{x^2}$ និង $F(0)=1$

**ដំណោះស្រាយ**

រកព្រីមីទីវ $F(x)$ នៃអនុគមន៍ $f$ ដែលកំនត់ដោយ

ក.$f(x)=\frac{3}{\cos^2 x}$ និង $F(\frac{\pi}{4})=-1$

**គេបាន** $F'(x)=f(x)=\frac{3}{\cos^2 x}$

គេទាញ $F(x)=\int \frac{3}{\cos^2 x}dx=3\tan x+C$

បើ $x=\frac{\pi}{4}$ នោះ $F(\frac{\pi}{4})=3\tan\frac{\pi}{4}+C=-1\Rightarrow C=-4$

**ដូចនេះ** $F(x)=3\tan x-4$ ។

ខ.$f(x)=x^2-x$ និង $F(o)=1$

គេបាន $F'(x)=f(x)=x^2-x$

គេទាញ $F(x)=\int (x^2-x)dx=\frac{1}{3}x^3-\frac{1}{2}x^2+C$

បើ $x=0$ នោះ $F(0)=C=1$

ដូចនេះ $F(x)=\frac{1}{3}x^3-\frac{1}{2}x^2+1$ ។

គ. $f(x)=x^2-e^x$ និង $F(0)=1$

គេបាន $F'(x)=f(x)=x^2-e^x$

គេទាញ $F(x)=\int (x^2-e^x)dx=\frac{1}{3}x^3-e^x+C$

បើ $x=0$ នោះ $F(0)=-1+C=1\Rightarrow C=2$

ដូចនេះ $F(x)=\frac{1}{3}x^3-e^x+2$ ។

ឃ.$f(x)=x^2-xe^{x^2}$ និង $F(0)=1$

គេបាន $F'(x)=f(x)=x^2-xe^{x^2}$

គេទាញ $F(x)=\int (x^2-xe^{x^2})dx=\frac{1}{3}x^3-\frac{1}{2}e^{x^2}+C$

បើ $x=0$ នោះ $F(0)=-\frac{1}{2}+C=1\Rightarrow C=\frac{3}{2}$

ដូចនេះ $F(x)=\frac{1}{3}x^3-\frac{1}{2}e^{x^2}+\frac{3}{2}$ ។

4-រកព្រីមីទីវ $F(x)$ នៃអនុគមន៍ $f$ ដែលកំណត់ដោយ

ក. $f(x)=\sin x$ និង $F(0)=3$

ខ. $f(x)=x-e^{x}$ និង $F(1)=1-e$

គ. $f(x)=\dfrac{x}{(x^{2}-4)^{3}}$ និង $F(5)=3$

ឃ. $f(x)=\sin x\cos^{3}x$ និង $F(\frac{\pi}{4})=16$

## ដំណោះស្រាយ

**រកព្រីមីទីវ $F(x)$ នៃអនុគមន៍ $f$ ដែលកំណត់ដោយ**

**ក. $f(x)=\sin x$ និង $F(0)=3$**

គេបាន $F'(x)=f(x)=\sin x$

គេទាញ $F(x)=\int \sin x\,dx=-\cos x+C$

បើ $x=0$ នោះ $F(0)=-1+C=3\Rightarrow C=4$

ដូចនេះ $F(x)=-\cos x+4$ ។

ខ. $f(x) = x - e^x$ និង $F(1) = 1 - e$

គេបាន $F'(x) = f(x) = x - e^x$

គេទាញ $F(x) = \int (x - e^x)dx = \frac{1}{2}x^2 - e^x + C$

បើ $x = 1$ នោះ $F(1) = \frac{1}{2} - e + C = 1 - e \Rightarrow C = \frac{1}{2}$

ដូចនេះ $F(x) = \frac{1}{2}x^2 - e^x + \frac{1}{2}$ ។

គ. $f(x) = \frac{x}{(x^2 - 4)^3}$ និង $F(5) = 3$

គេបាន $F'(x) = f(x) = \frac{x}{(x^2 - 4)^3}$

គេទាញ $F(x) = \int \frac{x}{(x^2 - 4)^3}.dx$

តាង $u = x^2 - 4 \Rightarrow du = 2xdx$

គេបាន $F(x) = \frac{1}{2}\int u^{-3}du = -\frac{1}{4}u^{-2} + C$

ឬ $F(x) = -\frac{1}{4}.\frac{1}{(x^2 - 4)^2} + C$

បើ $x = 5$ នោះ $F(5) = -\frac{1}{1764} + C = 3 \Rightarrow C = \frac{5293}{1764}$

ដូចនេះ $F(x) = -\frac{1}{4(x^2 - 4)^2} + \frac{5293}{1764}$ ។

ឃ.$f(x)=\sin x\cos^3 x$ និង $F(\frac{\pi}{4})=16$

**គេបាន** $F'(x)=f(x)=\sin x\cos^3 x$

គេទាញ $F(x)=\int \sin x\cos^3 x dx=-\frac{1}{4}\cos^4 x+C$

បើ $x=\frac{\pi}{4}$ នោះ $F(\frac{\pi}{4})=-\frac{1}{16}+C=16\Rightarrow C=\frac{257}{16}$

**ដូចនេះ** $F(x)=-\frac{1}{4}\cos^4 x+\frac{257}{16}$ ។

5-គណនាអាំងតេក្រាលខាងក្រោម

ក.$\int (2x^3-5x^2+3x+1)dx$ ខ.$\int (5-\frac{1}{\sqrt{x}})dx$

គ.$\int 2\sqrt[4]{x}.dx$ ឃ.$\int (\frac{3}{x^4}+\frac{1}{x^5})dx$

ង.$\int (x^2-1)\sqrt{x}.dx$ ច.$\int (2e^x+\frac{6}{x}-\ln 5)dx$

ឆ.$\int \frac{4x^4-3x^5+1}{x^4}dx$ ជ.$\int \frac{3x^2-2x+1}{\sqrt{x}}.dx$

ឈ.$\int (3\sin x+5\cos x)dx$ ញ.$\int (\frac{1}{\sin^2 x}+\frac{4}{\cos^2 x}-5)dx$

ដ.$\int \frac{e^{3x}+1}{e^x+1}.dx$ ឋ.$\int (1-e^x)^2 dx$

## ដំណោះស្រាយ

គណនាអាំងតេក្រាលខាងក្រោម

ក. $\int (2x^3 - 5x^2 + 3x + 1)dx$

$= 2\int x^3dx - 5\int x^2dx + 3\int xdx + \int dx$

$= \frac{1}{2}x^4 - \frac{5}{3}x^3 + \frac{3}{2}x^2 + x + C$

ខ. $\int (5 - \frac{1}{\sqrt{x}})dx$

$= 5\int dx - \int \frac{dx}{\sqrt{x}}$

$= 5x - 2\sqrt{x} + C$

គ. $\int 2\sqrt[4]{x}.dx$

$= 2\int x^{\frac{1}{4}}dx = \frac{8}{5}x^{\frac{5}{4}} + C$

ឃ. $\int (\frac{3}{x^4} + \frac{1}{x^5})dx$

$= 3\int x^{-4}dx + \int x^{-5}dx = -x^{-3} - \frac{1}{4}x^{-4} + C$

ង. $\int (x^2 - 1)\sqrt{x}.dx$

$= \int x^{\frac{5}{2}}dx - \int x^{\frac{1}{2}}dx = \frac{2}{7}x^{\frac{7}{2}} - \frac{2}{3}x^{\frac{3}{2}} + C$

ច. $\int (2e^x + \frac{6}{x} - \ln 5)dx$

$= 2\int e^x + 6\int \frac{dx}{x} - \ln 5\int dx$

$= 2e^x + 6\ln|x| - x\ln 5 + C$

ឆ. $\int \frac{4x^4 - 3x^5 + 1}{x^4}dx$

$= 4\int dx - 3\int xdx + \int x^{-4}dx$

$= 4x - \frac{3}{2}x^2 - \frac{1}{3}x^{-3} + C$

ជ. $\int \frac{3x^2 - 2x + 1}{\sqrt{x}}.dx$

$= 3\int x^{\frac{3}{2}}dx - 2\int x^{\frac{1}{2}}dx + \int \frac{dx}{\sqrt{x}}$

$= \frac{6}{5}x^{\frac{5}{2}} - \frac{4}{3}x^{\frac{3}{2}} + 2\sqrt{x} + C$

ឈ. $\int (3\sin x + 5\cos x)dx$

$= 3\int \sin xdx + 5\int \cos xdx$

$= -3\cos x + 5\sin x + C$

